អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 22-Oct-2012, 15:20
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០៥ នាទី**

**សវនាការលើកទី១២០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ *(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ *(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង) *(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា *(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

កញ្ញា សុង ឆវន្ត

លោក ឃីត រេយ៍ន័រ *(Mr.Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡោ ជុនធី

លោក សំ សុគង់

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្សី | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក សំ សុគង់ | ខ្មែរ |
| លោកស្រី យឹម សុវណ្ណ (TCCP-169) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី យឹម សុវណ្ណា** (TCCP-169)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី៖........................................................................ទំព័រ ៥២

សួរដោយលោក សំ សុគង់ ផ្តើមពី៖........................................................................ទំព័រ ៥៥

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី៖..........................................ទំព័រ ៦៦

សួរដោយលោក ឃីត រេយ៍ន័រ ផ្តើមពី៖..................................................................ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ នឹងបន្តនីតិវិធីភាគីដាក់ឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ នូវបណ្តាឯកសារទាំងឡាយដែលចាំបាច់សំខាន់ៗដែលពាក់ព័ន្ធទៅនឹងអង្គហេតុរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ ហើយកាលពីម្សិលមិញនេះ គឺដល់វេទិកានៃក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលនៅព្រឹកនេះនឹងមានឱកាសក្នុងការដាក់ឯកសាររយៈពេល១ម៉ោងថែមទៀត។ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមានអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៧:០៧]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ប៉ុន្តែយោងតាមពាក្យសុំលះបង់សិទ្ធិរបស់ជនជាប់ចោទ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១២ ឯកសារលេខ E237 ជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការនៃការស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន។ ក្នុងនោះមានដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 ដែលអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងស្តាប់សក្ខីកម្មនៅក្នុងថ្ងៃនេះ។ លោក ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្តីឱ្យលោក អៀង សារី អវត្តមាន ដោយមូលហេតុមានធុរៈផ្ទាល់ខ្លួន។

[០៩:០៧:៥៤]

ហើយដើមបណ្តឹងរដ្ឋប្បវេណី TCCP-169 នឹងមានវត្តមាននៅបន្ទប់រង់ចាំនៅម៉ោងដប់សាមសិបនាទីព្រឹកនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជា -- សូមអញ្ជើញលោកមេធាវី!

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ ទាក់ទងទៅនឹងការប្រកាសកាលពីពេលលើកមុន យើងនឹងបន្តទៅសក្ខីកម្មនៅពេលរសៀលនេះ។ តើមែនដែរឬទេ? គឺថា តើយើងនឹងបន្តស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី តើមែនដែរឬទេ?

[០៩:០៨:៤១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានកំណត់នូវកាលបរិច្ឆេទនៃភាគីដាក់ឯកសារ គឺតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ២ថ្ងៃ ហើយនិងសម្រាប់ក្រុមមេធាវីការពារក្តី ២ថ្ងៃ។ ដូច្នេះ អង្គជំនុំជម្រះនឹងគោរព និងអនុវត្តតាមនូវអ្វីដែលអង្គជំនុំជម្រះបានចេញសេចក្តីណែនាំរួចហើយ អំពីកាលវិភាគនៃកិច្ចដំណើរការសវនាការស្តាប់ -- ផ្តល់ការបង្ហាញឯកសារភស្តុតាងបញ្ចប់នូវអង្គហេតុពាក់ព័ន្ធជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យនេះ។ ប៉ុន្តែថ្ងៃនេះ អង្គជំនុំជម្រះបានត្រៀមបម្រុងទុកនូវដើមបណ្តឹងរដ្ឋប្បវេណីមួយរូបសម្រាប់បន្តកិច្ចដំណើរការនីតិវិធី ក្នុងន័យជំរុញល្បឿនកិច្ចដំណើរការនីតិវិធីសវនាការឲ្យប្រព្រឹត្តទៅឆាប់រហ័ស ក្នុងករណីដែលក្រុមមេធាវីការពារក្តីមិន -- សម្រេចចិត្តមិនដាក់បង្ហាញឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

នេះជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះគ្រោងកោះអញ្ជើញមកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកបម្រុង មិនឲ្យពេលវេលាហ្នឹងវាខាតបង់ឥតប្រយោជន៍។

[០៩:១០:៣៤]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ នេះគឺជាអ្វីដែលខ្ញុំចង់បាន។ សូមអរគុណច្រើនលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

[០៩:១០:៥៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម ភាគីដើមបណ្តឹងរដ្ឋប្បវេណី សាធាណរជន ហើយនិងព្រះសង្ឃគ្រប់ព្រះអង្គ!

ខ្ញុំបាទ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃនេះខ្ញុំ ហើយនិងសហភាតាខ្ញុំ នៅក្នុងរយៈពេល១ម៉ោងនេះ នឹងបង្ហើយអំពីការបង្ហាញឯកសារ។ ពីម្សិលមិញខ្ញុំបានបង្ហាញឯកសារមួយចំនួនរួចហើយ ដែលជាកិច្ចសម្ភាសន៍ជាមួយលោកនិង -- លោក នួន ជា និងលោក ខៀវ សំផន។ ថ្ងៃនេះខ្ញុំនៅមានឈុតវីដេអូចុងក្រោយ ដែលនឹងត្រូវបង្ហាញ ដែលជាកិច្ចសម្ភាសន៍ជាមួយនឹងលោកខៀវ សំផន ដែលឈុតវីដេអូនេះខ្ញុំសូមលើកលេខសាជាថ្មីគឺជាវីដេអូដែលមានលេខ E109/2.3R ហើយឈុតនេះ គឺជាឈុតទី២ នៃក្នុងចំណោមឈុតដែលខ្ញុំបានផ្តល់ជូនទៅមន្ត្រីសោតទស្សន៍រួចហើយ។ ដូច្នេះសូមលោកប្រធានមេត្តាអនុញ្ញាត ដើម្បីឲ្យមន្ត្រីសោតទស្សន៍ដាក់បញ្ចាំងជូនសាធារណជន។

សូមអរគុណ។

[០៩:១២:១៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

បុគ្គលិកសោតទស្សន៍ បង្ហាញឯកសារ -- បង្ហាញឈុតវីដេអូនៅលើ នៅអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:១២:៤៦]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"[...] ខំគោរពវិន័យតាមចលនា។ គោរពវិន័យក្នុងស្មារតីថា ខ្ញុំមិនបានទៅនៀយហាត់ជាមួយបងប្អូននៅតាមការដ្ឋាន នៅតាមសហករណ៍ ហាលថ្ងៃ ហាលក្តៅ ហាលភ្លៀង ខ្យល់ ខ្ញុំនៅមួយកន្លែងធ្វើម៉េចកុំឲ្យអំពល់រវល់ដល់គេ។ ស្មារតីខ្ញុំអ៊ីចឹងទេ ដែលនាំឲ្យខ្ញុំថា គឺថាខ្ញុំម៉េចក៏មិនរកយល់ រកដឹង។ ទី១ ខ្ញុំវា វាអត់នឹកស្មាន ពីព្រោះចលនាវាស្នេហាជាតិអ៊ីចឹងទៅហើយ ខ្ញុំវាទុកចិត្តអ៊ីចឹង។ ទី២ ក៏គិតថារួមចំណែកក្នុងការហៀយហាត់ដោយខ្លួនឯង មិនបានទៅនៀយហាត់ដូចបងប្អូន ធ្វើម៉េចកុំទៅអំពល់រវល់ដល់គេ ហើយខ្លួនឯងក៏រស់នៅឲ្យសមរម្យ កុំឲ្យពេលដែលគេទៅនៀយហាត់ហាលថ្ងៃ ហាលក្តៅ ហូបចុកខ្វះខាត ឯខ្លួនឯងនៅភ្នំពេញឯណេះ គិតតែពីសប្បាយហ៊ឺហា ហូបឆ្ងាញ់តែម្នាក់ឯង ទាំងប្តី ទាំង*

*ប្រពន្ធខ្ញុំ។ អ៊ីចឹងបានថា ប្រពន្ធខ្ញុំ ខ្ញុំជាប្រមុខរដ្ឋប្រពន្ធខ្ញុំដាំបាយ ខ្ញុំអត់តូចចិត្តទេ។ ខ្ញុំអត់តូចចិត្តទេ ពីព្រោះខ្ញុំថា ឥឡូវខ្ញុំក៏មិនបានទៅរួមហាលថ្ងៃ ហាលក្តៅហ្នឹងគេ ប្រពន្ធខ្ញុំក៏មិនបានទៅរួមហាលថ្ងៃ ហាលក្តៅ នឹងគេ។ ចុះហេតុផលអីនឹងទៅតូចចិត្តតូចថ្លើម? បើខ្លួននៅពីភ្នំពេញនេះបានសុខ បានស្រួល ជុំកូន ជុំចៅដែរ ពិតមែនតែកូនចៅហ្នឹងវាទៅនៅក្នុងមន្ទីរកុមារ ប៉ុន្តែ១អាទិត្យវាមកលេងផ្ទះម្តងៗដែរ។ វាគ្រាន់បើជាងបងប្អូននៅឯណោះដែរ។ អ៊ីចឹងរឿងអីទៅទោមនស្ស?"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[០៩:១៥:៤០]

បាទ សូមអរគុណ។ ខ្ញុំសូមបញ្ជាក់បន្តិច ដោយសារខ្ញុំមិនបានបញ្ជាក់អម្បាញ់មិញ។ ឃ្លីបវីដេអូនេះគឺ នៅចាប់ពីនាទីទី២៦ និង៣០វិនាទី ដល់នាទីទី២៨ និង២០នាទី នៅក្នុងឯកសារដូចខ្ញុំបានជម្រាបជូន។ ហើយពាក់ព័ន្ធទៅនឹងសហករណ៍ ហើយនិយាយអំពីស្ថានភាពរបស់ជនរងគ្រោះនៅសហករណ៍។ ហើយជាបន្តទៀតនេះ ខ្ញុំសូមអនុញ្ញាតលោកប្រធានអានឯកសារដែលជាលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាដែលចាប់ពីមាត្រា៨ នៃ -- អ៎! មាត្រា៧ នៃលក្ខន្តិកៈនេះ ដែលនិយាយអំពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជាពីមជ្ឈិមរហូតទៅដល់មូលដ្ឋាន។ សូមលោកប្រធានអនុញ្ញាត។ ហើយឯកសារបក្ស -- លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជានេះគឺ ឯកសារដែលមានលេខ IS9.1។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[០៩:១៦:០០]

**លោក ពេជ អង្គ៖**

បាទ ចាប់ពីមាត្រា៧ បាទ ខ្ញុំសូមបញ្ជាក់បន្តិចថា ដោយសារថាឯកសារ ឈ្មោះឯកសារខ្ញុំបានជម្រាបជូនរួចហើយ ហើយដើម្បីចៀសវាងការអានលេខ ERN ខ្ញុំអានជាមាត្រាតែម្តង ដើម្បីឲ្យភាគីងាយស្រួលក្នុងការតាម។ អ៊ីចឹងមាត្រ --

<u>"អំពីខ្សែចាត់តាំងរបស់បក្ស</u>

មាត្រា៧៖ ខ្សែចាត់តាំងរបស់បក្សមានដូចតទៅ៖ ១) អង្គការរបស់ បក្សមានសិទ្ធិអំណាចធំជាងគេបំផុត សម្រាប់ទូទាំងប្រទេស គឺមហាសន្និបាតតំណាងទូទាំងប្រទេស។ ក្នុងរយៈពេលពីមហាសន្និបាតមួយទៅមួយទៀត មានអង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសម្រាប់ទូទាំងប្រទេស គឺគណៈ

កម្មាធិការមជ្ឈិម។ ២) អង្គការមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ភូមិភាគនីមួយៗគឺ សន្និបាតតំណាងភូមិភាគនីមួយៗ នោះក្នុងរយៈពេលពីសន្និបាតភូមិភាគមួយទៅមួយទៀតមានអង្គការប្រតិបត្តិខ្ពស់ជាងគេបំផុតសម្រាប់ភូមិភាគនីមួយៗនោះគឺគណៈកម្មាធិការភូមិភាគ។ ៣) អង្គការមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់តំបន់ ឬក្រុងនីមួយៗ គឺសន្និបាតតំណាងតំបន់ ឬក្រុងនីមួយៗនោះ។ ក្នុងរយៈពេលពីសន្និបាតតំបន់ ឬក្រុងមួយទៅមួយទៀត មានអង្គការប្រតិបត្តិការខ្ពស់ជាងគេបំផុតសម្រាប់តំបន់ ឬក្រុងនីមួយៗនោះគឺ គណៈកម្មាធិការតំបន់ ឬក្រុង។ ៤) អង្គការមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ស្រុកនីមួយៗ គឺសន្និបាតតំណាងស្រុក។ ក្នុងរយៈពេលពីសន្និបាតស្រុកមួយទៅមួយទៀត មានអង្គការប្រតិបត្តិការសម្រាប់ស្រុកនីមួយៗគឺ គណៈកម្មាធិការស្រុក។ ៥) អង្គការមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់សាខា គឺសន្និបាតតំណាងសាខា។ ចំពោះសាខាធំ (ឬសន្និបាតសាខាទូទាំង អំ! សន្និបាតសាខាទាំងមូលតែម្តង (សម្រាប់សាខាតូច)។ ក្នុងរយៈពេលពីសន្និបាតមួយ ទៅសន្និបាតមួយទៀតរបស់សាខា មានអង្គការប្រតិបត្តិសម្រាប់សាខានីមួយៗគឺ គណៈកម្មាធិការសាខា ចំពោះសាខាធំ ឬលេខា និងអនុលេខាចំពោះសាខាតូច។ ៦) ចំពោះអង្គការបក្សក្នុងកងទ័ពបដិវត្តន៍កម្ពុជា ក៏មានខ្សែចាត់តាំងដូចនេះដែរ តាមក្របខ័ណ្ឌថ្នាក់បក្សនីមួយៗ។ ៨) ចំពោះតំបន់ណា ឬអង្គការណាដែលមានលក្ខណៈពិសេសខាងនយោបាយក្តី ខាងយោធាក្តី ខាងសេដ្ឋកិច្ចក្តី ខាងវប្បធម៌ក្តី សង្គមកិច្ចក្តី អាចចាត់តាំងជាផ្នែកដោយឡែកដោយគណៈកម្មាធិការមជ្ឈិមទទួលភារៈដឹកនាំដោយផ្ទាល់ ឬដោយប្រយោលតាមខ្សែចាត់តាំងជាក់ស្តែង។

[០៩:១៩:៣២]

<u>មាត្រា៩៖ អំពីសាខា</u>

សហករណ៍ ឬរោងចក្រ អង្គភាពអនុសេនាធំយោធា ការដ្ឋាន ក្រសួង មន្ទីរបដិវត្តន៍នីមួយៗ អាចចាត់តាំងជាសាខារបស់បក្សបាន ឲ្យតែមានបេក្ខជនពីបីនាក់ឡើងទៅ។ ចំពោះសាខាដែលមានបេក្ខជនពីបីនាក់ឡើងដល់ប្រាំបីនាក់ ត្រូវជ្រើសតាំងលេខា១រូប និងអនុលេខាមួយរូបដើម្បីដឹកនាំការងារប្រចាំថ្ងៃ។ ចំពោះសាខាដែលមានបក្ខជនពីប្រាំបីនាក់ឡើងទៅ ត្រូវជ្រើសតាំងគណៈកម្មាធិការមួយរបស់សាខាដើម្បីដឹកនាំ។ បើចាំបាច់ក្នុងការងារអាចចាត់តាំងជាអនុសាខារបស់សាខាបាន។

<u>មាត្រា១០៖ អំពីភារកិច្ចរបស់សាខា</u>

សាខាមានភារកិច្ចពីរយ៉ាងដូចតទៅ៖

១) ភារកិច្ចក្នុងមហាជន គឺឃោសនា អប់រំមហាជន ជាផែនការនិងកម្មវិធីជាក់ស្ដែងនៅទីកន្លែងរបស់ខ្លួនក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍អំពីមាគ៌ា គោលជំហរសតិអារម្មណ៍ មាគ៌ាចាត់តាំងតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យក្នុងជំហរតស៊ូវណ្ណៈនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ព្រមជាមួយនោះ ក៏ត្រូវក្ដាប់និងបំផុសបំផុលអង្គការមហាជនក្នុងកន្លែងនីមួយៗ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ដើម្បីធ្វើសកម្មភាពបដិវត្តន៍យ៉ាងខ្លាំងក្លាតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។

[០៩:២១:២១]

២) ភារកិច្ចក្នុងគឺៈ ក) អប់រំកសាងបេក្ខជន និងអង្គការស្នូលជាប់ខាងនយោបាយ សតិអារម្មណ៍ ចាត់តាំងតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យក្នុងជំហរតស៊ូវណ្ណៈនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ខ) ក្ដាប់ការចាត់តាំងជាប់ក្នុងការពង្រឹងពង្រីក សម្រិតសម្រាំងបក្ខជន និងអង្គការស្នូល។ ចាត់ចែងភារកិច្ចអង្គការស្នូលឲ្យធ្វើការងារក្នុងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ឲ្យច្បាស់ ឲ្យជ្រៅ និងឲ្យជាប់ដើម្បីបំផុសចលនាបដិវត្តន៍ឲ្យក្ដៅជានិច្ច តាមមាគ៌ានយោបាយការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យរបស់បក្សតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ អនុវត្តជីវភាពសាខាទៀងទាត់ និងហ្មត់ចត់១ខែម្ដង។ កាន់កាប់ទ្រព្យសម្បត្តិរបស់សាខា អនុវត្តវិន័យក្នុងសាខា មានរបបរាយការណ៍អំពីស្ថានការណ៍ និងការងារសាខាជូនថ្នាក់លើ។

[០៩:២២:៤០]

ខ្ញុំសូមរំលងទៅ មាត្រា១២ អំពីគណៈកម្មាធិការស្រុក។

គណៈកម្មាធិការស្រុកត្រូវធ្វើសន្និបាតតំណាងស្រុកជាសាមញ្ញ ៦ខែម្ដង ដើម្បីពិនិត្យតាមដាន និងវិនិច្ឆ័យសកម្មភាពស្រុក ដោយដកពិសោធន៍រកគុណសម្បត្តិ និងគុណវិបត្តិច្បាស់លាស់ និងជ្រៅជ្រះ។

២) កំណត់ការងារថ្មីតាមមាគ៌ានយោបាយរបស់បក្ស ត្រូវកំណត់ផែនការ ការងារក្នុងមហាជនឲ្យបានច្បាស់ និងការងារផ្ទៃក្នុងឲ្យច្បាស់ក្នុងក្របខ័ណ្ឌស្រុករបស់ខ្លួន។ ៣) ជ្រើសរើសអង្គការដឹកនាំជាគណៈកម្មាធិការស្រុក ឈរលើលក្ខណៈសម្បត្តិ ១០យ៉ាងរបស់បក្ស ហើយត្រូវមានគណៈកម្មាធិការតំបន់ និងគណៈកម្មាធិការភូមិភាគ ពិនិត្យ និងវិនិច្ឆ័យ និងយល់ព្រមទើបបានការ។

១៣) <u>ភារកិច្ចរបស់គណៈកម្មាធិការស្រុក</u>

ភារកិច្ចរបស់គណៈកម្មាធិការស្រុកគឺ ចុះជាប់សាខា ជាប់នឹងមូលដ្ឋានជាក់ស្តែងរបស់សាខាក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ដើម្បីដឹកនាំអនុវត្តភារកិច្ចក្នុងមហាជន និងផ្ទៃក្នុងឲ្យបានសកម្ម ក្តៅជាប់ជាផែនការតាមគោលនយោបាយការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិប-តេយ្យរបស់បក្ស និងតាមទិសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់បក្ស។

[០៩:២៤:០២]

២) ក្តាប់មហាជនក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ក្នុងក្របខ័ណ្ឌស្រុករបស់ខ្លួនឲ្យជាប់ ឲ្យណែនជានិច្ចខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ឲ្យជាប់ជានិច្ចក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់បក្ស។ ៣) ក្តាប់សាខាកម្មាភិបាល និងបក្ខជន ព្រមទាំងអង្គការស្នូលទាំងអស់នៅក្នុងស្រុកឲ្យជាប់ និងឲ្យណែនជានិច្ចខាងប្រវត្តិរូប ខាងគោលនយោបាយ សតិអារម្មណ៍ និងចាត់តាំង ហើយអប់រំបំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ចនៅក្នុងការការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់បក្ស។ ៤) កាន់កាប់ទ្រព្យសម្បត្តិទាំងអស់របស់អង្គការស្រុក អនុវត្តវិន័យក្នុងក្របខ័ណ្ឌស្រុក មានរបបរាយការណ៍អំពីស្ថានការ និងការងាររបស់ស្រុកជូនថ្នាក់លើ។

[០៩:២៤:៥៦]

មាត្រា១៤៖ គណៈកម្មាធិការស្រុកត្រូវប្រជុំជាសាមញ្ញ១ខែម្តង ដើម្បីពិនិត្យ តាមដានវិនិច្ឆ័យការងារចាស់ និងលើកការងារថ្មី។

<u>អំពីគណៈកម្មាធិការ តំបន់ ក្រុង</u>

មាត្រា១៥៖ គណៈកម្មាធិការតំបន់ ក្រុង ត្រូវធ្វើសន្និបាតតំណាងតំបន់ ក្រុង ជាសាមញ្ញ៦ខែម្តង ដើម្បីពិនិត្យតាមដាន និងវិនិច្ឆ័យតំបន់ ក្រុង ដោយដកពិសោធន៍រកគុណសម្បត្តិ និងគុណវិបត្តិឲ្យច្បាស់លាស់ និងជ្រៅជ្រះ។

២) កំណត់ការងារថ្មីរបស់ -- តាមមាគ៌ានយោបាយរបស់បក្ស ត្រូវកំណត់ផែនការងារក្នុងមហាជនឲ្យច្បាស់ និងការងារផ្ទៃក្នុងឲ្យច្បាស់ ក្នុងក្របខ័ណ្ឌតំបន់ ក្រុងរបស់ខ្លួន។ ៣) ជ្រើសរើសអង្គការដឹកនាំថ្មី ជាគណៈកម្មាធិការតំបន់ គណៈកម្មាធិការក្រុង ឈរលើលក្ខណៈ១០យ៉ាងរបស់បក្ស

ហើយត្រូវគណៈកម្មាធិការភូមិភាគ និងគណៈកម្មាធិការមជ្ឈិមពិនិត្យវិនិច្ឆ័យនិងយល់ព្រម ទើបបានការ។

[០៩:២៥:៥៨]

<u>មាត្រា១៦៖ ភារកិច្ចរបស់គណៈកម្មាធិការតំបន់ ក្រុង</u>

ភារកិច្ចរបស់គណៈកម្មាធិការតំបន់ ក្រុង គឺ ១) ចុះជាប់ស្រុកសាខា និងមូលដ្ឋានជាក់ស្តែងរបស់សាខា ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ដើម្បីដឹកនាំអនុវត្តភារកិច្ចក្នុងមហាជន និងផ្ទៃក្នុង ឲ្យសកម្មក្តៅជាប់ជាផែនការ តាមការភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ២) ក្តាប់មហាជនក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ក្នុងក្របខ័ណ្ឌតំបន់ ក្រុង របស់ខ្លួនឲ្យជាប់ និងឲ្យណែនាំជានិច្ចខាងនយោបាយ សតិអារម្មណ៍ ចាត់តាំងដោយអប់រំ បំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ ចាត់តាំងឲ្យជាប់ជានិច្ចតាមភារកិច្ច ការពារប្រទេស និងការកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ៣) ក្តាប់អង្គការស្រុក អង្គការសាខា គណៈកម្មាធិការបក្ខជន និងអង្គការស្នូលទាំងអស់ ក្នុងតំបន់ ខាងប្រវត្តិរូប ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ហើយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច តាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ៤) កាន់កាប់ទ្រព្យសម្បត្តិរបស់អង្គការតំបន់ ក្រុង អនុវត្តវិន័យក្នុងក្របខ័ណ្ឌតំបន់ ក្រុង មានរបបរាយការណ៍អំពីស្ថានការណ៍ និងការងាររបស់តំបន់ ក្រុង ជូនថ្នាក់លើ។

[០៩:២៧:៤៨]

មាត្រា១៧៖ គណៈកម្មាធិការតំបន់ ក្រុង ត្រូវប្រជុំជាសាមញ្ញ១ខែម្តង ដើម្បីពិនិត្យ តាមដានវិនិច្ឆ័យ ការងារចាស់ និងលើកការងារថ្មី។ គណៈកម្មាធិការភូមិភាគត្រូវ -- សូមទោស!

<u>អំពីគណៈកម្មាធិការភូមិភាគ</u>

មាត្រា១៨៖ គណៈកម្មាធិការភូមិភាគ ត្រូវធ្វើសន្និបាតតំណាងភូមិភាគជាសាមញ្ញ១ឆ្នាំម្តង ដើម្បី, ១) ពិនិត្យ តាមដាន និងវិនិច្ឆ័យសកម្មភាពរបស់ភូមិភាគ ដោយដកពិសោធន៍រកគុណសម្បត្តិ និងគុណវិបត្តិ ឲ្យច្បាស់លាស់ និងជ្រៅជ្រះ។ ២) កំណត់ការងារថ្មី តាមមាគ៌ានយោបាយរបស់បក្ស។ ត្រូវកំណត់ផែនការការងារក្នុងមហាជនឲ្យច្បាស់ និងការងារផ្ទៃក្នុងបក្សឲ្យច្បាស់ ក្នុងក្របខ័ណ្ឌភូមិភាគ

របស់ខ្លួន។

៣) ជ្រើសរើសតាំងអង្គការដឹកនាំថ្មី ជាគណៈកម្មាធិការភូមិភាគ ឈរលើលក្ខណៈសម្បត្តិ១០ យ៉ាងរបស់បក្ស ហើយត្រូវគណៈកម្មាធិការមជ្ឈិមពិនិត្យ វិនិច្ឆ័យ និងយល់ព្រម ទើបបានការ។

[០៩:២៨:៥៨]

<u>មាត្រា១៩៖ ភារកិច្ចរបស់គណៈកម្មាធិការភូមិភាគ</u>

ភារកិច្ចរបស់គណៈកម្មាធិការភូមិភាគគឺ ១) ចុះជាប់តំបន់ ស្រុក សាខា និងមូលដ្ឋានជាក់ស្ដែងរបស់សាខា ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ក្នុងភូមិភាគ ដើម្បីដឹកនាំអនុវត្តភារកិច្ចក្នុងមហាជន និងផ្ទៃក្នុងឲ្យសកម្ម ក្ដៅជាប់ជាផែនការតាមមាគ៌ានយោបាយការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យរបស់បក្ស និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ២) ក្ដាប់មហាជនក្នុងសហជីពសហករណ៍ និងកងទ័ពបដិវត្តន៍ក្នុងភូមិភាគរបស់ខ្លួនឲ្យជាប់ និងឲ្យណែនជានិច្ចខាងនយោបាយ សតិអារម្មណ៍ ចាត់តាំងដោយអប់រំបំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច តាមភារកិច្ចការប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ៣) ក្ដាប់បក្ស តំនប់ទាំងអស់ បក្សស្រុកទាំងអស់ និងសាខាទាំងអស់ កម្មាភិបាល និងបក្ខជនទាំងអស់ ព្រមទាំងអង្គការស្នូលទាំងអស់នៅក្នុងភូមិភាគខាងប្រវត្តិរូប ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ហើយអប់រំបំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ចតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ៤) កាន់កាប់ទ្រព្យសម្បត្តិរបស់អង្គការភូមិភាគ អនុវត្តវិន័យក្នុងក្របខ័ណ្ឌភូមិភាគ មានរបបរាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគជូនគណៈកម្មាធិការមជ្ឈិម។

[០៩:៣០:៥៦]

មាត្រា២០៖ គណៈកម្មាធិការភូមិភាគត្រូវប្រជុំជាសាមញ្ញ ៣ខែម្ដង ដើម្បីពិនិត្យតាមដានវិនិច្ឆ័យការងារចាស់ និងលើកជាការងារថ្មី។

<u>អំពីគណៈកម្មាធិការមជ្ឈិម</u>

មាត្រា២១៖ គណៈកម្មាធិការមជ្ឈិមត្រូវអញ្ជើញប្រជុំមហាសន្និបាតតំណាងទូទាំងប្រទេសជាសាមញ្ញ ៤ឆ្នាំម្ដង ដើម្បី៖

១) ពិនិត្យតាមដានវិនិច្ឆ័យសកម្មភាពរបស់គណៈកម្មាធិការមជ្ឈិមចាស់ ដោយដកពិសោធន៍ខុសត្រូវសំខាន់ៗឲ្យច្បាស់លាស់ និងជ្រៅជ្រះខាងផ្នែកនយោបាយ ខាងផ្នែកសតិអារម្មណ៍ និងខាងផ្នែកចាត់តាំង និងការងារសំខាន់ៗទាំងអស់។ ២) កំណត់មាគ៌ានយោបាយ និងលក្ខន្តិកៈរបស់បក្ស។ ៣) ជ្រើសរើសគណៈកម្មាធិការថ្មី មជ្ឈិមថ្មី ឈរលើលក្ខណៈសម្បត្តិ ១០យ៉ាងរបស់បក្ស។

មាត្រា២២៖ មហាសន្និបាតអាចធ្វើឡើងមុនពេលកំណត់ ឬពន្យារពេលក៏បានតាមសភាពការណ៍ជាក់ស្តែង។ ចំនួនពេញសិទ្ធិដែលត្រូវអញ្ជើញចូលរួមក្នុងមហាសន្និបាតតំណាងទូទាំងប្រទេស ត្រូវគណៈកម្មាធិការមជ្ឈិមកំណត់។

[០៩:៣២:១១]

<u>មាត្រា២៣៖ ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម</u>

ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិមគឺ ១) អនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទូទាំងមូល -- ក្នុងបក្សទាំងមូល។ ២) ណែនាំអង្គការភូមិភាគ តំបន់ ក្រុងទាំងអស់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំងតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមរបស់បក្ស។ ៣) គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់លាស់ ឲ្យជាប់ជានិច្ច ហើយអប់រំបំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច"។

បាទ នេះសូមចប់សម្រង់ ហើយខ្ញុំមានសម្រង់ចុងក្រោយ។ មានមួយឃ្លានៅក្នុងឯកសារមួយដែលជាៗឯកសារ ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់"។

[០៩:៣៣:៥០]

សូមទោសខ្ញុំអត់មានលេខាឯកសារ ខ្ញុំ -- ដែលមានលេខឯកសារ E4.23។ ហើយខ្ញុំសូមអនុញ្ញាតលោកប្រធានអានមួយឃ្លានេះ ដែលមាន ៗ លេខ ERN ជាភាសាខ្មែរ 00103882, ERN ជាភាសាអង់គ្លេស 00103785, ជាភាសាបារាំង 00595497។ សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំអាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក ពេជ អង្គ៖**

បាទ ខ្ញុំសូមដកស្រង់ឃ្លានៃៗសំណេររបស់លោក ខៀវ សំផន ដូចតទៅ៖ "ប៉ុន្តែបើគេស៊ើបអង្កេតឲ្យបានហ្មត់ចត់បន្តិច គេអាចឃើញយ៉ាងងាយថា គណៈកម្មាធិការមជ្ឈិមបក្សបក្សកុម្មុយនីស្តកម្ពុជាមិនអាចប្រៀបបានទៅនឹងគណៈកម្មាធិការមជ្ឈិបក្សកុម្មុយនីស្តដទៃទៀត ដែលគេធ្លាប់ស្គាល់នៅក្នុងសកលលោកនោះទេ។ ដូចដែលខ្ញុំបានសរសេរក្នុងសំបុត្រចំហរបស់ខ្ញុំចុះថ្ងៃទី១៦ សីហា ឆ្នាំ២០០១ហើយ។ អង្គការនេះ មានន័យថាជាអង្គការមជ្ឈិមបក្ស -- គណៈកម្មាធិការមជ្ឈិមបក្សនេះ មិនមែនជាអង្គការដឹកនាំរបស់បក្សនោះទេ វាគ្រាន់តែជាមជ្ឈមណ្ឌលមួយសម្រាប់អប់រំកម្មាភិបាលខាងមនោគមវិជ្ជានិងខាងនយោបាយតែប៉ុណ្ណោះ ពិសេសសម្រាប់អប់រំលេខា និងគណៈកម្មាធិការបក្ស ដែលទទួលខុសត្រូវគ្រប់គ្រងភូមិភាគ តំបន់ និងកងទ័ព សំដៅឲ្យគេជ្រួតជ្រាបខាង -- ជ្រួតជ្រាបការសម្រេចខាងនយោបាយជាទូទៅរបស់គណៈកម្មាធិការអនិន្ត្រៃយ៍តែប៉ុណ្ណោះ"។ ចប់សម្រង់។

[០៩:៣៦:១៦]

ខ្ញុំបានបញ្ចប់ការបង្ហាញឯកសាររបស់ខ្ញុំហើយ សូមលោកប្រធានអនុញ្ញាតឲ្យសហភាតារបស់ខ្ញុំ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ដើម្បីបន្តការបង្ហាញឯកសាររបស់គាត់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំនឹងបញ្ចប់ការបង្ហាញឯកសារ មានឯកសារជាច្រើនដែលបានបង្ហាញជូនអង្គជំនុំជម្រះរួចហើយ ហើយក៏ដូចជាបង្ហាញជូនសាធារណជន។ ដូច្នេះខ្ញុំនឹងបង្ហាញតែឯកសារបន្តិចបន្តួចទេ គឺមានតែ១១ទេ។

ខ្ញុំនឹងកម្រិតត្រឹមតែរចនាសម្ព័ន្ធមជ្ឈិម ដូចដែលមានចែងនៅក្នុងដីកាដំណោះស្រាយ។ ដើម្បីចាប់ផ្តើមការបង្ហាញឯកសារនេះ ខ្ញុំសូមលើកឡើងនូវសម្តីរបស់ ខៀវ សំផន និង នួន ជា ប៉ុន្មានឆ្នាំក្រោយពីបញ្ចប់របបនេះ គឺឆ្នាំ២០០៦, ២០០៧។ សម្តីនេះត្រូវបានចងក្រងដោយអ្នកសារព័ត៌មាន។ ដូច្នេះខ្ញុំសូមបង្ហាញឯកសារមួយចំនួនពាក់ព័ន្ធទៅនឹងសម្តីរបស់ ខៀវ សំផន និង នួន ជា ដែលបង្ហាញអំពីទស្សនៈ

របស់គាត់អំពីរចនាសម្ព័ន្ធមជ្ឈិមរបស់បក្ស ហើយនិងទស្សនៈរបស់គាត់អំពីតួនាទីរបស់ពួកគាត់នៅក្នុងគណៈកម្មការទាំងអស់នេះ។

[០៩:៣៨:០៥]

ឯកសារដំបូងរបស់ខ្ញុំនេះ គឺឯកសារលេខ E3/122 ទាំងអស់នេះគឺជាកំណត់ត្រាដែលធ្វើឡើងដោយលោក អៀវ ម៉េងទ្រី និង លឿង សូភ័ក្ត នៅពេលដែលពួកគាត់សម្ភាសន៍ ខៀវ សំផន និង នួន ជា នៅថ្ងៃទី០៩, ១០ ខែមិថុនា ឆ្នាំ២០០៦។

លោកខៀវ សំផន ជាដំបូងបានបញ្ជាក់នៅក្នុងឯកសារ E3/122 នៅ ERN ជាភាសាបារាំង 00613201, ERN ជាភាសាខ្មែរ 00347033, ERN ជាភាសាអង់គ្លេស 00000926។ លោក ខៀវ សំផន បានបញ្ជាក់ដូចតទៅនេះ ខ្ញុំសូមដកស្រង់ "អ្នកទាំងអស់គ្នាបានប្រព្រឹត្តកំហុសជាច្រើន។ មិនដែលមាននរណាសុក្រឹត ឥតខ្ចោះនោះទេ។ យើងត្រូវតែរៀនសូត្រពីការខុសឆ្គងរបស់យើង រួចហើយធ្វើការកែប្រែ។ ខ្ញុំក៏បានប្រព្រឹត្តខុសជាច្រើនដែរនៅក្នុងពេលដែលខ្ញុំកាន់អំណាច"។ នៅក្នុងឯកសារដដែលនេះ នៅ ERN ជាភាសាបារាំង 00613204, ERN ជាភាសាខ្មែរ 00347037, ERN ជាភាសាអង់គ្លេស 00000929។ លោក ខៀវ សំផន ឆ្លើយទៅនឹងសំណួរថា "តើអ្នកណាខ្លះជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ គាត់ឆ្លើយថា មានមនុស្សចំនួនប្រាំបីនាក់។

[០៩:៣៩:៥៥]

គណៈកម្មាធិការនេះរួមប្រជុំគ្នាដើម្បីសម្រេចលើបញ្ហាជាក់លាក់ រួចហើយបានជម្រាបជូនសមា -- មជ្ឈិមបក្សដែលមកពីគ្រប់តំបន់ និងភូមិភាគទាំងអស់នៅទូទាំងប្រទេស។ ខ្ញុំជាសមាជិកមួយរូបរបស់គណៈអចិន្ត្រៃយ៍ ក៏ប៉ុន្តែខ្ញុំគ្មានតំបន់សម្រាប់ត្រួតត្រានោះទេ។ ក្នុងគណៈអចិន្ត្រៃយ៍រួមមាន ប៉ុល ពត ជាលេខា នួន ជា អនុលេខា អៀង សារី, សុន សេន, តាម៉ុក, វន វ៉េត, និង សោ ភឹម"។

នៅក្នុងឯកសារដដែលនេះ នៅ ERN--

**ប្រធានអង្គជំនុំ៖**

ផ្អាកសិនលោកស្រី! សូមអញ្ជើញលោកមេធាវី!

**លោក អាកទួរ វ៉ែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជាមេធាវីការពារក្ដីលោក ខៀវ សំផន។ ខ្ញុំចង់បញ្ជាក់ជូននៅទីនេះថា យើងសូមជំទាស់ឯកសារនេះ គឺគ្រាន់តែជាកំណត់ត្រាដែលធ្វើឡើងដោយអ្នកសារព័ត៌មាន

ហើយមិនមានៗខ្សែអាត់នៃការសម្ភាសនោះទេ។ ដូច្នេះ យើងសូមជំទាស់ទៅនឹងការបង្ហាញឯកសារនេះ។ ខ្ញុំចាត់ទុកថាសវនាការការបង្ហាញនូវការអានឯកសារដោយគ្មានការឆ្លើយតបបែបនេះ គឺវាមានលក្ខណៈរឹតត្បិត ដូច្នេះបើធ្វើបែបនេះមិនចាំបាច់ធ្វើសវនាការទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះគឺបានទទួលយកដោយអង្គជំនុំជម្រះហើយ គឺមានលេខ E3/122។ ហើយខ្ញុំសូមបញ្ជាក់ផងដែរថា លោក ខៀវ សំផន ក្នុងឋានៈជាជនជាប់ចោទ គាត់អាចតបទៅនឹងឯកសារនេះ។ ហើយខ្ញុំបានមើលនូវសេចក្តីណែនាំរបស់អង្គជំនុំជម្រះរួចហើយ គឺជនជាប់ចោទមិនអាចតបទៅនឹងឯកសារនោះទេ។ ហើយឯកសារនេះ គឺជាឯកសារ E3 ដែលមានលេខ E3 រួចហើយ ដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ ហើយបន្តទៅទៀត អង្គជំនុំជម្រះនឹងវាយតម្លៃទៅលើតម្លៃជាភស្តុតាងនៃឯកសារមួយនេះ។ សូមអរគុណ។

[០៩:៤២:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៣:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន មិនមានមូលដ្ឋាននោះទេ។ ឯកសារនេះគឺអង្គជំនុំជម្រះបានកំណត់ឯកសារ E3 រួចទៅហើយ ដូច្នេះភាគីមានសិទ្ធិក្នុងការលើកយកមកបង្ហាញជាភស្តុតាង នៅក្នុងកិច្ចដំណើរការនៃការបង្ហាញឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយក្នុងករណីការកំណត់នៃការវាយតម្លៃ ឬក៏ទម្ងន់នៃភស្តុតាង ឬតម្លៃនៃភស្តុតាងនោះ គឺអង្គជំនុំជម្រះនឹងពិនិត្យពិចារណានៅពេលចេញសាលក្រម។ នេះអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ ហើយបានរំឭកបញ្ជាក់កាលពីម្សិលមិញថែមទៀត។ ហើយមួយទៀត អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តីលោក ខៀវ សំផន មិនគប្បីលើកឡើងជំទាស់នៅក្នុងអំឡុងពេលនៃការលើកឡើងនូវការបង្ហាញឯកសាររបស់ភាគីម្ខាងទៀតទេ ហើយករណីនេះគឺលោកមេធាវីការពារក្តី ក៏ដូចជាជនជាប់ចោទ ខៀវ សំផន មានឱកាសនៅក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើសេចក្តីថ្លែងការណ៍តប ដូចអង្គជំនុំជម្រះបានជម្រាបជូនកាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ រួចហើយ ទោះបីលោកមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន បានអះអាងថា លោកនៅស្ងៀមមិនឆ្លើយតបក៏ដោយ ប៉ុន្តែសិទ្ធិ

នេះគឺមានជាដរាបនៅក្នុងការធ្វើការកត់សម្គាល់ ឬក៏ធ្វើការសេចក្តីថ្លែងការណ៍តបទៅនឹងឯកសារភស្តុតាងដែលដាក់ដោយភាគីម្ខាងទៀត។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

[០៩:៤៥:៥០]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមទោសដែលខ្ញុំហាក់ដូចជាវង្វេងវង្វាន់បន្តិច។ ខ្ញុំចង់ឲ្យមានការបញ្ជាក់ទៅលើអ្វីដែលបានសម្រេចអម្បាញ់មិញនេះ គឺថាអង្គជំនុំជម្រះបានបញ្ជាក់ថាមេធាវីការពារក្តីមិនអាចជំទាស់ទៅលើអ្វីដែលបាននិយាយ លុះត្រាតែកូនក្តីរបស់យើងបានដាក់សំណើសុំ ឬមួយក៏កូនក្តីរបស់យើងបានលើកមតិ។ ដូច្នេះ ខ្ញុំស្នើសុំឲ្យលោកប្រធានជួយបញ្ជាក់បន្ថែម ដោយសារខ្ញុំស្តាប់មិនច្បាស់ទៅលើចំណុចនេះ។

[០៩:៤៦:២២]

**ប្រធានអង្គជំនុំ៖**

ឱកាសនៅក្នុងការដាក់ឯកសារ គឺលោកមានសិទ្ធិនៅក្នុងការកត់សម្គាល់ ឬក៏ធ្វើការថ្លែងការណ៍តបទៅនឹងបណ្តាខ្លឹមសារនៃឯកសារដែលភាគីម្ខាងទៀតដាក់។ អង្គជំនុំជម្រះបានរំឭកអំពីសិទ្ធិនេះចំពោះភាគីខាងជនជាប់ចោទរួចហើយកាលព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២។ យើងបានឃើញនូវសំណើសុំរបស់លោកកាលពីម្សិលមិញពាក់ព័ន្ធនឹងបញ្ហានេះ ប៉ុន្តែទំនងជាលោកមិនបានមើល ឬក៏មិនបានស្តាប់នៅក្នុងកិច្ចដំណើរការសវនាការកាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ អំពីការរំឭកអំពីសិទ្ធិរបស់ជនជាប់ចោទនៅក្នុងការកត់សម្គាល់ ឬក៏ធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងបណ្តាឯកសារដែលដាក់ដោយភាគីម្ខាងទៀត។ លោកគួរតែពិនិត្យមើលជាមុននូវប្រតិចារឹកកាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ មុនពេលផ្តល់វេទិកាជូនទៅសហ -- តំណាងសហព្រះរាជអាជ្ញាក្នុងការដាក់ឯកសារ។ ប្រហែលជាមានខ្លឹមសារគ្រប់គ្រាន់នៅក្នុងការ -- សិទ្ធិរំឭកអំពីសិទ្ធិនេះ។

[០៩:៤៧:៤២]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ដូច្នេះប្រហែលជាមានតែខ្ញុំដែលស្តាប់មិនច្បាស់ ប៉ុន្តែឥឡូវខ្ញុំយល់ថាជនជាប់ចោទ នឹងត្រូវទទួលបាននូវឱកាសដើម្បីបញ្ចេញមតិយោបល់ទាក់ទងទៅនឹងឯកសារ ប្រសិន

បើពួកគាត់ចង់បាន។ សំណួរ១ -- បញ្ហារបស់ខ្ញុំគឺខ្ញុំសូមអភ័យទោសដែលខ្ញុំត្រូវយកដៃទប់កអាវខ្ញុំបែបនេះ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយថា តើមេធាវីដទៃទៀត ឬក៏ផ្នែកដទៃទៀតហ្នឹងមិនត្រូវ -- ត្រូវបានជំទាស់មិនឲ្យធ្វើការជំទាស់នៅពេលដែលយើងធ្វើការលើកឡើងដែរឬទេ។ អានេះគឺជាអ្វី ដែលអង្គជំនុំជម្រះចង់បញ្ជាក់ តើបញ្ហានេះមែនដែរឬទេ ថាតើអ្វីដែលខ្ញុំនិយាយហ្នឹង តើវាច្បាស់លាស់ដែរឬទេ អានេះគឺតាមអ្វីដែលខ្ញុំយល់ទៅលើការសម្រេចរបស់ខ្ញុំ។

[០៩:៤៨:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥២:២៦]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា អញ្ជើញក្រោកឈរ!

អង្គជំនុំជម្រះសូមរំឭកបញ្ជាក់បន្ថែមឲ្យបានកាន់តែច្បាស់លាស់ថា មេធាវី -- ភាគីម្ខាងទៀត គឺគិតទាំងមេធាវីការពារក្តីផង គឺមានសិទ្ធិនៅក្នុងការលើកឡើងនូវមតិ កត់សម្គាល់ ឬក៏ជំទាស់ទៅនឹងឯកសារទាំងឡាយ ដែលភាគម្ខាងទៀតបានដាក់បង្ហាញ ចំពោះមុខអង្គជំនុំជម្រះ ប៉ុន្តែមិនគប្បីលើកនៅពេលនេះទេ គឺគប្បីលើកនៅពេលភាគីម្ខាងទៀត បានដាក់បង្ហាញឯកសារចប់ ហើយដល់ពេលវេនលោកដែលមានបំណងធ្វើដូច្នេះ គឺលោកអាចធ្វើបាន។ ហើយទាំងជនជាប់ចោទដូចគ្នា អាចធ្វើបាន។ លើកមុន យើងមានបទពិសោធន៍មួយថា នៅពេលដែលយើងសួរបញ្ជាក់ទៅជនជាប់ចោទ អំពីសិទ្ធិនេះ ប៉ុន្តែមានប្រតិកម្មអំពីខាងមេធាវីការពារក្តី អំពីខ្លួន កូនក្តីរបស់ខ្លួន រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ អ៊ីចឹងហើយ បានជានៅក្នុងកិច្ចដំណើរការនីតិវិធី យើងបានណែនាំថា ក្នុងករណីដែលខ្លួនមានបំណងក្នុងការជំទាស់តវ៉ា គឺនៅពេលចប់ហ្នឹង គឺអាចលើកដៃ ដើម្បីសុំធ្វើការ ធ្វើសេចក្តីថ្លែងការណ៍ ឬក៏កត់សម្គាល់ទៅនឹងការដាក់ឯកសាររបស់ភាគីម្ខាងទៀត។

[០៩:៥៤:១៥]

អ៊ីចឹង គឺទាំងសងខាង យ៉ាងណាមិញ នៅពេលដែលភាគី មេធាវីការពារក្តីដាក់ឯកសារ ក៏ភាគីម្ខាងទៀត គេមានសិទ្ធិធ្វើការកត់សម្គាល់ដូចគ្នាដែរ។ ប៉ុន្តែមិនមែននាពេលនេះទេ គឺនៅពេលដែលចប់បន្តិចទៀត យើងនឹងសួរ ប្រគល់វេទិកាជូនទៅលោកហើយ ហើយលោកអាចធ្វើទាំងពីរ។ ទាំងការបង្ហាញឯកសាររបស់លោក ដែលលោកគិតថា មានប្រយោជន៍នៅក្នុងការពារក្តីកូនក្តីរបស់ខ្លួន ដែល

ច្បាប់អនុញ្ញាត ហើយនិងលោកអាចធ្វើការតបទៅនឹងឯកសារដែលបានដាក់ដោយភាគីម្ខាងទៀតបាន។

[០៩:៥៥:១៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តការបង្ហាញឯកសារមួយចំនួនទៀត។ ខ្ញុំនៅតែនិយាយអំពីឯកសារ E3/122 គឺ ERN 00613205, ជាភាសាបារាំង 00347039 ជាភាសាខ្មែរ, 000929 (សូមទោស) គឺ 30 ជាភាសាបារាំង លោក ខៀវ សំផន និយាយថា “យើងបានប្រព្រឹត្តកំហុសជាច្រើនកាលពីមុន ប៉ុន្តែនៅពេលទន្ទឹមគ្នានេះ យើងក៏បានធ្វើអ្វីល្អៗសម្រាប់ប្រទេសជាតិរបស់យើង ហេតុនេះជាការត្រឹមត្រូវយុតិធម៌ ត្រូវនិយាយទាំងល្អ និងអាក្រក់នៃរបបនេះ។ ចូរឈប់និយាយតែអំពីការកាប់សម្លាប់ដែលជាជ្រុងតែម្ខាងនៃសេនតែប៉ុណ្ណោះ។ ប្រសិនបើលោកចង់ឲ្យប្រទេសទទួលបានឯករាជ្យ និងសេរីភាពនោះ លោកត្រូវតែបូជាអ្វីមួយដើម្បីប្រទេសជាតិរបស់លោក។ ប្រជាជនប្រហែលជាមិនបានទទួលសេរីភាពច្រើនទេ។ មេដឹកនាំទាំងឡាយត្រូវតែអនុវត្តនូវគោលនយោបាយជ្រុលនិយម បើសិនជាយើងមិនធ្វើដូចនោះទេ គឺយើងមុខតែពឹងផ្អែកលើវៀតណាមឲ្យជួយលើគ្រប់ -- សព្វគ្រប់ទាំងអស់”។ សូមបញ្ចប់ការដកស្រង់។

នៅក្នុងឯកសារដដែលនោះ គឺបន្ទាប់មកគឺលោក នួន ជា ដែលត្រូវបានគេសម្ភាស ហើយគាត់បានឆ្លើយនៅ ERN ជាភាសាបារាំង 00613208, ERN ខ្មែរ 00347042 ទៅដល់ 43, ជាភាសាអង់គ្លេស 00000932។ លោក នួន ជា ឆ្លើយថា “ពេលដែលខ្ញុំកាន់អំណាច នយោបាយល្អ មន្ត្រីរបស់យើងគឺមិនល្អទេ យើងមិនមានស្ពានល្អសម្រាប់នាំយកគោលនយោបាយល្អរបស់យើងទៅដល់ប្រជាជន។ អាស្រ័យហេតុនេះហើយ បានជាយើងបរាជ័យមិនអាចទៅដល់គោលដៅរបស់យើង”។ ហើយគេសួរសំណួរគាត់ថា “តើលោកបានដោះស្រាយបែបយ៉ាងណាចំពោះសមមិត្តដែលមិនល្អ?” លោក នួន ជា ឆ្លើយថា “ខ្ញុំបានធ្វើការអប់រំកែប្រែពួកគេ នេះគឺជាការងារដ៏លំបាកណាស់”។ សំណួរ “តើលោកបានធ្វើអ្វីខ្លះទៅឲ្យប្រាកដនោះ?” នួន ជា ឆ្លើយ “ខ្ញុំបានធ្វើការអប់រំកែប្រែពួកគេ ហើយមិនអនុញ្ញាតឲ្យពួកគេស្ថិតនៅក្នុងមុខតំណែងទៀតឡើយ”។

[០៩:៥៧:៥៤]

នៅក្នុងឯកសារនេះ ដដែលគឺ ERN ជាភាសាបារាំង 00613210, ERN ជាភាសាខ្មែរ 00347046, ERN ជាភាសាអង់គ្លេស 00000933។ លោក នួន ជា បានឆ្លើយថា “នៅទីបញ្ចប់ ផែន

ការរបស់ខ្ញុំត្រូវបានបំផ្លាញ ហើយធ្វើឲ្យរបបរបស់ខ្ញុំទន់ខ្សោយ។ នៅចុងបញ្ចប់ខ្ញុំត្រូវបរាជ័យ"។

ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារទី២ ដែលជាប្រតិចារឹកនៃកិច្ចសម្ភាសន៍ជាមួយលោក ខៀវ សំផន របស់វិទ្យុសំឡេងអាមេរិក គឺនៅថ្ងៃទី១៤ កញ្ញា ឆ្នាំ២០០៧ ដែលមានលេខ E3/204។ នៅក្នុងប្រតិចារឹកនៃបទសម្ភាសន៍តាមវិទ្យុនេះ លោក ខៀវ សំផន បានឆ្លើយនៅ ERN ជាភាសាបារាំង 00656178, ERN ជាភាសាខ្មែរ 00424211, ERN ជាភាសាអង់គ្លេស 00680033។ ខ្ញុំសូមអាន "ខៀវ សំផន៖ បាទ អាធ្វើការគឺអ៊ីចេះ ពីមុនមកហូរហែមក ពីឆ្នាំ៧៥មក លោក អៀង សារី ទទួលខាងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ហើយទំនួលខុសត្រូវលើការបរទេសនេះ ក៏ទទួលក្នុងបក្សផង ទទួលរដ្ឋផង ក៏ប៉ុន្តែខ្ញុំវិញ ខ្ញុំធ្វើតែគណៈប្រធានរដ្ឋតែប៉ុណ្ណោះ។ ហើយខ្ញុំធ្វើការនៅក្នុងមន្ទីរមួយដែលគេហៅថា ៨៧០។

[០៩:៥៩:៥០]

ឃើញទេ ក្នុងមន្ទីរ ៨៧០ ហ្នឹង ខ្ញុំមានភារកិច្ចច្បាស់លាស់ណាស់"។ បន្ទាប់មកទៀត គឺនៅទំព័រខាងមុខទៀត គឺ ERN 00656179 ជាភាសាបារាំង, ជាភាសាខ្មែរ 00424212 និងជាភាសាអង់គ្លេស ERN 00680034។ លោក ខៀវ សំផន បានបន្ថែមថា "នេះខ្ញុំសូមជម្រាបខ្លះៗអ៊ីចេះណ៎ា ខ្ញុំបានជម្រាបហើយណ៎ា លោក អៀង សារី ទទួលការងារជា -- ទទួលការជាការងារបរទេស ឯខ្ញុំទទួលខាងដូចខ្ញុំជម្រាបរៀបរាប់អម្បាញ់មិញហ្នឹង គឺប្រមុខរដ្ឋជាផ្លូវរដ្ឋចំហ។ ប៉ុន្តែការងារជាក់ស្តែងប្រចាំថ្ងៃ គឺមន្ទីរ ៨៧០ ហ្នឹង។ ឯមន្ទីរ៨៧០ ខ្ញុំបានជម្រាបហើយ វាមានគោលការណ៍អីយ៉ាងម៉េចៗខ្លះនោះ"។

បន្ទាប់មកទៀត ខ្ញុំសូមចូលទៅឯកសារមួយចំនួនទៀត ដែលពាក់ព័ន្ធទៅនឹងគោលចំហររបស់បញ្ញាជន និងអ្នកការទូតពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធមុនខែមេសា ឆ្នាំ៧៥។ ហើយក្នុងអំឡុងពេលពិនិត្យឯកសារទាំងអស់នេះ ខ្ញុំចង់ពិនិត្យមើលថាតើមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នេះ នៅក្នុងរចនាសម្ព័ន្ធក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥។

[១០:០១:២៥]

ខ្ញុំសូមយោងទៅលើឯកសារ D22/289 ដែលជាពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ដែលជាបងរបស់លោក ថៅ សេង។ ខ្ញុំ ៗមិនអាននូវចម្លើយរបស់ពួកគាត់ទេ។ ហើយខ្ញុំសូមដកឯកសារនេះចេញដោយស្ម័គ្រចិត្តតាមការសម្រេចរបស់អង្គជំនុំជម្រះកាលពីម្សិលមិញ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ! សូមគោរពលោកប្រធាន! លោក លោកស្រីចៅក្រម! សហភាតា សហព្រះរាជអាជ្ញា!

ខ្ញុំសូមវិលមកចំណុចមួយចំនួន ដែលខ្ញុំបានជម្រាបម្សិលមិញ ប៉ុន្តែខ្លីទេ មិនចង់រំខានទេ។ អម្បាញ់មិញលោកប្រធានបានសម្រេចហើយថា ឯកសារដែលមានលេខ E3 នោះ គឺអាចយកមកអានបាន គឺមិនគួរជំទាស់ទេ។ ក៏ប៉ុន្តែឯកសារមួយចំនួនខាងក្រោម របស់បញ្ជីភាគីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននោះ អត់មានលេខ E3 ទេ។ អ៊ីចឹងតាមការកំណត់នេះ យើងមិនអាចយកមកអានបានទេ។

[១០:០៣:០០]

ទី២ ចំណុចទី២ លោកប្រធានទើបនឹងបានកំណត់អំមិញថា មិនអាច -- អាចធ្វើការជំទាស់បាន នៅពេលដែលគេបានអានឯកសាររួចអស់ហើយ។ ក៏ប៉ុន្តែគោលបំណងដែលខ្ញុំបានសុំម្សិលមិញនោះ គឺ សុំមិនឲ្យអានន្ទូវឯកសារមួយចំនួន ដែលខ្ញុំបានរៀបរាប់ក្នុងបញ្ជីរួចហើយ។ ក៏ប៉ុន្តែបើសិនជាឯកសារទាំងអស់ហ្នឹងត្រូវបានអានទៅហើយ ឮទៅហើយ ដឹងទាំងអស់ទៅហើយ តើយើងជំទាស់យ៉ាងម៉េច? គោលបំណងយើងមិនចង់ឲ្យអាន មិនចង់ឲ្យឮ។ តែបើអានហើយ ឮហើយ តើយើងជំទាស់យ៉ាងម៉េច? តើយើងដកសំឡេង ដកការឮហ្នឹងមកវិញបានឬអត់? អ៊ីចឹងខ្ញុំសូមជំទាស់ចំពោះឯកសារមួយចំនួន ជាពិសេសឯកសារដែលមិនទាន់មានចុះ E3 នៅឡើយ។ សូមអរគុណ។

[១០:០៣:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ លើសេចក្តីជំទាស់របស់លោកមេធាវីជាតិ ការពារក្តីលោក អៀង សារី កាលពីម្សិលមិញ។ ដូច្នេះអង្គជំនុំជម្រះមិនយកបញ្ហានេះមកដោះស្រាយជាលើកទី២ទៀតទេ។ មេធាវីអន្តរជាតិមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចបន្តនូវការដាក់ឯកសាររបស់ខ្លួនតាមអ្វីដែលអង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញ។

អញ្ជើញ!

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកបន្តបញ្ហាអ្វីទៀតទេ!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតទេ។ អញ្ជើញលោកស្រីមេធាវីអន្តរជាតិការ -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បន្តការដាក់ឯកសាររបស់ខ្លួនឲ្យបានចប់!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

លោកប្រធាន ហេតុអ្វីក៏មិនអនុញ្ញាត?

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតទេ!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតទេ!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតទេ!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អ្វី បញ្ហានេះយើងបានសម្រេចរួចហើយ អង្គជំនុំជម្រះបានសម្រេចរួចហើយ កាលពីម្សិលមិញ។

[១០:០៥:១១]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន ដូច្នេះខ្ញុំនឹងបន្តទៅទៀត។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថាឯកសារលេខ D22/289 នេះ គឺថាមិនទាន់មានលេខ E3 ទេ។ ខ្ញុំមិនដកស្រង់នូវចម្លើយនៅក្នុងឯកសារនេះទេ។ កាល

ពីម្សិលមិញ ខ្ញុំបានលះបង់សិទ្ធិក្នុង -- (សូមទោស) ខ្ញុំសម្រេចបានដកឯកសារហ្នឹងចេញ ដែលជាប្អូនរបស់លោក ថៅ សេង។ ដូច្នេះ ខ្ញុំសូមដកឯកសារនេះចេញដោយស្ម័គ្រចិត្ត ដូចដែលខ្ញុំបានបញ្ជាក់កាលពីម្សិលមិញ។

ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារមួយទៀត គឺ D22/289.21 ឯកសារនេះគឺជាឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់ប្អូនលោក ថៅ សេង។ ខ្ញុំបង្ហាញឯកសារនេះ គ្រាន់តែចង់បញ្ជាក់ថា ឯកសារនេះគឺជាកិច្ចសម្ភាសន៍លោក ថៅ សេង តាំងនាមឲ្យរណសិរ្សរួបរួមជាតិកម្ពុជា។ កិច្ចសម្ភាសន៍នេះត្រូវបានធ្វើឡើងដោយកាសែតបារាំងដែលមានឈ្មោះថា “លុយម៉ានីតេ” ដែលជាកាសែតកុម្មុយនីស្ត ដែលចុះខែមីនា ឆ្នាំ៧៥។ នៅពេលនោះលោក ថៅ សេង គាត់បាននិយាយក្នុងនាមជាសមាជិកការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា។

ជាបន្ទាប់មកទៀត ខ្ញុំសូមលើកឡើងនូវឯកសារមួយទៀតដែលជាឧបសម្ព័ន្ធរបស់--

[១០:០៦:៤៥]

**ប្រធានអង្គជំនុំ៖**

មានបញ្ហាអីទៅ?

បើកក្បាលមីក្រូហ្វូនផង អត់ស្តាប់បានទេ អត់--

**លោក គង់ សំអុន៖**

ឯកសារដែលមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញនេះ ជាភាសាបារាំង ហើយតើមានជាភាសាខ្មែរទេ? បើសិនជាមានសូមឲ្យបង្ហាញជាភាសាខ្មែរផងបាទ។ សូមអរគុណ។

[១០:០៧:១៩]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី បង្ហាញឲ្យបានច្បាស់លាស់ ឯកសារត្រូវមានយ៉ាងតិចពីរភាសា។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

យើងខ្ញុំបានស្នើសុំបកប្រែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងឧបសម្ព័ន្ធទាំងអស់ហើយតាំងពីយូរមក ប៉ុន្មានខែមកហើយ ក៏ប៉ុន្តែផ្នែកបកប្រែនោះមិនអាចបកប្រែបានទេ ដោយសារតែមិនសូវមានបុគ្គលិកគ្រប់គ្រាន់។ ដូច្នេះឯកសារនេះមានតែជាភាសាបារាំងនោះទេ។ ខ្ញុំមិនដកស្រង់ខ្លឹមសារទេ ខ្ញុំគ្រាន់តែអានចំណងជើងនៃឯកសារនេះ។ ដោយសារថាមិនមានការបកប្រែ ដូច្នេះ ខ្ញុំមិនអានខ្លឹមសារ

នៃឯកសារនោះទេ។ ទោះបីជាយើងខ្ញុំបានដាក់ពាក្យសុំការបកប្រែក៏ដោយ ក៏ប៉ុន្តែការបកប្រែនេះមិនទាន់ធ្វើបានទេ។

[១០:០៨:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:០៨:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីបន្ត!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមចូលទៅឯកសារ D22/289.11។ ERN ជាភាសាបារាំង 00481462 ទៅដល់ 63, ERN ជាភាសាអង់គ្លេស 00806052, ERN ជាភាសាខ្មែរ 00797532 ទៅដល់ 33។ ឯកសារនេះគឺជាសំបុត្រដែលលោក ចៅ សេង ផ្ញើជូនប្រពន្ធរបស់គាត់នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ គាត់ផ្ញើពីទីក្រុងប៉េកាំង។ នៅក្នុងសំបុត្រនោះ គាត់បញ្ជាក់ថា "ប្រពន្ធ -- ភរិយាជាទីស្រលាញ់ បន្ទាប់ពីពេលសម្រាកថ្ងៃត្រង់ហើយ ដោយគិតទៅតាមម៉ោងនៅស្រុកបារាំង ពួកបងបានទៅទទួលបងប្អូនខ្មែរមួយក្រុម ដែលមានគ្នាប្រហែល៤០នាក់ ដែលពួកគេទាំងនោះវិលត្រឡប់ទៅកាន់ទីក្រុងភ្នំពេញដូចពួកបងដែរ។ បន្ទាប់មកគាត់និយាយថា--"

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យលោកមេធាវីអានយឺតៗបន្តិច អ្នកបកប្រែតាមអត់ទាន់លោកប្រធាន។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

*(គ្មានការបកប្រែ)* ហើយជា--

**ប្រធានអង្គជំនុំ៖**

អត់មានការបកប្រែទេលោកស្រីនិយាយញាប់ណាស់។ និយាយយ៉ាងវែងអម្បាញ់មិញនេះ អត់មានការបកប្រែទេ និយាយសាឡើងវិញ!

[១០:១១:០៥]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអានឡើងវិញនៅពាក់កណ្ដាលសំបុត្រនេះ គឺនៅ ERN ដែលខ្ញុំបានបញ្ជាក់

ជូនអម្បាញ់មិញហើយ។ លោក ចៅ សេង បាននិយាយថា "ជាចុងក្រោយក្ដីជឿជាក់នៅតែមានរហូតដល់ដំណាច់ខែ។ ហើយពិតប្រាកដណាស់ មានឯកអគ្គរដ្ឋទូតមួយចំនួនបានចាប់ផ្ដើមបំពេញការងាររបស់ខ្លួនហើយ ហើយអ្វីៗមានលក្ខណៈល្អប្រសើរជាងមុន"។ សូមបញ្ចប់ការដកស្រង់។ និងជាចុងក្រោយ ខ្ញុំសូមអាននូវឃ្លាមួយនៅក្នុងលិខិតនេះ នៅ ERN ដែលខ្ញុំបានបញ្ជាក់រួចហើយ។ "ហើយសុទិដ្ឋិនិយមបដិវត្តន៍នេះបានធ្វើឲ្យអ្វីៗបានល្អប្រសើរ។ យើងត្រូវតែមានសុទិដ្ឋិនិយមបដិវត្តន៍នេះ ព្រមទាំងមានសេចក្ដីសង្ឃឹមនៅក្នុងខ្លួន ពីព្រោះថាអ្វីៗនឹងល្អប្រសើរចំពោះយើងសម្រាប់អ្វីៗគ្រប់យ៉ាង"។

ជាបន្ទាប់មកទៀត ខ្ញុំសូមបង្ហាញឯកសារដែលមានលេខ D22/289.14 ឯកសារនេះគឺជាបញ្ជីមួយផ្នែកនៃអ្នកដែលចេញមកពីបរទេសមកកាន់កម្ពុជាប្រជាធិបតេយ្យនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៦។ នេះគឺជាបញ្ជីមួយផ្នែកដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ខ្ញុំសូមបញ្ជាក់ថាឯកសារនេះមានឈ្មោះ ២៣២នាក់។ ជាបន្ទាប់មកទៀត ខ្ញុំសូមលើកនូវបុគ្គលមួយរូបទៀត។ ខ្ញុំឃើញថា សហភាតារបស់ខ្ញុំងើបឈរ។

[១០:១៣:០៥]

**លោក អាកទួរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំដូចជាមិនឃើញមានថា មានភាពពាក់ព័ន្ធអ្វីសោះទៅនឹង -- ចំពោះនៃឯកសារដែលលើកឡើង ហើយនិង -- ទៅនឹងរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងការងារនៃសវនាការរបស់យើងនេះ។ ដូច្នេះ ខ្ញុំគិតថាសហភាតារបស់ខ្ញុំអាចនពន្យល់អំពីបញ្ហានេះបាន។ ក៏ប៉ុន្តែវាហាក់ដូចងាកចេញអំពីដែនកំណត់នៃសវនាការរបស់យើងហើយ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមឆ្លើយតប ខ្ញុំបានពន្យល់មូលហេតុនៃការបង្ហាញឯកសារនេះរួចហើយ។ វាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធមជ្ឈិម ពាក់ព័ន្ធទៅនឹងមនុស្សដែលធ្វើការនៅក្នុងរចនាសម្ព័ន្ធមជ្ឈិមនៅមុនខែមេសា ឆ្នាំ៧៥។ ហើយខ្ញុំបានលើកឡើងអំពីហេតុការណ៍មុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ អ្នកទាំងអស់នេះបានស្នាក់នៅបឹងត្របែក ហើយមានលើកឡើងនៅក្នុងដីកាដំណោះស្រាយ។ ហើយយើងបានពិនិត្យមើលឃើញហើយថា វាពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធមជ្ឈិមដែលមានចែងនៅក្នុងដីកាដំណោះស្រាយ។

**លោក អាកទួរ វែកគែន៖**

លោកប្រធាន យើងមិនដឹងថា តើអ្នកទាំងអស់ហ្នឹងពិតជាធ្វើការនៅក្នុងរដ្ឋបាលនោះទេ។ ចំពោះ

E1/135.1

ខ្ញុំ ខ្ញុំគិតថាសហភាតារបស់ខ្ញុំនេះកំពុងតែព្យាយាមបង្ហាញនូវឧទាហរណ៍ ដើម្បីបំពេញចិត្តអ្នកណាមួយ ដូច្នេះខ្ញុំមិនដឹងពីគោលបំណងច្បាស់របស់គាត់នោះទេ។ ខ្ញុំមិនឃើញថាមានជាប់ពាក់អីទៅនឹងអត្ថបទដែលអាន ឬក៏ទៅនឹងបញ្ជីអ្នកទោស -- បញ្ជីដែលគាត់បានលើកឡើង វាមានពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធឆ្នាំ៧៥ អ្វីនោះទេ។ ទោះបីជាមានការពន្យល់ពីគាត់ក៏ដោយ ក៏ខ្ញុំដូចថាមិនមានឃើញការពាក់ព័ន្ធអ្វីនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញមេធាវីអន្តរជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បន្តការងាររបស់ខ្លួនតទៅទៀត!

[១០:១៥:២៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

ខ្ញុំសូមចូលទៅនិយាយអំពីបុគ្គលម្នាក់ទៀត ដែលមានឈ្មោះ អ៊ុក កេត ដែលជាអគ្គរដ្ឋទូត មុនឆ្នាំ៧៥ ហើយដែលបានចូលមកកម្ពុជាក្រោយឆ្នាំ៧៥។ ខ្ញុំមិនអានសម្រង់នេះទេ ខ្ញុំគ្រាន់តែលើកឡើងអំពីពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់ប្រពន្ធគាត់ ដែលមានលេខ D22/44។ ខ្ញុំមិនបង្ហាញកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ទេ ពីព្រោះកាលពីម្សិលមិញ ខ្ញុំបានសម្រេចចិត្តដកចេញហើយ ដើម្បីកុំឱ្យមានការតវ៉ា។ ទោះបីជាការជំទាស់នោះ មិនមានមូលដ្ឋានត្រឹមត្រូវក៏ដោយ។

ឥឡូវនេះ ខ្ញុំចូលទៅដល់ឯកសារ D22/44.11 ដែលជាឧបសម្ព័ន្ធ ទៅនឹងពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីដែលជាប្រពន្ធរបស់លោក អ៊ុក កេត។ ឯកសារនេះ គឺERN ជាភាសាបារាំង 00838993, ខ្មែរ 00281227, ភាសាអង់គ្លេស 00326564។ ឯកសារនេះគឺជាលិខិតមួយដែលផ្ញើដោយឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យឈ្មោះ ជាង នៅចិន។ ផ្ញើជូនឯកអគ្គរដ្ឋទូតមួយចំនួន។ នៅឆ្នាំ៧៧ ដែលគាត់បានប្រាប់ថា “ជូនមិត្តទទួលភារកិច្ចនៅស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសសេណេហ្គាល់។ តាមការណែនាំរបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមជម្រាបដូចតទៅ៖ ក្រសួងសម្រេចឱ្យមិត្តត្រឡប់មកក្នុងប្រទេសវិញ សូមត្រៀមរៀបចំដំណើរ ពេលលោកបានទទួលសំបុត្រនេះរួច។ ២) ចំពោះគ្រួសាររបស់មិត្ត សូមរង់ចាំមួយរយៈសិន អាចឱ្យគេស្នាក់នៅជាមួយឪពុកម្តាយគេ។ ៣) អគារស្ថានទូត យើងបានស្នើឱ្យស្ថានទូតចិនជួយរក្សាគ្រប់គ្រងឱ្យហើយ។ សូម

ជម្រាបមិត្ត ថែមទៅស្ថានទូតចិនផង។ ៤) រដ្ឋាភិបាលអញ្ជើញឲ្យចូលក្នុងប្រទេស គឺមកអប់រំរៀនសូត្រ ដើម្បីបំពេញភារកិច្ចជូនរដ្ឋ"។ ជាបន្ទាប់ទៅទៀតនេះ ខ្ញុំសូមលើកឡើងនូវឯកសារមួយ ដែលមានលេខ D22/44.13 ដែលជាឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាប្រពន្ធរបស់លោក អ៊ុក កេត ហើយនេះជាបញ្ជីអ្នកទោសដែលត្រូវបានសម្លាប់ចោលនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៧។ ERN ជាភាសាបារាំង 00339169, ជាភាសាខ្មែរ 00281230, ជាភាសាអង់គ្លេស 00328268។

នៅក្នុងបញ្ជីនេះ គឺនៅលេខរៀងទី៤៣ នេះ គឺលោក អ៊ុក កេត លេខាទី៣ ស្ថានទូត។ ចូលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧។

[១០:១៩:០៣]

ជាចុងក្រោយពាក់ព័ន្ធទៅនឹងប្រធានបទនេះ ខ្ញុំសូមលើកឡើងនូវឯកសារ D22/289.17។ នេះ គឺជាបញ្ជីឈ្មោះខ្មែរមកបរទេសសម្លាប់នៅទួលស្លែង ពីខែមេសា ឆ្នាំ១៩៧៥ ទៅដល់ខែមករា ឆ្នាំ១៩៧៩។ ខ្ញុំសូមបញ្ជាក់ថា ឧបសម្ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាប្អូនរបស់លោក ចៅ សេង នេះ ក៏ជាបញ្ជីមួយដែលមាននៅក្នុងសៀវភៅរបស់លោក អុង ថុងហឿង ដែលបានដាក់ចូលក្នុងសំណុំរឿងរួចមកហើយ កាលពីប៉ុន្មានសប្តាហ៍មុនមកនេះ។ នៅក្នុងនេះ គឺលេខ៨ គឺលោក ចៅ សេង ហើយនិងលេខ៩៥ នោះ គឺមានឈ្មោះលោក អ៊ុក កេត។ ខ្ញុំសូមបង្ហាញឯកសារនេះជាឧទាហរណ៍។ ខ្ញុំនឹងបញ្ចប់ការបង្ហាញឯកសារដ៏លំបាកនេះ ដោយបង្ហាញឯកសារចុងក្រោយមួយទៀត គឺឯកសារលេខ E3/200។

[១០:២០:០០]

ឯកសារដ៏លំបាកនេះ តាម -- ដោយបង្ហាញឯកសារចុងក្រោយមួយទៀត គឺឯកសារលេខ E3/200។ ឯកសារនេះត្រូវបានលើកឡើងរួចមកហើយ ដោយកញ្ញាសហព្រះរាជអាជ្ញាកាលពីម្សិលមិញ ហើយដែលជាប្រតិចារឹកនៃសុន្ទរកថារបស់លោក ខៀវ សំផន នៅក្នុងកិច្ចប្រជុំគម្រប់ខួបនៃការវាយយកទីក្រុងភ្នំពេញដោយខ្មែរក្រហម។ ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារនេះ ដោយលើកឡើងនូវឃ្លាមួយដែលលោក ខៀវ សំផន បានថ្លែងមតិក្នុងឋានៈជាប្រធានគណៈប្រធានរដ្ឋ ហើយគាត់បានលើកឡើងនូវរបាយការណ៍សរុបនៃឆ្នាំ -- ២ឆ្នាំកន្លងផុតទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលគាត់ជាអ្នកតំណាង។ ខ្លឹមសារនេះមានលេខ ERN ជាភាសាបារាំង 00612165, ជាភាសាខ្មែរ 00292804, ជាភាសាអង់គ្លេស S00004164។ លោកខៀវ សំផន បានថ្លែងដូចតទៅ៖

[១០:២១:២១]

"នៅថ្ងៃនេះ បន្ទាប់ពីបណ្តេញពួកចក្រពត្តិនិយមអាមេរិក និងខ្ញុំកញ្ជះរបស់ពួកវាចេញពីប្រទេសយើងអស់ កម្មករ កសិករ និងកងទ័ពបដិវត្តន៍យើង បានក្លាយជាម្ចាស់គ្រប់គ្រងប្រទេស ដោយឥតសង្ស័យ។ ក្នុងអំឡុងពេល២ឆ្នាំកន្លងទៅ ស្ថិតក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់អង្គការបដិវត្តន៍យើង កម្មករ កសិករ និងកងទ័ពបដិវត្តន៍យើង សម្រេចបានសមិទ្ធផលដ៏អស្ចារ្យផ្សេងទៀតជាច្រើន--

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

លោកប្រធាន ខ្ញុំសូមអភ័យទោស ដោយសារខាងភាសាអង់គ្លេស អត់មានការបកប្រែជាភាសាអង់គ្លេសទេ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងអ្នកបកប្រែភាសា! បាទ អត់មានជាភាសាអង់គ្លេស។

[១០:២២:១០]

*(មានបញ្ហាបច្ចេកទេស)*

[១០:២៣:០៦]

សូមអញ្ជើញបន្តលោកស្រីមេធាវី! បាទ សូមឲ្យយឺត យឺតៗ ពីព្រោះអ្នកបកប្រែបកមិនទាន់។ រកឯកសារមិនទាន់។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអភ័យទោសចំពោះការអានលឿនពេកអម្បាញ់មិញនេះ។ ដូច្នេះខ្ញុំព្យាយាមបន្ថយល្បឿន។ ខ្ញុំសូមអានឡើងវិញ ហើយបន្ទាប់មកខ្ញុំនឹងបញ្ចប់។

"ឥឡូវនេះ បន្ទាប់ពីបានបណ្តេញពួកចក្រពត្តិនិយមអាមេរិក និងខ្ញុំកញ្ជះរបស់ពួកវាចេញពីប្រទេសយើងអស់ កម្មករ កសិករ និងកងទ័ពបដិវត្តន៍យើង បានក្លាយជាម្ចាស់គ្រប់គ្រងប្រទេស យើងដោយឥតប្រកែកបាន។ ក្នុងអំឡុងពេល២ឆ្នាំកន្លងទៅ ស្ថិតក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់អង្គការបដិវត្តន៍យើង កម្មករ កសិករ និងកងទ័ពបដិវត្តន៍យើង សម្រេចបានសមិទ្ធផលដ៏អស្ចារ្យផ្សេងទៀតជាច្រើន ជាពិសេសសមិទ្ធផលដែលបញ្ជាក់យ៉ាងច្បាស់អំពីសមត្ថភាពរបស់យើង ទាំងក្នុងវិស័យ

ការពារប្រទេស ទាំងខាងរដ្ឋបាល និងទាំងក្នុងវិស័យស្ថាននីតិសម្បទារជាតិដ៏ទូលំទូលាយ ដោយផ្អែកលើគោលការណ៍ឯករាជ្យ និងម្ចាស់ការ"។ នៅបន្ទាប់មកទៀត លោកខៀវ សំផន និយាយអំពីខ្លាំង ក៏ប៉ុន្តែខ្ញុំនឹងមិនអានឃ្លានេះទេ ពីព្រោះថាកញ្ញាតំណាងសហព្រះរាជអាជ្ញាកាលពីម្សិលមិញ គាត់បានអានឃ្លានេះហើយ។

សូមអរគុណលោកប្រធាន ខ្ញុំសូមបញ្ចប់ការបង្ហាញឯកសារ។

[១០:២៥:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលក៏សមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២៥នាទី ដល់ម៉ោង ១០:៥៤នាទី)*

[១០:៥៤:៣១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ហើយដើម្បីមានឱកាសក្នុងការដាក់បង្ហាញឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

សូមៗ--

[១០:៥៥:១៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥៦:០២]

លោកមេធាវីការពារក្ដីលោក នួន ជា អង្គជំនុំជម្រះសូមជម្រាបជូនលោកថា ឯកសារដែលលោកបានស្នើសុំដាក់ ឯកសារ E190.1.398 អង្គជំនុំជម្រះមិនទាន់សម្រេចថាកោះហៅ ឬមិនកោះហៅអ្នកជំនាញនោះឲ្យមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយទេ។ ដូច្នេះ ឯកសាររបស់អ្នកជំនាញរូបនេះ អង្គជំនុំជម្រះនឹងកំណត់កាលវិភាគសម្រាប់ពិភាក្សាលើបញ្ហានេះនៅពេលក្រោយ។ ហើយស្រដៀងគ្នានេះដែរ គឺឯកសារ E/9 សៀវភៅរបស់ ហ្វីលីព ស្សូត អ្នកជំនាញរូបនេះ អង្គជំនុំជម្រះបានគ្រោង ថានឹងកោះហៅមកផ្ដល់សក្ខីកម្មនៅដើមឆ្នាំក្រោយនេះហើយ។ ដូច្នេះ ឯកសារនេះក៏អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកដាក់បង្ហាញនាពេលនេះដែរ ដោយយើងរង់ចាំរហូតដល់ពេលយើងបានស្ដាប់សក្ខីកម្មអ្នកជំនាញរូបនេះចប់សព្វគ្រប់។ ហើយអង្គជំនុំជម្រះនឹងផ្ដល់ឱកាសភាគីក្នុងការដាក់ឯកសារទាំងអស់នេះដូចករណីទី១ ដែរ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានព្យាយាមដោយទទួលបាននូវការណែនាំ គឺថាព្យាយាមគោរពទៅតាមការណែនាំនេះ ប៉ុន្តែនេះគឺជាលើកទី១ ហើយដែលខ្ញុំបានឮអំពីលក្ខខណ្ឌបែបនេះ ទាក់ទងនឹងការដាក់ឯកសារ។ គេបានជម្រាបយើងថា យើងអាចដាក់ឯកសារណាក៏បានដែលយើងគិតថាវាពាក់ព័ន្ធទៅនឹងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ នៅពេលដែលយើងទទួលបានការជម្រាបនៅម៉ោងដប់មួយ គឺថាមុន ២នាទីមុនខ្ញុំចាប់ផ្ដើមធ្វើបទបង្ហាញនេះ គឺថាខ្ញុំមិនអាចដាក់ឯកសារពីរដែលខ្ញុំបាននិយាយនេះ។ ខ្ញុំគិតថាវាជាការគួរឲ្យចាប់អារម្មណ៍ជាទីបំផុតទៅលើការណែនាំបែបនេះ។

តើទទួលបាននូវការសម្រេចហ្នឹងដោយសារតែផ្អែកទៅលើមូលដ្ឋានអ្វីដែរឬទេ? នេះគឺជាអ្វីដែលខ្ញុំ--

[១០:៥៨:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! យើងបានជម្រាបអំមិញហើយថា យើងបាននិយាយរួចហើយអំពីហេតុផលដែលសម្រេចថា សុំឲ្យលោកបង្អង់ទុកនូវការបង្ហាញឯកសារទាំងពីរនេះសិន ដោយសារមូលហេតុអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ។ យើងមិននិយាយសាឡើងវិញដដែលទេ។ ហើយឱកាសនៅក្នុងការដាក់បង្ហាញឯកសារនេះ អង្គជំនុំជម្រះនឹងផ្ដល់ជូនភាគីនៅពេលក្រោយ។ ពេលសមស្របណាមួយជាពិសេសគឺកាលវិភាគសម្រាប់ការស្ដាប់សក្ខីកម្មអ្នកជំនាញ ដែលអង្គជំនុំជម្រះនឹងសម្រេចផ្ដល់ អ៎!

សម្រេចកោះអញ្ជើញគាត់ឲ្យមកផ្តល់សក្ខីកម្ម ដែលយើងបានកំណត់រួចហើយ។ ករណី ហ្វីលីព ស្បូត ដោយឡែក ស្ទីវិន ហេដឌ័រ គឺយើងមិនទាន់បានសម្រេចឲ្យបានច្បាស់លាស់ថា អញ្ជើញគាត់មកផ្តល់សក្ខីកម្ម ឬអត់នោះទេ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនដល់ភាគី ដើម្បីដាក់នូវឯកសារដែលពាក់ព័ន្ធជាមួយនឹងអ្នកជំនាញ ស្នាដៃអ្នកជំនាញទាំងអស់នេះ នៅពេលសមស្របណាមួយ។

[១០:៥៩:៣៤]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរពីរបីទាក់ទងទៅនឹងចំណុចនេះ។ ទី១ ខ្ញុំចង់បញ្ជាក់នៅក្នុងកំណត់ត្រា ហើយខ្ញុំសូមបង្ហាញនៅក្នុងកំណត់ត្រាថាខ្ញុំមានឯកសារបី ដែលខ្ញុំមានចេតនាដើម្បីលើកយកមកពិភាក្សានៅទីនេះ គឺឯកសារ E190.1.318 -- 198 គឺឯកសារ E3/1 និង E3/9។ ឯកសារទាំងបីនេះ គឺត្រូវបានដាក់នៅក្នុងសំណុំរឿងនៃអង្គជំនុំជម្រះសាលាដំបូង អស់រយៈពេលជាយូរឆ្នាំមកហើយ ហើយនៅពេលនេះ គឺលោកបានបញ្ជាក់ថា វាជាលើកទី១ហើយ ដែលបានខ្ញុំបានឮនៅថ្ងៃនេះ នៅម៉ោងដប់មួយ គឺនៅថ្ងៃទី០៣ នៃការស្តាប់សវនាការដាក់ឯកសារ។ ខ្ញុំគិតថា វាជាការចម្លែកបំផុត ដែលយើងបានចំណាយពេលវេលាជាច្រើនក្នុងការរៀបចំឯកសារ។

[១១:០០:៣៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ លោកមេធាវី។ អង្គជំនុំជម្រះមិនចង់ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិខាងការពារក្តី ដែលចង់បង្ហាញដោយខ្លួន គឺថាពាក់ព័ន្ធនោះទេ។ ក៏ប៉ុន្តែពេលនេះ មិនមែនជាពេលសមស្របនោះទេ។ ចៅក្រមមានសិទ្ធិដឹកនាំសវនាការ ឯកសាររបស់លោកដែលចង់បង្ហាញនេះ គឺថានឹងអាចបង្ហាញបាន ក៏ប៉ុន្តែនៅពេលដែលអ្នកជំនាញនឹងមកទីនេះ យើងនឹងស្តាប់។ ហើយនិងនៅពេលដែលមានធ្វើការសម្រេចចិត្តស្តាប់លោក ស្ទីវ ហេដឌ័រ។ បាទ ឥឡូវនេះ ខ្ញុំគិតថាមិនមែនជាពេលសមស្របនោះទេ ចំពោះលោកក្នុងការធ្វើអត្ថាធិប្បាយ។ អត្ថាធិប្បាយទៅលើសេចក្តីសម្រេច ដែលយើងទើបតែនឹងចេញនេះ។ អ៊ីចឹង សូមព្យាយាមសូមកុំធ្វើយ៉ាងដូច្នេះ។

[១១:០១:៤០]

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកចៅក្រម ឡាវ៉ែន៍។ ដូច្នេះ ខ្ញុំសូមបន្តបន្តិច ដើម្បីឲ្យខ្ញុំបញ្ជាក់ច្បាស់ទៅលើបញ្ហានេះ។ គឺលោកចង់ជម្រាបយើងថា ឯកសារ ហ្វីលីព ស្បត មិនអាចពិភាក្សានៅពេលនេះ តើមែនដែរទេ? គឺថាឯកសារហ្នឹងអាចពិភាក្សាតែនៅពេលដែលលោក ហ្វីលីព ស្បត មកបង្ហាញខ្លួន នៅមុខអង្គជំនុំជម្រះ តើមែនដែរទេ? ហើយឯកសារបន្ទាប់ទៀត គឺឯកសារ -- ហើយឯកសារទី២ របស់ខ្ញុំ គឺជាការសម្ភាសដែលធ្វើឡើងដោយ ប៉ែន យៀរនិន ជាមួយនឹង ជា ស៊ីម ហើយនិង ហេង សំរិន បើតាមខ្ញុំដែលខ្ញុំដឹង គឺថាឯកសារហ្នឹងមិនអាចយកមកពិភាក្សា។ លុះត្រាតែលោក ប៉ែន យៀរនិន មកបង្ហាញខ្លួនផ្តល់សក្ខីកម្ម ឬមួយក៏ខ្ញុំអាចបន្តជាមួយឯកសារ E3/1568។

ដូច្នេះ ចៅក្រម ខាតវ៉ាយថ៍ ខ្ញុំសង្ឃឹមថា ប្រហែលមានការបញ្ជាក់អំពីចំណុចនេះ សូមអរគុណ។

[១១:០២:៥៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

គឺថាមានឯកសារពីរ គឺថាឯកសារទី១ គឺថាសៀវភៅរបស់លោក ហ្វីលីព ស្បត ពីព្រោះថា ហ្វីលីព ស្បត នេះ ជាអ្នកជំនាញ ដែលថាយើងនឹងស្តាប់នៅពេលខាងមុខនេះ គឺស្តាប់ពីសប្តាហ៍ក្រោយនោះ។ អ៊ីចឹង យើងអាចបង្ហាញឯកសារគាត់នេះ នៅពេលដែលគាត់មកផ្តល់សក្ខីកម្ម ឬក៏នៅពេលសវនាការក្រោយទេ ពាក់ព័ន្ធនឹងការបង្ហាញឯកសារ។ ឯកសារមួយទៀត គឺឯកសារដែលសរសេរដោយលោក ស្ទីវិន ហេដឌ័រ ដែលគាត់នេះ ក៏ជាសាក្សីដែរ ហើយយើងមិនធ្វើការសម្រេចចិត្តនោះទេ។ អ៊ីចឹង មានឯកសារពីរហ្នឹង ហើយលោកបានជូនដំណឹងមក -- លោកជូនដំណឹងមកតុលាការ ហើយយើងនឹងមិនជំទាស់អីទេ ឲ្យតែលោកមានហេតុផលសមស្រប។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ចៅក្រម ឡាវ៉ែន៍ ខ្ញុំជិតបញ្ចប់ការសួររបស់ខ្ញុំហើយ។ ខ្ញុំមានចំណុចមួយទៀត។ ខ្ញុំយល់ថា អ្វីដែលលោកចង់ជម្រាបខ្ញុំ គឺថាប្រសិនបើលោក ហេដឌ័រ មិនមកបង្ហាញខ្លួនក្នុងនាមជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនោះទេ ប្រហែលជាមិនមានការពិភាក្សាអំពីឯកសារនេះ។ តើមែនដែរទេ? ខ្ញុំឃើញថា លោកចៅក្រមបានងក់ក្បាល ដូច្នេះបានន័យថា លោកចៅក្រមបានយល់ស្របតាមអ្វីដែលខ្ញុំនិយាយ។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ? ក្នុងនាមជាមេធាវីការពារក្តី នួន ជា អាចនិយាយអំពីអត្ថបទមួយ

នេះ តែក្នុងករណីដែលលោក ស្ទីវ ហេដឌ័រ បានមកបង្ហាញខ្លួននៅមុខអង្គជំនុំជម្រះ។ អ៊ីចឹងប្រសិនបើនេះ ខ្ញុំចង់ឲ្យមានការបញ្ជាក់បន្ថែមទៅលើចំណុចនេះ។

[១១:០៥:៤៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ឯកសាររបស់ ស្ទីវិន ហេដឌ័រ គឺថាជួន -- គឺថាតុលាការកោះហៅគាត់មកៗផ្តល់សក្ខីកម្ម ហើយយើងនឹងពិភាក្សា ហើយនិងបង្ហាញឯកសារ។ ចំពោះតុលាការ បើសិនជាមិនហៅមកទេ គឺថាលោកអាចមានពេលក្រោយទៀត ក្នុងការបង្ហាញឯកសារនុ៎ង បើសិនជាលោកគិតថា ឯកសារហ្នឹងសំខាន់ក្នុងការការពារកូនក្តីរបស់លោកនោះ បាទ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំនិយាយនេះច្បាស់លាស់ហើយ។

**លោក អេនឌ្រូ អ៊ីនួហ្ស៊ី៖**

ឥឡូវនេះ ខ្ញុំយល់ច្បាស់ហើយលោកចៅក្រម។ ដូច្នេះ ក្នុងករណីនេះ ការធ្វើបទបង្ហាញរបស់ខ្ញុំគឺខ្លីមែនទែននៅពេលនេះ។ ខ្ញុំមានឯកសារតែមួយគត់ដើម្បីបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ នៅមុនពេលខ្ញុំចាប់ផ្តើមខ្ញុំសូមធ្វើការលើកមតិជាទូទៅ ទាក់ទងទៅនឹងបញ្ហាមួយចំនួន ដែលខ្ញុំជឿជាក់ថា ដែលយើងបាននិយាយកាលពីពេលមុន។ ខ្ញុំចង់បញ្ជាក់អំពីគោលជំហររបស់យើងក្នុងពេលឥឡូវនេះ គឺយើងចង់បញ្ជាក់ថា ពាក់ព័ន្ធទៅនឹងវិសាលភាពនៃកិច្ចដំណើរការនីតិវិធីនេះ យើងទទួលយកទៅលើកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿង០០២ ដែលពាក់ព័ន្ធទៅនឹងការមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការចោទប្រកាន់អង្គហេតុ ទៅលើការជម្លៀសលើកទី១ និងលើកទី២ នៃប្រជាជន ហើយនិងការបន្ថែមនូវទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ ហើយខ្ញុំយល់ថា ហេតុផលសម្រាប់មូលហេតុទាំងអស់នេះ គឺបង្កើតមូលដ្ឋានដើម្បីការជំនុំជម្រះបន្តទៀតនៅក្នុងសំណុំរឿង០០២។ ហើយខ្ញុំគិតថានៅចំណុចមួយនេះ យើងទទួលយល់ស្របទាំងស្រុងទៅលើអ្វីដែលលោក ខេលី បាននិយាយនៅពេលដែលគាត់បង្ហាញខ្លួននៅក្នុងពេលនៅក្នុងតុលាការនោះ។ ប៉ុន្តែនៅក្នុងចំណុចនេះ គឺជាថ្មីម្តងទៀត គឺខ្ញុំចង់និយាយអំពីការចោទប្រកាន់អំពីរចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងអំឡុងពេលវេលាដែលពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានបង្ហាញ គឺថាចោទប្រកាន់អំពីអង្គហេតុដែលបានបង្ហាញ។ ដូច្នេះហើយ គឺរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា គឺពាក់ព័ន្ធ។

[១១:០៧:១៣]

វាជាការពិតហើយ ប៉ុន្តែរចនាសម្ព័ន្ធដែលពាក់ព័ន្ធនៅក្នុងរយៈពេលប្រហែលជាមុនបន្តិច និង

ក្រោយបន្តិច គឺរយៈពេលអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងអង្គជំនុំ -- នៅក្នុងអង្គជំនុំជម្រះសាលាដំបូងនោះ គឺពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនក៏ដូចជាអ្វីដែលទើបបន្ថែមថ្មី គឺទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃនោះ ខ្ញុំចង់លើកយកមតិមួយចំនួន ដែលមតិផ្តើមដំបូង គឺនិយាយអំពីទំហំនៃឯកសារដែលខ្ញុំត្រូវដាក់ ដែលខ្ញុំគិតថាវាជាការចាំបាច់។ ថាតើខ្ញុំអាចបញ្ជាក់អំពីឯកសារនៅថ្ងៃនេះ ឬក៏អត់? ប្រសិនបើជាមិនអាចទេ ខ្ញុំអាចធ្វើនៅពេលក្រោយបាន។

ពាក់ព័ន្ធទៅនឹងឯកសារតែមួយ ដែលខ្ញុំនឹងបង្ហាញនៅពេលនេះ ខ្ញុំសូមស្នើសុំឲ្យដាក់ចូលនូវឯកសារទាំងមូល មិនមែនជាឯកសារដែលខ្ញុំដកស្រង់តែមួយចំណុច -- តែចំណុចខ្លះប៉ុណ្ណោះនោះទេ។ ឥឡូវនេះ ឯកសារដែលខ្ញុំចង់ដាក់គឺឯកសារ E3/1566568 (ស៊ីក) គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលធ្វើ ឡើងដោយ ប៉ែន យៀរនិន ចំពោះបុគ្គលពីររូបគឺ ជា ស៊ីម និង ហេង សំរិន គឺមានផ្នែកតូចៗមួយចំនួនដែលខ្ញុំចង់អាន ហើយខ្ញុំគិតថា ខ្ញុំនឹងអានឲ្យបានយឺតៗបន្តិច ដោយសារតែខ្ញុំមិនបានផ្តល់ឯកសារនេះ ជាមុន។ ដូច្នេះ ខ្ញុំធ្វើបែបនេះដើម្បីឲ្យជួយសម្រួលដល់អ្នកបកប្រែ ខ្ញុំនឹងដោយយឺត។

ឥឡូវនេះ ខ្ញុំនិយាយអំពី ERN ជាភាសាអង់គ្លេស 00651878 រហូតដល់ 00651880, ភាសាខ្មែរ ERN គឺមានលេខ 00713945 ដល់ 48, ហើយនិង ERN ជាភាសាបារាំងគឺមានលេខ 00743349 ដល់ 51។ ហើយដូច្នេះ ខ្ញុំសូមចាប់ផ្តើម។

[១១:០៩:២៩]

គឺភាសាអង់គ្លេស គឺមានលេខ 00651878 នៅចុងទំព័រ ហើយនេះគឺជាការសម្ភាសជាមួយលោក ហេង សំរិន ហើយនៅពេលនោះគឺបាននិយាយ “នៅពេលនោះ ខ្ញុំបាននៅជាមួយ សុន សេន ហើយ សុន សេន បានធ្វើការជួបប្រជុំជាមួយនឹងការបែងចែកក្រុម។ ខ្ញុំបានចូលរួមសកម្មភាពជាមួយ សុន សេន។ ក្រោយមក បន្ទាប់ពី ៣ខែនៅទីក្រុងភ្នំពេញ នៅទីនេះបន្ទាប់ពីគេរំដោះ គេបានបញ្ជូនខ្ញុំទៅបូព៌ាវិញ។ ក្រោយមកបន្ទាប់ពីខ្ញុំបានត្រឡប់ទៅបូព៌ាវិញ កងពលធំលេខ១ត្រូវបានកម្ទេចទាំងស្រុង”។ ហើយបើកក្នុងរង្វង់ក្រចក ខ្ញុំមិនដឹងថាតើមានន័យបែបណា ដែលបើករង្វង់ក្រចកហ្នឹង (គឺនិយាយថាកូនទាហានត្រូវបានចាប់ខ្លួន)។ “បើសិនជាខ្ញុំនៅក្នុងកងពលធំនោះ ខ្ញុំមិនដឹងថាខ្ញុំនឹងទៅជាយ៉ាងណាទេ។ ហើយមានតែកងពលធំលេខ១នេះទេ ដែល ប៉ុល ពត សរសើរខ្លាំងជាងគេនៅក្នុងការប្រយុទ្ធ”។ គឺយើងនិយាយអំពីកងពលធំ ដែលក្រោមការ -- របស់លោក ហេង សំរិន។ “មានតែកងពលធំនេះទេដែលបានតស៊ូប្រយុទ្ធយ៉ាងខ្លាំង និងរុលទៅមុខយ៉ាងជ្រៅទៅក្នុងតំបន់ផ្លូវជាតិលេខ១ និងតាមដងទន្លេ

មេគង្គ(មិនច្បាស់) រហូតដល់ព្រំដែន និងសកម្មខ្លាំង។ ការរំដោះអ្នកលឿងបាន គឺដោយសារកងពលនេះឯង ហើយកងវរសេនាធំរបស់ខ្ញុំ (គឺរបស់ ហេង សំរិន) បានប្រយុទ្ធរំដោះអ្នកលឿងខាងកើត និងខាងលិច និងតាមផ្លូវទឹក រំដោះបាននៅថ្ងៃ០១ មេសា ឆ្នាំ១៩៧៥ គឺខ្ញុំនេះឯង គឺ ហេង សំរិន ដែលរំដោះបានអ្នកលឿងពីខាងកើត និងខាងលិច។ ក្រោយមក គេបានបញ្ជាឲ្យខ្ញុំបញ្ជូនទាហានទៅវ៉ៃចូលភ្នំពេញ។ ប៉ុន្តែការវ៉ៃចូលភ្នំពេញមិនសូវប្រឹងខ្លាំងទេ។ បើកឃ្លាប [ពាក្យខ្មែរមិនច្បាស់] (ទាហាន លន់នល់) បានប្រមូលផ្តុំគ្នាទទួលយើង ហើយឲ្យទាហានយើងដើរចូលនៅពេលនេះ។ នៅថ្ងៃទី១៧ មេសា វេលាម៉ោងប្រាំបួនព្រឹក ខ្ញុំបានមកដល់វិមានឯករាជ្យ។ ក្រោយការរំដោះ មានការបែងចែកការទទួលខុសត្រូវក្នុងចំណោមកងពលធំបីកងមកពីបូព៌ា។ កងពលធំលេខ១របស់ខ្ញុំ កងពលធំលេខ២ របស់ប្អូនប្រុសខ្ញុំ និងកងពលធំលេខ៣របស់ ឈាវ ដែលបានវ៉ៃចូលដល់ជ្រោយចង្វា ជាមួយទាហានជើងទឹក។ កងពលធំលេខ២ បានវ៉ៃចូលដល់ទល់មុខ បើកដង្កៀប [ពាក្យខ្មែរមិនច្បាស់]។ ហើយកងពលធំលេខ១នេះ ចូលតាមផ្លូវជាតិលេខ១ និងតាមផ្លូវពី ភ្នំពេញ ចូលមកភ្នំពេញ -- និងតាមផ្លូវពីតាខ្មៅចូលមកភ្នំពេញ។ មានការរុលចូលបីមុខព្រួញពីបូព៌ា”។

[១១:១២:២៩]

ឥឡូវនេះឯកសារ 00651880 គឺអ្វីដែលខ្ញុំបានអានរួចទៅហើយ គឺខ្ញុំសូមដកស្រង់ “បន្ទាប់ពីស្នាក់នៅ៣ខែ គឺថាកងពលរបស់ខ្ញុំបានបញ្ជូនទៅព្រៃកឯង គឺថាក្នុងរយៈពេល៣ខែហ្នឹង គឺខ្ញុំបានធ្វើការងារជាច្រើនបន្ទាប់ពីការរំដោះ ដើម្បីទទួលបាននូវការបែងចែកផែនការ ហើយបើកឃ្លាប [គឺពាក្យខ្មែរមិនច្បាស់] ទៅខាងហ្នឹង។ គឺថាមិនមែនតែមួយតំបន់ទេ គឺនៅទូទាំងប្រទេសតែម្តង ហើយបើករង់ក្រចក(គឺផ្លូវការ)។ នៅពេលនោះ គឺតំបន់ទាំងអស់មកពីតំបន់ផ្សេងៗក្នុងប្រទេស គឺទទួលផែនការពីខាងមជ្ឈិម គឺទទួលបានពី ប៉ុល ពត គឺថ្ងៃទី២៣ ឧសភា គឺជាថ្ងៃដែលផែនការរបស់ ប៉ុល ពត ត្រូវបានប្រកាស។ ដូច្នេះយើងត្រូវរៀបចំផែនការ ទាំងនៅក្នុង និងក្រៅប្រទេស។ ហើយនៅពេលនោះ ប៉ុល ពត បានប្រកាសអំពីបញ្ហានេះ។ ដូច្នេះហើយយើងបានសម្រេចយកថ្ងៃ២០ ឧសភា ជាទិវាចងកំហឹង ជាបើកដង្កៀប [មិនច្បាស់]”។

[១១:១៣:៥៣]

ហើយបន្តមួយជួរទៀត គឺខ្ញុំសូមបញ្ចប់ គឺឯកសារ E3/1568, ភាសាអង់គ្លេស គឺមានលេខ ERN 00651884, ខ្មែរគឺមានលេខ 00713955, ភាសាបារាំងគឺមានលេខ 00743356។ ហើយជាថ្មី

ម្តងទៀត ខ្ញុំសូមបញ្ជាក់ថា នេះគឺជាការសម្ភាសដដែលរវាង ប៉ែន ឃៀរនិន ជាមួយនឹងលោក ហេង សំរិន។ ហើយនៅក្នុងដំណាក់កាលនេះ គឺនិយាយអំពីការប្រជុំដែលធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ឧសភា ឆ្នាំ៧៥ គឺគេនិយាយថា៖ មិនមានការសម្លាប់ទាហាន លន់ នល់ ទេ បើក -- ពួកគេបាននិយាយថា [មិនច្បាស់ភាសាខ្មែរ] មិនអនុញ្ញាតឲ្យនៅក្នុងក្របខ័ណ្ឌនោះទេ គឺមិនមែនមានន័យថាកម្ទេចនោះឡើយ។ នួន ជា ប្រើប្រាស់ពាក្យនេះ។ នួន ជា បាននិយាយអំពីកម្ទេច គឺបន្ទាប់មកប្រើប្រាស់ជាភាសាអង់គ្លេស គឺថា “កម្ទេច” បានន័យថា “សម្លាប់” ហើយក៏គេប្រើពាក្យទូទៅ “កម្ចាត់”។

[១១:១៥:០៩]

ខ្ញុំគិតថា ប្រហែលជាមានការបកប្រែជាភាសាខ្មែរទៅជាភាសាអង់គ្លេស។ នួន ជា បាននិយាយអំពីកម្ទេចផ្សារ មិនអនុញ្ញាតឲ្យចាយលុយ។ សម្គាធដ៏ធ្ងន់បំផុត គឺប្រឆាំងទ្រព្យសម្បត្តិ បើមានលុយមានផ្សារ បើមានផ្សារនឹងមានមនុស្សដែលមានលុយ ហើយមនុស្សទាំងនោះនឹងមានទ្រព្យសម្បត្តិ។ ដូច្នេះពួកគេចង់បោសសម្អាតទ្រព្យសម្បត្តិ មិនអនុញ្ញាតឲ្យមានទ្រព្យសម្បត្តិឯកជនទេ។

ខ្ញុំសូមនិយាយថា បរិបទហ្នឹង គឺគេចង់មានន័យ “សម្លាប់” ប៉ុន្តែគេប្រើពាក្យ “កម្ចាត់”។ ខ្ញុំសង្ឃឹមថា ប្រហែលជាអស់លោក លោកស្រីទាំងអស់ ហើយអស់លោក លោកស្រីដែលបានតាមដានការសវនាការ ប្រហែលជាមានការប្រើប្រាស់ទាក់ទងទៅនឹងនិយាមរបស់លោក ប៉ៅ ជាមួយនឹងលោក ដេវីដ ឆេនដ៍ល័រ ទាក់ទងទៅនឹងពាក្យមួយនេះ។ ហើយខ្ញុំគិតថា វាជាបញ្ហាសំខាន់សម្រាប់ការការពារក្តីរបស់យើង។

[១១:១៦:០៥]

ហើយចំណុចចុងក្រោយដែលខ្ញុំចង់ដកស្រង់ គឺថាខ្ញុំមិនមានអ្វីបន្ថែមច្រើនទៀតទេ គឺគ្រាន់តែជាមតិបន្តិចបន្តួចដែលខ្ញុំចង់សង្ខេប គឺខ្ញុំព្យាយាមមិនធ្វើការកំណត់លក្ខណៈនៃអ្វីដែលខ្ញុំចង់និយាយ ប៉ុន្តែខ្ញុំចង់និយាយដោយសង្ខេបថា ខ្ញុំចង់និយាយអំពីការ -- ដែនកំណត់នៃការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត គឺខ្ញុំចង់ឲ្យមានការដកស្រង់ពីឯកសារ ឬក៏សម្ភារៈ។ ខ្ញុំគិតថា ប្រហែលជាអ្វីដែលខ្ញុំនិយាយដូចជាមិនមានន័យអ្វីច្រើនទេ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយ គឺថា ឯកសារពីរដែលខ្ញុំមិនអនុញ្ញាតឲ្យដកស្រង់មកយកពិភាក្សានៅពេលនេះ គឺឯកសារទាំងអស់នោះគឺមានយ៉ាងច្រើន គឺថាតាមអ្នកជំនាញទាំងពីរនោះគឺនឹងមានយ៉ាងច្រើននូវការបញ្ជាក់អំពីការ --អំពីស្វ័យភាពនៅថ្នាក់ក្រោម និងថ្នាក់កណ្តាល។

ខ្ញុំឃើញខាងសហព្រះរាជអាជ្ញាបានងើបឈរហើយ។

[១១:១៧:០៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធាន ខ្ញុំគិតថា ខ្ញុំហាក់ដូចជាស្ទាក់ស្ទើរបន្តិចក្នុងការជំទាស់ទៅលើការបង្ហាញឯកសារនេះ។ ខាងមេធាវីការពារក្តីបានព្យាយាមលើកឡើងនិយាយនូវអ្វីដែលមិន គឺថាគាត់គ្រាន់តែមិនមែនដើម្បីបង្ហាញខ្លឹមសារនៃឯកសារនៅចំពោះមុខអង្គជំនុំជម្រះនោះឡើយ ប៉ុន្តែគាត់ចង់និយាយអំពីការមិនទទួលយក។ ហេតុដូច្នេះហើយ យើងគួរតែមិនមានការលួច -- ការបើកទ្វារពីខាងក្រៅ ខាងក្រោយខ្នងនោះឡើយ។

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

ខ្ញុំគ្រាន់តែៗ ធ្វើតាមអ្វីដែលគេបានធ្វើកាលពីម្សិលមិញ។ ដូច្នេះខ្ញុំគ្រាន់សង្ឃឹមថា ខ្ញុំធ្វើដូចគ្នាទាក់ទងទៅនឹងឯកសារនេះ គឺនៅក្នុងពេលធ្វើសវនាការទៅលើឯកសាររបស់រចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំគិតថា ប្រហែលជាខ្ញុំធ្វើនៅពេលក្រោយ។

[១១:១៨:១៣]

ដូច្នេះទាក់ទងទៅនឹងចំណុចចុងក្រោយរបស់ខ្ញុំ គឺវាពាក់ព័ន្ធទៅនឹងការពិភាក្សាដែលយើងបានលើកឡើង គឺវាសំខាន់បំផុតចំពោះយើង។ ផ្អែកទៅតាមសំណើរបស់កូនក្តីរបស់យើង គឺនិយាយអំពីសំណើសុំស្តាប់លោក ស្ទីវ ហេដឌ័រ ហើយក៏សូមឱ្យមានការរួមបញ្ចូល គឺមានសំណើសូមស្តាប់សក្ខីកម្មរបស់លោក ហេង សំរិន ផងដែរ។ ដូច្នេះហើយ គឺថាយើងមានការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមករវាងអង្គជំនុំជម្រះជាមួយខាងយើង ប៉ុន្តែយើងនៅតែមិនច្បាស់ ថាតើហេតុអ្វីមិនយើងមិនទាន់ទទួលបាននូវហេតុផលឱ្យបានច្បាស់លាស់ ថាហេតុអ្វីបានជាសំណើសុំរបស់យើងត្រូវបានបដិសេធនោះឡើយ យើងមិនទទួលបានសំអាងហេតុណាមួយទៅលើបញ្ហានេះឡើយ។ ខ្ញុំគិតថាប្រហែលជាចំណាយ១០នាទីដើម្បីពន្យល់ ឬមួយក៏យ៉ាងម៉េច?

អ្វីដែលខ្ញុំចង់កត់សម្គាល់ គឺថា លោកប្រធានបានជម្រាបខ្ញុំថា យើងធ្វើការសំណើសុំជាលាយលក្ខណ៍អក្សរ ហើយយើងបានធ្វើសំណើសុំជាលាយលក្ខណ៍អក្សរ ហើយខ្ញុំបានបញ្ជាក់នូវសេចក្តីសម្រេចដើម្បីជាប្រយោជន៍របស់សាធារណជន ខ្ញុំគិតថា អ្វីដែលលោកប្រធានបានមានប្រសាសន៍ គឺថា

ប្រហែលជា មិន -- បញ្ជាក់ថា យើងមិនបានអាននូវសំណុំរឿងនៅក្នុងតុលាការ ឬមួយក៏អ្វី។ ព្រោះថា យើងមានសាក្សីជាច្រើន ដែលយើងចង់ស្តាប់នៅក្នុងអង្គជំនុំជម្រះ ហើយនិងបានធ្វើសំណើជាច្រើនដង ទាំងជាលាយលក្ខណ៍អក្សរផងដែរ--

[១១:១៩:៤០]

**ប្រធានអង្គជំនុំ៖**

វេទិកានេះ ដូចជាអង្គជំនុំជម្រះបានផ្តល់វេទិកាជូនឲ្យលោកធ្វើការបង្ហាញនូវឯកសារភស្តុតាង ដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុ រចនាសម្ព័ន្ធកម្ពុជាប្រជាធិបតេយ្យ។

លោកតែងតែប្រើសិទ្ធិរបស់លោកហួសពីព្រំដែន វិសាលភាពនៃអង្គជំនុំជម្រះបានកំណត់របៀបវារៈសម្រាប់ធ្វើសវនាការនីមួយៗហើយ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ។ អ្វីដែលលោកបានធ្វើសំណើសុំទាំងភាគីដទៃទៀតធ្វើសំណើសុំ អង្គជំនុំជម្រះនឹងពិចារណាសម្រេចនៅក្នុងៗពេលសមស្របខាងមុខ។ នៅក្នុងវិធានផ្ទៃក្នុងមិនបានកំណត់ពេលវេលាថា អង្គជំនុំជម្រះត្រូវសម្រេចបញ្ហាណាមួយក្នុងអំឡុងពេលប៉ុន្មាននោះទេ។ ដូច្នេះ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើបញ្ហាជាបណ្តើរៗ ជាបន្តបន្ទាប់ ដូចអ្វីដែលភាគីបានដាក់ឯកសារកន្លងមក គឺច្រើន រាប់រយ រាប់ពាន់ឯកសារ ដែលយើងបានដោះស្រាយជាហូរហែរួចមកហើយនៅក្នុងកិច្ចដំណើរការ ចាប់ផ្តើមពីចុងឆ្នាំ ២០១១ រហូតដល់ពេលនេះ។ យើងសង្ឃឹមថាលោកនឹងអនុវត្តតាមការណែនាំរបស់អង្គជំនុំជម្រះក្នុងការកំណត់នូវរបៀបវារៈសម្រាប់ធ្វើសវនាការនីមួយៗជាមិនខាន។

[១១:២១:៣៥]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ដូចខ្ញុំបាននិយាយរួចហើយថា ខ្ញុំកំពុងតែធ្វើការទៅលើបញ្ហានេះ ហើយខ្ញុំនឹងដាក់ជាឯកសារជាលាយលក្ខណ៍។ ដើម្បីជាការកត់ត្រា ខ្ញុំមិនយល់ស្របជាមួយនឹងអ្វីដែលបានផ្តល់ឲ្យនៅក្នុងការប្រាស្រ័យទាក់ទងនោះឡើយ។ ខ្ញុំបានជម្រាបអង្គជំនុំជម្រះកាលពីប៉ុន្មានសប្តាហ៍មុនរួចមកហើយអំពីការប្រើប្រាស់ឯកសារនេះ។ ប៉ុន្តែអង្គជំនុំជម្រះមិនបានប្រាប់ទេ ទើបតែថ្ងៃនេះបានមកប្រាប់ខ្ញុំ ថាខ្ញុំមិនអាច -- មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារនេះ។ ជាថ្មីម្តងទៀត ទាក់ទងទៅនឹងការតាមដានទៅលើកំណត់ត្រាប្រតិចារឹក ក៏ដូចជាការប្រើប្រាស់ឯកសារប្រតិចារឹក គឺថាបញ្ហានេះត្រូវបានលើកឡើង--

[១១:២២:១៧]

**ប្រធានអង្គជំនុំ៖**

លោក -- ទំនងជាចប់ហើយ លោកដូចអត់មានឯកសារអីដាក់ទៀតទេ មែនទេ? បើអត់ហើយ យើងមិនអនុញ្ញាតឲ្យលោកលើកអ្វីទៀតទេ។ យើងមិនអនុញ្ញាតឲ្យលោកនិយាយអ្វីទៀតទេ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានចំណុចមួយដែលខ្ញុំចង់លើកឡើង គឺថាដើម--

**ប្រធានអង្គជំនុំ៖**

អត់ឲ្យលោកនិយាយអីទៀតទេ។ លោកដាក់ឯកសារ បើមានឯកសារអញ្ជើញដាក់ឯកសារដែលអង្គជំនុំជម្រះបានកំណត់របៀបវារៈសម្រាប់ធ្វើសវនាការនៅថ្ងៃនេះ គឺដាក់ឯកសារភស្តុតាង។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

យើងមានកូនក្តីនៅក្នុងអង្គជំនុំជម្រះនេះ ដូច្នេះយើងចង់ធានាថាលោក នួន ជា ដែលជាកូនក្តីរបស់យើង អ្វីដែលខ្ញុំចង់និយាយគឺ ចំណុចចុងក្រោយរបស់ខ្ញុំគឺថា ផ្អែកទៅលើអ្វីដែលបានផ្តល់ឲ្យ គឺថាកូនក្តីរបស់យើងមិនទទួលយកនូវការផ្តល់ឲ្យក្នុងការបញ្ចេញមតិ គឺគាត់សូមមិនបញ្ចេញមតិនោះឡើយ។ សូមអរគុណលោកប្រធាន។

[១១:២៣:៤៩]

**ប្រធានអង្គជំនុំ៖**

យើងបានរំឭករួចហើយអំពីសិទ្ធិនៅក្នុងការធ្វើការកត់សម្គាល់ ឬសេចក្តីថ្លែងការណ៍តបទៅនឹងបណ្តាឯកសារដែលដាក់ដោយភាគីរបស់ជនជាប់ចោទទាំងពីររូប គឺគាត់បានឆ្លើយច្បាស់លាស់ហើយថាគាត់មិន រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ លោកមើលប្រតិចារឹកនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២។ ហើយអង្គជំនុំជម្រះបានផ្តល់ឱកាសជានិច្ចនៅក្នុងឱកាសនៃការធ្វើសេចក្តីថ្លែងការណ៍តប ឬការធ្វើការកត់សម្គាល់របស់ជនជាប់ចោទ ចំពោះបណ្តាឯកសារទាំងឡាយ ដែលបានដាក់ដោយភាគីនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយជនជាប់ចោទខ្លួនឯងអាចលើកដៃដើម្បីធ្វើការថ្លែងការណ៍ នូវអ្វីដែលគាត់ចង់និយាយ គ្រាន់តែវិសាលភាពក្របខ័ណ្ឌតបទៅនឹងបណ្តាឯកសារដែលពាក់ព័ន្ធទៅនឹងការ -- មិនឯកសារភស្តុតាងដែលដាក់ដោយភាគី។

[១១:២៥:០៩]

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំមានបញ្ហាថ្មីមួយទៀតលោកប្រធាន គឺថាខ្ញុំទើបតែទទួលបានព័ត៌មានថា អូ.ស៊ី.ភី កាលពីខែតុលា ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារ ស្ទីវ ហេដឆ័រ។ ខ្ញុំបានឆែកនូវប្រតិចារឹក ហើយខ្ញុំបានឃើញថា វាត្រឹមត្រូវដូច្នេះមែន។ ដូច្នេះ ខ្ញុំគិតថា តើវាអាចមានលទ្ធភាពបែបនេះដែរទេ ប្រសិនបើមានករណីបែបនេះមែន។ បានន័យថា អូ.ស៊ី.ភី ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឯកសារដែលធ្វើឡើងដោយលោក ស្ទីវ ហេដឆ័រ។ ខ្ញុំមិននិយាយថា គេពិតជាបាននោះទេ ប៉ុន្តែខ្ញុំនិយាយថាក្នុងករណីដែលគេអាចប្រើប្រាស់មែន គឺខ្ញុំចង់ឲ្យមានការប្រព្រឹត្តិឲ្យស្មើគ្នាចំពោះខ្ញុំក៏ដូចជាខាងផ្នែក អូ.ស៊ី.ភី។ ចំពោះខ្ញុំក៏ដូចជា លោក នួន ជា មិនមានមតិអ្វីបន្ថែមទៀតទេ។ សូមអរគុណ។

[១១:២៦:០១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនយកឧបមាណវិធីទេ ទី១។ ទី២ អង្គជំនុំជម្រះបានសម្រេចរួចហើយ អង្គជំនុំជម្រះកត់សម្គាល់លើបញ្ហានេះថា នឹងផ្ដល់ឱកាសពេលណាមួយឲ្យលោកបង្ហាញឯកសារនេះនៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះមិនបានហាមឃាត់ទេ គ្រាន់តែកាលៈទេសៈនេះមិនទាន់សមស្របនៅក្នុងការដាក់បង្ហាញឯកសារនោះ ដោយសារអ្នកជំនាញទាំងពីររូបនោះ អង្គជំនុំជម្រះនឹងធ្វើការកោះអញ្ជើញគាត់មកផ្ដល់សក្ខីកម្មនៅក្នុងអំឡុងពេលណាមួយនៃដំណើរការសវនាការសំណុំរឿង ០០២/០១ នេះ។

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ប្រហែលជាយើងអាចពិនិត្យមើលទៅលើទំព័រ១៦ នៃប្រតិចារឹក គឺនៅថ្ងៃទី១០ ខែ១០ ប្រហែលជាអាចឃើញនូវចំណុចទាំងអស់នេះ។ សូមអរគុណលោកប្រធាន។

[១១:២៧:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៧:៥៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រី ស៊ីលវៀ ខាតវ៉ាយច៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោកព្រះរាជអាជ្ញា គឺមានការនិយាយយោងទៅលើឯកសារដែលពាក់ព័ន្ធទៅនឹងសាក្សីសក្ខានុពលគឺលោក ស្ទីវ ហេដឌ័រ តើលោកដឹងដែរឬទេថាឯកសារអ្វីដែលគេនិយាយយោងទៅដល់នុ៎ង ប្រសិនបើលោកដឹង តើលោកអាចជម្រាបមកអង្គជំនុំជម្រះបានដែរឬទេ អំពីឯកសារយោងនេះ ដើម្បីអង្គជំនុំជម្រះអាចពិចារណាអំពីបញ្ហានេះ នៅពេលដែលអង្គជំនុំជម្រះឈប់សម្រាកពិសាអាហារថ្ងៃត្រង់។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំចង់និយាយថា គឺថានៅពេលគឺយើងមានកំណត់ប្រតិចារឹកនៅទំព័រទី១៦ ខ្ញុំនឹងពិនិត្យមើលទៅលើប្រតិចារឹកទំព័រទី១៦ នេះ ហើយខ្ញុំនឹងជម្រាបជូនលោក -- អង្គជំនុំជម្រះនៅពេលក្រោយ។

[១១:២៨:៥៥]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកតំណាងព្រះរាជអាជ្ញា។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំមានព័ត៌មានបន្ថែមបន្តិចទៀតគឺឯកសារ E3/--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

បានហើយលោកមេធាវី អ៊ីនូហ្ស៊ី គឺខាងព្រះរាជអាជ្ញាគាត់បានធានាធ្វើទៅហើយ ប៉ុន្តែយើងសូមអរគុណដែលលោកស្ម័គ្រចិត្តជួយបន្ថែមទៅទៀតនេះ។ សូមអរគុណលោកមេធាវី។

**ប្រធានអង្គជំនុំ៖**

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការដាក់បង្ហាញឯកសារភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធជាមួយនឹងអង្គហេតុស្តីពីរចនាសម្ព័ន្ធរដ្ឋបាលកម្ពុជាប្រជាធិបតេយ្យ។ សូមអញ្ជើញ!

[១១:២៩:៤១]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូលជាថ្មី។ ក្រុមមេធាវី

លោក អៀង សារី មិនបានស្នើសុំដាក់ឯកសារអ្វីដើម្បីបង្ហាញទេ។ ក៏ប៉ុន្តែមានការកត់សម្គាល់មួយចំនួនទាក់ទងនឹងសវនាការនៅដំណាក់កាលនេះ។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំធ្វើនាពេលនេះ ឬនៅពេលណាមួយក្នុងរយៈពេលសវនាការនេះ? សូមអរគុណ។

[១១:៣០:០៩]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ! អនុញ្ញាត អនុញ្ញាតឲ្យលោកធ្វើការកត់សម្គាល់តបទៅនឹងបណ្តាឯកសារទាំងឡាយ ដែលភាគីម្ខាងទៀតហ្នឹង បានដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ។ ហើយបើបានបង្ហាញនូវការតប់ជាក់លាក់ចំពោះឯកសារ គឺសូមបង្ហាញលេខឯកសារ ឬក៏លេខ ERN ផង នូវការតបរបស់លោក។ មិនអនុញ្ញាតឲ្យលោកធ្វើការតបជាទូទៅនោះឡើយ។

**លោក អាង ឧត្តម៖**

សូមអរគុណ។ ខ្ញុំមិនធ្វើការតបជាទូទៅទេ ក៏ប៉ុន្តែគ្រាន់តែខ្ញុំធ្វើការកត់សម្គាល់តូចមួយ ថានៅមានបញ្ហាមួយចំនួនដែលអត់ទាន់ច្បាស់លាស់នៅឡើយ។ ហើយដើម្បីឆ្លើយតបនេះ ខ្ញុំរង់ចាំចម្លើយរបស់តំណាងអយ្យការដែលលើកអម្បាញ់មិញសិន តើលោកនឹងអះអាងយ៉ាងម៉េចទាក់ទងនឹងឯកសារអម្បាញ់មិញនេះ? ប្រហែលជាខ្ញុំចាំរហូតដល់ព្រះរាជអាជ្ញា គាត់អះអាងហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ចុះនៅលោកក្រុមមេធាវីការពារក្តីលោក ខៀវ សំផន?

សូមអញ្ជើញ! អង្គជំនុំជម្រះផ្តល់ឱកាសឲ្យក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ផ្តល់ឱកាសក្នុងការដាក់ឯកសារភស្តុតាងចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើមាន។

[១១:៣២:០២]

**លោក អាកទ្វរ វែកកែន៖**

បាទ សូមអរគុណលោកប្រធាន។

តាមពិត ខ្ញុំដាក់ខ្លួនជាមនុស្សដែលនៅចំពោះមុខយើងនេះ ហើយយើងសួរសំណួរខ្លួនឯង ថាតើគេនិយាយអំពីអ្វី? បញ្ហាសម្រាប់មេធាវីការពារក្តីលោក ខៀវ សំផន នោះ គឺថាអស់រយៈពេល២ថ្ងៃមកហើយ គឺថាយើងបានចាកចេញពីដែនកំណត់នៃសវនាការ។ តាមពិតទៅ អ្វីដែលកើតឡើងចំពោះមុខយើងរយៈពេលប៉ុន្មានថ្ងៃនេះ មិនមែនជាការជំនុំជម្រះក្តីទេ គឺជាសន្និសីទកាសែតទៅវិញទេ។ ហេតុនេះ

ហើយបានជាមេធាវីការពារក្តី ខៀវ សំផន បដិសេធមិនចូលរួមនៅក្នុងសវនាការបែបនេះ។ មានការប្រកាសជាមុន ចំពោះសវនាការ២ថ្ងៃនោះ ថាការពិភាក្សាដេញដោលគ្នានោះ នឹងមិននិយាយអំពីការទទួលយកឯកសារ ដែលនឹងបង្ហាញដោយភាគីនោះទេ ហើយក៏មិននិយាយអំពីតម្លៃជាភស្តុតាងនៃឯកសារដែរ។ នេះជាអ្វីដែលគេបានជូនដំណឹងដល់យើង។ ហើយសវនាការពីនេះ ក៏បានប្រព្រឹត្តទៅយ៉ាងបែបនេះ។

[១១:៣៣:១៥]

អម្បាញ់មិញនេះ លោកប្រធានបានបញ្ជាក់ថា ភាគីអាចឆ្លើយតបទៅនឹងឯកសារទាំងនេះ។ សហភាតារបស់ខ្ញុំចង់ឡើងអន្តរាគមន៍ ប៉ុន្តែខ្ញុំមិនទាន់បញ្ចប់ទេលោកប្រធាន។ ខ្ញុំសូមបញ្ចប់ជាមុនសិន។

សូមអរគុណលោកប្រធាន។

លោកប្រធានៗ បានបញ្ជាក់ជូនថា យើងអាចឆ្លើយតបទៅនឹងឯកសារបាន ក៏ប៉ុន្តែបញ្ហានោះគឺថាយើងមិនអាចឆ្លើយតបនៅក្នុងវិនាទីចុងក្រោយបែបនេះ ទៅនឹងឯកសារជាច្រើន ដែលបានបង្ហាញជូនដោយភាគី ក្នុងខណៈដែលយើងនេះ យើងចាត់ទុកថាវាជាគ្រាន់តែជាសន្និសីទសារព័ត៌មាននោះទេ។ ដូច្នេះ កាលពីមុនមក គេប្រាប់យើងថា អត់មានលទ្ធភាពក្នុងការឆ្លើយតបទេ។ ហើយពីមុនមក ក៏គេប្រាប់យើងថា យើងមិននឹងពិភាក្សាអំពីការទទួលយក ឬក៏ពិភាក្សាអំពីតម្លៃជាភស្តុតាងនៃឯកសារនោះដែរ។ ហើយប៉ុន្មាននាទីមុននេះ ទោះបីជាលោកប្រធាន ហាក់ដូចជាកែប្រែនៃវិធាននៃសវនាការនេះក៏ដោយ នេះបើតាមអ្វីដែលយើងយល់នោះ ក៏យើងមិនទាន់ត្រៀមខ្លួន យើងមិនបានត្រៀមលក្ខណៈគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងឯកសារដែលបានបង្ហាញជូនដោយភាគី។ ហើយយើងកត់សម្គាល់ឃើញផងដែរថា ក្នុងរយៈពេល២ថ្ងៃនៃសវនាការនេះ ការឆ្លើយតបរបស់យើងតែមួយគត់នោះ គឺការឆ្លើយតបផ្នែកបច្ចេកទេសតែប៉ុណ្ណោះ។ គឺនៅពេលដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់ពាក្យទូទៅ ដើម្បីពិពណ៌នាឯកសារដែលខ្លួនបានប្រើប្រាស់នោះ។ ហើយក្នុងឯកសារនោះ គេប្រើពាក្យជាក់លាក់បំផុត ហើយគាត់គាត់ប្រើពាក្យលក្ខណៈជាទូទៅ។ នេះជាការឆ្លើយតបរបស់យើងកាលពេលនោះ។

[១១:៣៥:១៥]

ឥឡូវនេះយើងខាងមេធាវី ខៀវ សំផន គឺមិនចង់ចូលរួមថែមបន្តទៅទៀតនៅក្នុងសវនាការបែបនេះទេ វាចាកចេញអំពីកំណត់ហេតុ ពីកំណត់ -- ដែនកំណត់នៃសវនាការនេះហើយ ហើយក្នុងនោះទៀត គឺសិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានគោរពនោះទេ។ ដូច្នេះយើងមិនចង់ចូលរួមនៅក្នុងសវនាការ

បែបនេះតទៅទៀតទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងអង្គសវនាការទាំងមូល។ តាមការពិតពេលនេះ ការអន្តរាគមន៍របស់ខ្ញុំអាចមានការយឺតយ៉ាវ ដោយៗខ្ញុំ--

**ប្រធានអង្គជំនុំ៖**

បើយឺតហើយ មិនបាច់អន្តរាគមន៍ ដូចជាអាចសមស្របទេ!

**លោក ពេជ អង្គ៖**

បាទលោកប្រធាន--

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យទេលោកមេធាវីការពារក្ដីលោក នួន ជា ចប់ហើយណ៎ា។ ឱកាសរបស់លោក សម្រាប់លោក អង្គជំនុំជម្រះបានផ្ដល់ជូនឲ្យចប់ហើយ ហើយនីតិវិធីបានឈានទៅមុខរួចហើយ។

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាតិ យ៉ាងម៉េចទៅ?

[១១:៣៦:២៧]

**លោក ពេជ អង្គ៖**

បាទ ខ្ញុំគ្រាន់តែ--

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ហេតុអ្វីបានជាមិនអាច នេះជាបញ្ហាថ្មី?

**ប្រធានអង្គជំនុំ៖**

បាទ មិនអាចទេ ព្រោះឱកាសហ្នឹងគឺឲ្យរួចហើយ។ ឥឡូវហ្នឹងឈានដល់ដំណើរការទៅមុខហើយ នីតិវិធីទៅមុខហើយ។ ឥឡូវហ្នឹងខាងភាគីទាំងពីរហ្នឹងបានចប់សព្វគ្រប់ហើយ គ្រាន់តែមានបញ្ហាបន្តិចបន្តួច យើងនឹងរង់ចាំការដែលផ្ដល់ព័ត៌មានដោយតំណាងសហព្រះរាជអាជ្ញាប៉ុណ្ណោះ។ ព្រោះបានថា អះអាងថា លោកហ្នឹងបានបញ្ចប់នូវភារកិច្ចរបស់លោកហើយ ក្នុងការបង្ហាញឯកសារ។

តំណាងសហ អំ! លោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

ឥឡូវនេះយើងឲ្យ អនុញ្ញាតឲ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បើសិនជាគាត់ចង់មានមតិយោបល់អ្វី ពីព្រោះអំមិញគាត់ថាយឺតពេលហើយ។ យើងថាបើយឺតពេល មិនបាច់និយាយក៏បានដែរ។

[១១:៣៧:៣៧]

**លោក ពេជ អង្គ៖**

បាទ ទោះជាខ្ញុំបានលើកថា អាចយឺតពេល ក៏ប៉ុន្តែវាសារៈសំខាន់ណាស់សម្រាប់សាធារណជន ដោយសារពេលនេះ ក្របខ័ណ្ឌនៃសវនាការរយៈពេល២ថ្ងៃនេះ គឺមានគោលដៅពីរ ដូចដែលយើងខ្ញុំបានទទួលដំណឹងពីអង្គជំនុំជម្រះ គឺបង្ហាញឯកសារ ហើយដែលជាឯកសារសំខាន់ ហើយដែលជាលក្ខណៈជាឯកសារភស្តុតាង។ ហើយម្យ៉ាងទៀត ជាការជូនដំណឹង ដែលមានលក្ខណៈជាឯកសារខ្លឹមសារ ដែលមានលក្ខណៈខ្លឹមសារសំខាន់ៗជូនទៅដល់សាធារណជន ដែលគ្មានលទ្ធភាពនៅក្នុងការចូលមើលឯកសារនៅក្នុងស្តុកឯកសាររបស់តុលាការ។

អ៊ីចឹងវាមានសារៈសំខាន់ មិនអាចនិយាយថា ជាៗសវនាការដោយគ្មានសារៈសំខាន់ទេ ហើយលោកប្រធានបានមានប្រសាសន៍អម្បាញ់មិញ ដោយឆ្លើយតបទៅនឹងលោកមេធាវី អាង ឧត្តម មេធាវីរបស់លោក អៀង សារី ថាមានការអនុញ្ញាតតែចំពោះការធ្វើការអត្ថាធិប្បាយ ពាក់ព័ន្ធទៅនឹងឯកសារជាក់លាក់ ឬក៏តែប៉ុណ្ណោះ។ អ្វីដែលលោកមេធាវី អាកឡូវ វែកគែន បានលើកគឺជាការធ្វើការអធិប្បាយដែលមានលក្ខណៈទូទៅ ហើយដែលបង្ហាញ -- ដែលនិយាយថាការធ្វើសវនាការនេះជាការអត់ប្រយោជន៍។

[១១:៣៩:០១]

ដូច្នេះការធ្វើអត្ថាធិប្បាយមានលក្ខណៈជាទូទៅ ដោយមិនផ្តោតជាក់លាក់ទៅលើឯកសារជាក់លាក់ នេះគឺជាការមិនសមស្រប ហើយជាការនិយាយដែលមិនសមស្របទៅនឹងគោលដៅនៃសវនាការនេះ។ ដូច្នេះហើយបានជាអម្បាញ់មិញ ខ្ញុំមានចេតនានៅក្នុងការកាត់ផ្តាច់នូវអ្វីដែលលោក អាកឡូវ វែកគែន គាត់ធ្វើការអត្ថាធិប្បាយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! លោកចង់មានបញ្ហាអីទៀតហើយ?

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោស ខ្ញុំចង់លើកឡើងនូវចំណុចមួយដែលថាសហការីរបស់ខ្ញុំគឺលោក វែកគែន បានលើកឡើងនូវបញ្ហាថ្មីមួយ ហើយបញ្ហាថ្មីមួយនេះ គឺថាតើភាគីនានាអាចបញ្ចេញមតិបានដែរឬទេ? គឺថាខ្ញុំគាំទ្រជាមួយនឹងអ្វីដែលលើកឡើងនេះ គឺថានៅពេលព្រឹកមិញ គឺថាមានការធ្វើបែបនេះមែន គឺអត់មានការ ជម្រាបទៅដល់ភាគីនានា។ គឺថាពួកយើងនៅខាងការពារក្តីហ្នឹងអាចធ្វើការជំទាស់ អាចធ្វើមតិយោបល់សំខាន់ៗ អាចឆ្លើយតប អាចធ្វើអ្វីមួយដើម្បីបញ្ជាក់ ដើម្បីជាការឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើង។ អ្វីដែលជម្រាបមកយើងបាន គឺថាឯកសារ គឺការបង្ហាញពីឯកសារ។ ហើយអ្វីដែលខាងមេធាវី ខៀវ សំផន ប្រើប្រាស់ថាសន្និសីទកាសែតហ្នឹង គឺសមរម្យមែនទែន គឺថាដោយសារតែមិនមានការជំទាស់ ដោយមានការពិភាក្សាទៅតាមអ្វីដែលយើងបានជម្រាប។ ដូច្នេះ លោកប្រធានកាលពីព្រឹកនេះ បានជម្រាបខ្ញុំ ខាងមកយើងថា នេះគឺជាការជំនុំជម្រះមួយដែល --នេះដូច្នេះ ខ្ញុំគិតថាអ្វីដែលលោក--

[១១:៤០:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៤៣:២០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះនឹងពិភាក្សាគ្នានូវអ្វីដែលមេធាវីការពារក្តីលោក នួន ជា បានលើកឡើង ហើយនិងធ្វើការឆ្លើយតបបន្ទាប់ពីចូលវិញៗ ពិសាបាយថ្ងៃត្រង់រួចហើយ។ តើសហព្រះរាជអាជ្ញាមានអ្វីទេ?

**លោក ឃីត រេយ៍ន័រ៖**

នៅថ្ងៃ -- លោកស្រីចៅក្រម នៅថ្ងៃទី១០ ខែតុលា សហព្រះរាជអាជ្ញាបានដាក់ជូនទៅតុលាការនូវទង់បដិវត្តជាសង្ខេប។ គឺថាមានការច្បាស់ នេះជាការសង្ខេបជាភាសាអង់គ្លេសដែលសហព្រះរាជអាជ្ញាបានរៀបចំអាចដោយ ស្ទីវិន ហេដឌ័រ ឬក៏ដោយលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន។ នេះគឺជាសេចក្តីយោងឯកសារដែលយោងនេះគឺយោងទៅលើទង់បដិវត្តគឺ E3/724 និង E3/731។ គឺវាយោង

ទៅលើឯកសាររបស់ ស្ទីវិន ហេដឌ័រ ដែលរៀបចំឡើងដោយ ស្ទីវិន ហេដឌ័រ សម្រាប់ធ្វើការ -- យកមកធ្វើការបទបង្ហាញនេះ។

[១១:៤៥:៥២]

មិនមានអ្វីខុសគ្នា មិនមានអ្វីដែលកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយ ស្ទីវ ហេដឌ័រ ក៏ដូចជាឯកសារទង់បដិវត្តនោះទេ។ ដោយសារតែ ខ្ញុំក្រោកឈរទៅហើយ ហើយលោក លោកស្រីចៅក្រមគឺសហព្រះរាជអាជ្ញានឹងមានមតិយោបល់ពាក់ព័ន្ធទៅនឹងការលើកឡើងសង្ខេប ដោយលោកមេធាវី វ៉ែកគែន គឺ នេះមិនមែនជាសន្និសីទកាសែតទេ។ ហើយគាត់បានលើកឡើងនិយាយអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិដែលថាចៅក្រមបរទេសម្នាក់ ហៅ រីឆាត មេ គាត់ជាអតីតប្រធាន កាត់ទោសលោក មីឡូសឺវិកគឺថាសម្រាប់បញ្ហានេះគឺថា គាត់មិនបានប្រើឃ្លាជាភាសាអង់គ្លេសថាជាៗសន្និសីទកាសែតបែបនេះទេ។ សវនាការជំទាស់តវ៉ាលើឯកសារនេះ គឺនៅចំពោះមុខអង្គជំនុំជម្រះបែបនេះដែលលោក លោកស្រីចៅក្រមមិនធ្លាប់បានឃើញ គឺថាមេធាវីការពារក្តីហាក់បីដូចជាថា គាត់ត្រូវតែទទួលខុសត្រូវចំពោះការអនុវត្តឲ្យស្របទៅតាមផ្លូវគតិយុត្តិ។ ប្រហែលជាពេលវេលានេះសមស្របហើយដែលថា មេធាវីការពារក្តីគួរណាស់តែបង្ហាញឲ្យបានច្បាស់លាស់ លើកឡើងភស្តុតាងឲ្យបានច្បាស់លាស់ ហើយត្រៀមលក្ខណៈរបស់ខ្លួនឲ្យបានច្បាស់លាស់។

**លោក អាកទួរ វ៉ែកគែន៖**

បាទ ខ្ញុំនិយាយតែមួយម៉ាត់ទេលោកប្រធាន មិនចង់ឲ្យមានការឈ្លោះប្រកែកគ្នាអីទៀតទេ។ បាទ ខ្ញុំគ្រាន់តែ -- ដោយមិនចង់ឆ្លើយ -- មិនឆ្លើយទៅសហព្រះរាជអាជ្ញាទេ ខ្ញុំគ្រាន់តែចង់បញ្ជាក់ឡើងវិញថា គេនិយាយ -- អង្គជំនុំជម្រះបានជូនដំណឹងមកយើង ឬក៏ ស៊ូហ្សាន ឡេម បានជូនដំណឹងមកឲ្យយើងនោះតាមរយៈអ៊ីម៉ែល ថាសវនាការក្នុងការដាក់ឯកសារនេះមិនទាក់ទង ទាំងការដាក់ឯកសារ និងការពិភាក្សាអំពីតម្លៃភស្តុតាងដែលយើងត្រូវផ្តល់ជូន។ គេប្រាប់យើងថា សវនាការនេះគឺមានបំណងឲ្យសាធារណជនដឹងអំពីឯកសារ។

[១១:៤៧:២៥]

ហើយយើងឃើញស្រាប់ហើយ ឯកសារទាំងអស់នេះសុទ្ធតែមានលេខកូដ E3 ហើយៗលោកប្រធានឃើញស្រាប់ហើយ ហើយសាធារណជននោះ នៅទីនេះ នេះគឺថាគឺមកដើម្បីដឹងអំពីឯកសារដែលប្រើនៅក្នុងតុលាការនេះ។ តែស្រាប់ឥឡូវនេះ អ្វីដែលអង្គជំនុំជម្រះជម្រាបជូននេះ ហើយនិងខាង

ដើមបណ្តឹងរដ្ឋប្បវេណីជម្រាបជូននេះគឺថា ២ថ្ងៃមកហើយនេះ គឺជាការពិភាក្សាអំពីឯកសារ គឺថាពិភាក្សាផ្លូវតុលាការ មន្ត្រីច្បាប់ជាន់ខ្ពស់បានជម្រាបជូនហើយ ហើយប្រាប់ថាមិនមែនជាការពិភាក្សាលើឯកសារនោះទេ នៅពេលដែលយើងមិននិយាយអំពីការកំណត់តម្លៃឯកសារ E3 ឬក៏អំពីតម្លៃជាភស្តុតាងនៃឯកសារ ដែលនឹងអាចប្រើនៅពេលក្រោយ នៅពេលដែលអង្គជំនុំជម្រះធ្វើសេចក្តីសម្រេច។

[១១:៤៨:៣១]

ហើយគឺអ៊ីចឹង ខ្ញុំមិនយល់ថា ហេតុអ្វីក៏តុលាការមិនប្រាប់ភាគីឲ្យច្បាស់លាស់ថា គោលបំណងនៃការពិភាក្សាហ្នឹងជាអ្វី ហើយកុំឲ្យពិភាក្សាទៅអត់ប្រយោជន៍យ៉ាងដូច្នេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក អាង ឧត្តម! ឥឡូវបានស្តាប់នូវមតិយោបល់របស់លោកតំណាងសហព្រះរាជអាជ្ញាហើយ។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន អង្គសវនាការទាំងមូល។ ខ្ញុំដឹងថា សវនាការពីថ្ងៃ១០ រហូតដល់នេះៗមិនមែនជាសវនាការនេះតាមៗការ -- លិខិតឆ្លើយឆ្លងរបស់មន្ត្រីជាន់ខ្ពស់របស់សាលាដំបូងថា មិនមែនជាសវនាការដើម្បីសូមឲ្យទទួលស្គាល់ឯកសារភស្តុតាង ឬសុំឲ្យច្រានចោលឯកសារភស្តុតាងមួយចំនួនណានោះទេ។ វាគ្រាន់តែជាសវនាការស្តាប់នូវការអានឯកសារមួយចំនួន ដែលកន្លងមកអត់បានលើកអស់ក្នុងការសួរដេញដោលសាក្សីកន្លងមក។ នេះតាមការយល់របស់ខ្ញុំ បើខ្ញុំខុសសូមអភ័យទោស។

អម្បាញ់មិញលោកប្រធានបានអះអាងថា ចំពោះឯកសារតាក់តែងរៀបចំឡើងដោយអ្នកជំនាញពីររូបគឺ ស្ទីវិន ហេដឌ័រ ហើយនិង ហ្វីលីព ស្សូត មិនគួរ ហើយមិនទាន់ដល់ពេលសមស្រប នឹងលើកនៅពេលនេះទេ ដោយហេតុថាតុលាការមិនទាន់បានកំណត់ថា តើត្រូវយកអ្នកជំនាញទាំងពីរនេះមកសួរដេញដោល ឬក៏អត់។ នេះមួយ។ អ៊ីចឹង ខ្ញុំឆ្ងល់ថា ចុះហេតុអី កាលពីថ្ងៃទី១០ ក្នុងសវនាការដដែលហ្នឹងតំណាងអយ្យការ ព្រះរាជអាជ្ញាបានលើកយកឯកសារមួយដែលរៀបចំឡើងដោយលោក ស្ទីវ ហេដឌ័រ ទាក់ទងនឹងកិច្ចសម្ភាសន៍ជាមួយលោក អៀង សារី មកអាន ឬមួយអានបានដោយសារអត់មានការជំទាស់ ខ្ញុំអត់ដឹងដែរ រឿងចំណុចនេះ។ វាខុសគ្នាត្រង់ចំណុចហ្នឹង។

[១១:៥០:៥៣]

ចំណុចទី២ ខ្ញុំ -- លោកព្រះរាជអាជ្ញាបរទេសអំមិញ លោកអានថា កាលនុំង និយាយតែពីរឿង

ទង់បដិវត្តទេ តែខ្ញុំសូមនិយាយរួចហើយថា មិនមែននិយាយតែទង់បដិវត្តទេ គឺនិយាយដល់កិច្ចសម្ភាសន៍ដែលគាត់តែងឡើងដោយអ្នកឯកទេសទាំងពីរហ្នឹង។ ហើយសួរទៀតថា អាចសួរមកបាន ដោយហេតុថា ឯកសារទាំងអស់ហ្នឹង មានលេខ E3 រួចទៅហើយ។ អ៊ីចឹង ខ្ញុំសួរទៀតថា ចុះឯកសារដែលសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីខាងបរទេសលើកឡើងមួយចំនួនដែលអត់ទាន់មានលេខ E3 ផងនោះ ហេតុអីអនុញ្ញាតឲ្យមានអាន? វាច្របូកច្របល់ចំណុចអស់នេះ ខ្ញុំអត់យល់ អត់សូវយល់ចំណុចត្រង់ហ្នឹង មិនដឹងជាហេតុអីបានជាអ៊ីចឹង។ វាមាន -- មានច្របូកច្របល់ចំណុចហ្នឹង។ អ៊ីចឹង ខ្ញុំត្រូវការការបំភ្លឺ បើសិនជាការយល់ឃើញរបស់ខ្ញុំខុស សូមជួយកែតម្រូវផង ថាឯកសារដែលយើងយកមកតតាំងនេះ មិនមែនជានីតិវិធី ឬដំណើរការជាសវនាការសុំឲ្យទទួលឯកសារ ឬច្រានចោលឯកសារទេ។ គ្រាន់តែជាការអានឯកសារមួយចំនួន និងហេតុអីបានគេអាចអានឯកសារមួយចំនួននេះបាន? ឯកសារមួយចំនួននោះអានអត់បាន? អាហ្នឹង ខ្ញុំអត់យល់ ហើយសូមការបំភ្លឺផង។ សូមអរគុណ។

[១១:៥២:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ហើយអង្គជំនុំជម្រះបានជម្រាបជូនលោករួចហើយ អំពីហេតុផលនៃឯកសារចំនួនពីរ ដោយលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បានបញ្ជាក់ច្បាស់លាស់ហើយ។ ហើយចំពោះឯកសារ D ដែលជាប្រភេទឯកសារតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺអង្គជំនុំជម្រះបានទទួលយកមកពិភាក្សាដេញដោលច្រើនហើយ។ នោះជាឯកសារដោយឡែកដែលវាពាក់ព័ន្ធជាមួយនឹងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជិត៤.០០០នាក់ឯណោះ ហើយភាគីដែលពាក់ព័ន្ធនឹង គឺជាពិសេសហ្នឹងតំណាង -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង បានលើកយកឯកសារប្រភេទនេះ យកមកដេញដោលហើយ។ យើងមិនមែនកំណត់ទេ កំណត់ជារួមថា E3 អាហ្នឹងជាទូទៅ ដើម្បីយើងសម្រេច ប៉ុន្តែឯកសារមួយចំនួនគឺជាឯកសារឧបសម្ព័ន្ធ ឯកសារដែលភ្ជាប់ហ្នឹងគឺយើងអាចប្រើប្រាស់បាននៅក្នុងករណីមួយចំនួន ជាពិសេសគឺប្រភេទឯកសារ D ដែលពាក់ព័ន្ធជាមួយនឹងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[១១:៥៣:២៨]

ហើយឯកសារអំមិញនេះ គឺយើងមិន អ៎! បាននិយាយច្បាស់ យើងញែកជាពីរ រវាងអ្នកជំនាញមួយគឺអ្នកជំនាញដែលយើងបានកំណត់កាលវិភាគសម្រាប់ធ្វើកំណត់អញ្ជើញគាត់មកធ្វើសវនាការ ហើយ

និងមួយទៀត គឺអង្គជំនុំជម្រះនឹងពិចារណាលើបញ្ហាហ្នឹង ហើយអង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យភាគីក្នុងការដាក់បង្ហាញឯកសារដែលពាក់ព័ន្ធលើបញ្ហានេះ នៅក្នុងពេលវេលាសមស្របណាមួយ។ យើងគ្រាន់តែសម្រួលបញ្ហានេះ ដើម្បីកុំវាមានការច្រឡូកច្របល់ប៉ុណ្ណោះ។ បញ្ហាមួយទៀត ដែលយើងបានលើកឡើង គឺគ្រាន់តែបញ្ជាក់ជូនទៅភាគីដែលស្នើសុំ ពីព្រោះភាគីដែលបានសួរយើង។ យើងគ្រាន់តែប្រាប់ថា ប្រសិនបើមានបំណងធ្វើដូច្នេះហ្នឹង គឺយើងអាចធ្វើបាន។ ហើយមិនឲ្យធ្វើការវិភាគលើបញ្ហាតម្លៃនៃភស្តុតាងអីទេ គ្រាន់តែធ្វើការកត់សម្គាល់ទៅលើការដាក់ឯកសារដូចអម្បាញ់មិញអ៊ីចឹង គឺថាគ្រាន់តែធ្វើកម្រិតប៉ុណ្ណឹងតើ យើងមិនមែនឲ្យទៅវិភាគ វាយតម្លៃទម្ងន់នៃភស្តុតាង ពិចារណាភស្តុតាងដូចនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលឯណា។

សូមអញ្ជើញលោកមេធាវី!

[១១:៥៤:៤៧]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធានសាថ្មី។ ខ្ញុំគ្រាន់តែសុំឡើងបញ្ជាក់ថា ពីបញ្ជីឈ្មោះឯកសារដែលសហព្រះរាជអាជ្ញាប្រើកាលពីថ្ងៃទី១០ ទាក់ទងរឿងកិច្ចសម្ភាសន៍ដែលធ្វើឡើងរបស់លោក ស៊ីវ ហេងឌ័រ នោះប៉ុណ្ណោះ។ គឺឯកសារ E3/89 ហើយហ្នឹងហើយ តែប៉ុណ្ណោះ បាទសូមបញ្ជាក់។ ហើយអំមិញខ្ញុំបានឮលោកប្រធានបានបញ្ជាក់ហើយ ប៉ុន្តែដូចជាមិនច្បាស់ ព្រោះខ្ញុំបានបញ្ជាក់ បាន១លើកឡើងថា នេះជាសវនាការអានឯកសារទាំងឡាយ មិនមែនជាសវនាការសុំឲ្យទទួលឯកសារ ឬច្រានចោលឯកសារទេ។ បើលោកប្រធានមិនជំទាស់ទេ សូមមេត្តាបញ្ជាក់ចំណុចនេះឲ្យច្បាស់ថែមទៀត។ សូមអរគុណ។

[១១:៥៥:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ យើងមិនទាន់ -- មិនបានច្រានចោលឯកសារណាមួយនៅពេលដំណើរការនេះទេ។ អង្គជំនុំជម្រះគ្រាន់តែជម្រាបថា ឲ្យបង្អង់បញ្ហាពាក់ព័ន្ធនឹងឯកសារពីរ ព្រោះទាក់ទិននឹងអ្នកជំនាញដែលអង្គជំនុំជម្រះមានបំណងកំណត់យកកោះហៅអ្នកជំនាញមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះប៉ុណ្ណោះ នៅពេលកាលៈទេសៈសមស្របនៅក្នុងការដែលកំណត់កាលវិភាគសម្រាប់កោះហៅសាក្សី អ៊ំ! អ្នកជំនាញមកផ្តល់សក្ខីកម្មគឺ ហ្វីលីព ស្សូត គឺបានធ្វើរួចហើយ ប៉ុន្តែគាត់មានធុរៈគាត់រវល់មិនអាចមកបាន ក៏មានការលើកទៅ ហើយយើងកំណត់ថានឹងពិចារណានៅលើដើមឆ្នាំ២០១៣ ក្នុងការ

ស្តាប់សក្ខីកម្មរបស់គាត់។ ហើយដោយឡែក រឿងអ្នកជំនាញមួយទៀតនោះគឺ យើងបានជម្រាបជូនហើយថា អង្គជំនុំជម្រះបាននឹងកំពុងតែពិចារណា ថាតើគួរអញ្ជើញគាត់មកផ្តល់សក្ខីកម្ម ឬក៏អត់ បើសិនជាយើងអញ្ជើញមក ឬក៏មិនអញ្ជើញមកនោះ គឺលោក ហ្សង់ម៉ាក ឡាវែន៍ បានឆ្លើយច្បាស់លាស់ហើយ គឺផ្តល់ឱកាសឲ្យភាគី ដែលពាក់ព័ន្ធនឹងរឿងក្តីនេះ គឺផ្តល់ឯកសារនៅពេលដំណាក់កាលណាមួយ នៅពេលណាមួយ នៅពេលខាងមុខ ពីព្រោះកិច្ចដំណើរការសវនាការនេះ ទំនងអាចដំណើរការរហូតដល់ទៅឆ្នាំ២០១៣ឯណោះ។ បានន័យថា រហូតដល់មួយឆ្នាំ២០១៣ ទៀតឯណោះ ដោយសារបញ្ហាវាវែង។

លោកតំណាងសហព្រះរាជអាជ្ញាមានបញ្ហាអីទេ?

បាទ បើមិនមានបញ្ហាអីទេ ឥឡូវដល់ពេល--

[១១:៥៧:០៨]

**លោក ឃីត វេយ៉ន័រ៖**

មិននមានទេលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមបញ្ជាក់មុននឹងខ្ញុំអង្គុយចុះទៅវិញ ខ្ញុំឃើញថាមានការខុសគ្នារវាងអត្ថបទដែលរៀបចំឡើងដោយអ្នកនិពន្ធ និងកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយអ្នកនិពន្ធ។ ចំណុចដែលខ្ញុំចង់លើកនោះគឺថា មិនមានការជូនដំណឹងឲ្យបានច្បាស់លាស់អំពីវង្វង់នៃការជជែកតវ៉ាគ្នានេះ។ វាមានបញ្ហាសំខាន់ៗនៅឡើយ ចំពោះការសម្ភាសដែលធ្វើឡើងដោយអ្នកដែលសម្ភាស ដែលមិនមែនជាអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស។ បើសិនណាជាមានមូលហេតុណាមួយដែលពាក់ព័ន្ធទៅដល់របាយ-ការណ៍របស់អ្នកជំនាញ ដែលមិនត្រូវមានវត្តមាននៅទីនេះ គឺការសម្ភាសនោះគឺថា គាត់មិនមែនជាអ្នកអង្កេតរបស់តុលាការ របស់ ក.ស.ច.ស នោះទេ។ បាទ នេះគឺជាចំណុចដែលខ្ញុំចង់លើកឡើង បើសិនណាជាត្រូវហាមឃាត់មិនឲ្យពិភាក្សាទេ នោះគួរណាស់តែជូនដំណឹងមកខាងយើងខ្ញុំជាមុនឲ្យបានដឹងថាហេតុអ្វីបានត្រូវហាមឃាត់មិនឲ្យខ្ញុំមានការឡើងជំទាស់តវ៉ា ដើម្បីឲ្យខ្ញុំស្វែងរកលក្ខណៈឲ្យបានសមស្រប និងស្វែករកថាតើយើងខ្ញុំត្រូវប្តឹងឧទ្ធរណ៍ ដោយរបៀបណានោះ? សារទុក្ខដោយរបៀបណានោះ?

ហើយខ្ញុំសូមជម្រាបផងដែរថា ដោយសារកូនក្ដីរបស់ខ្ញុំ លោក នួន ជា នេះគឺមានការឈឺខ្នង មិនអាចមានការផ្ដង់អារម្មណ៍បានត្រឹមត្រូវ ដូច្នេះគាត់ស្នើសុំទៅតាមដានស្ដាប់ដំណើរការនីតិវិធីនៅបន្ទប់រង់ចាំនៅខាងក្រោម។ សូមអរគុណ។

[១១:៥៩:១២]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដល់ពេលសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកពិសាថ្ងៃត្រង់ ចាប់ពេលពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយនៅរសៀលនេះអង្គជំនុំជម្រះនឹងកិច្ចដំណើរការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប។

ហើយបានស្ដាប់នូវសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយមានបញ្ហាសុខភាព។ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដែលមានចុះហត្ថលេខា ឬផ្ដិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់របស់ជនជាប់ចោទ នួន ជា។

[១២:០០:២៤]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដាន និងចូលរួមកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនលោក នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះឲ្យទុកលោក នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ

សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទីរសៀលថ្ងៃនេះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៤៤ នាទី)*

[១៣:៤៤:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដូចដែលយើងបានជម្រាបជូនភាគីនិងសាធារណជនរួចហើយកាលពីព្រឹកមិញថា កិច្ចដំណើរការសវនាការនៅរសៀលនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីមួយរូបដែលមានរហស្សនាម TCCP-169។

ហើយមុននឹងកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ចូលមកកាន់បន្ទប់សវនាការ អង្គជំនុំជម្រះប្រកាសនូវសេចក្តីសម្រេចផ្ទាល់មាត់ចំនួនពីរ។ ហើយអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ក្នុងនាមអង្គជំនុំជម្រះ ប្រកាសនូវសេចក្តីសម្រេចចំនួនពីរ។ ទី១ គឺពាក់ព័ន្ធទៅនឹងការបង្ហាញឯកសាររបស់ ស្ទីវ ហេដឌ័រ ហើយនិងទី២ សេចក្តីព្រមានចំពោះមេធាវី អេនឌ្រូ អ៊ីនូហ្ស៊ី ដែលជាមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៤៦:២៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជាបឋមគឺថា ទាក់ទងទៅនឹងការកត់សម្គាល់របស់មេធាវីការពារក្តី ទាក់ទងទៅនឹងការបង្ហាញដោយការិយាល័យសហព្រះរាជអាជ្ញា បង្ហាញអំពីកិច្ចសម្ភាសន៍ជនជាប់ចោទ អៀង សារី ដែលធ្វើដោយលោក ស្ទីវ ហេដឌ័រ។ អង្គជំនុំជម្រះបន្ទាប់ពីបានធ្វើការផ្ទៀងផ្ទាត់កត់សម្គាល់ថា ឯកសារ E3/89 នេះត្រូវបានប្រើដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសវនាការថ្ងៃទី១០ តុលា កន្លងទៅនេះ។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះមិនចង់កែប្រែសេចក្តីសម្រេចរបស់ខ្លួនក្នុងការលើកការបង្ហាញរបស់ក្រុមមេធាវីលោក នួន ជា នូវឯកសារដែលសរសេរដោយលោក

ស្ទីវ ហេដឌ័រ នេះទេគឺថា រហូតដល់ពេលដែលអង្គជំនុំជម្រះ សម្រេចថាត្រូវកោះលោក ស្ទីវ ហេដឌ័រ នេះមកធ្វើជាសាក្សីនៅសវនាការ។

អង្គជំនុំជម្រះចង់បញ្ជាក់ថា ការធ្វើដូចនេះគឺជា ដើម្បីប្រយោជន៍យុត្តិធម៌ ហើយនិងដើម្បីជៀសវាងការធ្វើច្រំដែលៗនៅក្នុងសវនាការ ហើយវាក៏មិនមែនជាការរំលោភ ឬក៏ការប៉ះពាល់ដល់សិទ្ធិរបស់ខាងការពារក្ដី ហើយនិងក៏មិនបានហាមឃាត់មិនឲ្យគាត់ប្រើឯកសារនេះ។ ហើយសេចក្ដីសម្រេចនេះគឺថាគ្រាន់តែសូមលើកពេលទៅថ្ងៃក្រោយ គឺថានៅពេលណាដែលសមស្របក្នុងការបង្ហាញឯកសារនេះតែប៉ុណ្ណោះ។

[១៣:៤៨:១២]

បាទ ទាក់ទងនឹងការសម្រេចលើកលោកមេធាវី អ៊ីន្ទូហ្វី សូមលោកមេធាវីក្រោកឈរ!

កាលពីសវនាការកាលពីព្រឹកមិញនោះ មេធាវី អ៊ីន្ទូហ្វី ដែលជាមេធាវីអន្តរជាតិរបស់ក្រុមការពារក្ដីលោក នួន ជា បាន -- ជាថ្មីម្ដងទៀតធ្វើការអត្ថាធិប្បាយសំដៅបដិសេធ និងទិតៀនដល់សេចក្ដីសម្រេចដែលអង្គជំនុំជម្រះបានចេញរួចហើយក្នុងនាមតុលាការទាំងមូល ទាក់ទងនឹងការដឹកនាំសវនាការ។ ហើយការធ្វើអត្ថាធិប្បាយនេះនោះ គឺថាបានធ្វើឡើងនៅក្នុងខណៈដែលគាត់ហ្នឹងត្រូវបាន គាត់ត្រូវបានព្រមានជាច្រើនដងហើយថា អាកប្បកិរិយាបែបនេះមិនស្រួបទេ ហើយមិនត្រូវបន្តធ្វើទៀតទេ។ លើសពីនេះទៅទៀត ការធ្វើអត្ថាធិប្បាយនេះ គាត់ធ្វើអត្ថាធិប្បាយនៅពេលដែលគាត់និយាយទៅកាន់លោកប្រធាន ថាលោកប្រធាននេះជាចៅក្រមដ៏គួរឲ្យកត់សម្គាល់។ ហើយរបៀបដែលនិយាយពាក្យពេចន៍ទាំងអស់នេះ ហើយនិងសូរសៀងនិយាយទាំងអស់នេះ គឺថាវាបង្ហាញថាមានលក្ខណៈមិនត្រឹមតែមិនគួរសម ឬមិនគោរពទេ វាថែមទាំងជាការជេរប្រមាថដល់ចៅក្រមប្រធាន ហើយនិងអង្គចៅក្រមទាំងមូលទៀតផង។

អាស្រ័យហេតុដូច្នេះ អាកប្បកិរិយាទាំងអស់នេះ មិនសមស្រប ហើយនិងមិនអាចទទួលយកបានអង្គជំនុំជម្រះ សូមព្រមានដល់លោកមេធាវី អ៊ីន្ទូហ្វី ថា ដោយយោងទៅតាមវិធាន៣៨ នៃវិធានផ្ទៃក្នុងថាវា គឺជាការមិន -- អាកប្បកិរិយាមិនល្អ មិនសមរម្យ ហើយនិងអាចបង្កើតឲ្យមានការដាក់ទណ្ឌកម្មមួយទៅលើគាត់រហូតដល់ការដែលមិនអនុញ្ញាតឲ្យគាត់ចូលរួមក្នុងសវនាការទៀតផង។

**ប្រធានអង្គជំនុំ៖**

ជាបន្ទមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី TCCP-169 ចូលមកកាន់កន្លែង

ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១៣:៥១:៤៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី តើលោកស្រីឈ្មោះអ្វី?

**លោកស្រី យឹម សុវណ្ណ៖**

**ឆ៖** ចាស ជម្រាបសួរលោកប្រធាន នាងខ្ញុំឈ្មោះ យឹម សុវណ្ណ។

**ស៖** បាទ អរគុណ តើលោកស្រីអាចប្រាប់ដល់អង្គសវនាការបានដែរទេ ថាតើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ចាស នាងខ្ញុំកើតនៅថ្ងៃទី០៥ ឆ្នាំ១៩៦០ ខែ១០។

**ស៖** បាទ អរគុណ ហើយលោកស្រីមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ចាស នាងខ្ញុំមានទីកំណើតនៅភូមិព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល។

**ស៖** បាទ អរគុណ ហើយចុះសព្វថ្ងៃនេះទីលំនៅរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ចាស សព្វថ្ងៃនាងខ្ញុំមានទីលំនៅបច្ចុប្បន្ន នៅទីក្រុងភ្នំពេញ សង្កាត់ -- ភូមិទី៤ សង្កាត់ផ្សារកណ្តាលទី១ ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ ហើយលោកស្រីប្រកបមុខរបរ រកស៊ីធ្វើអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ចាស នាងខ្ញុំសព្វថ្ងៃនេះសម្រាកនៅផ្ទះ។

**ស៖** តើឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះអ្វី?

**ឆ៖** ចាស ឪពុកបង្កើតរបស់នាងខ្ញុំឈ្មោះ តូច ស៊ុំ។ ម្តាយរបស់នាងខ្ញុំឈ្មោះ ទូច លី។

**ស៖** បាទ អរគុណ។ ចុះស្វាមីរបស់លោកស្រី គាត់ឈ្មោះអ្វីដែរ? ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស ស្វាមីរបស់នាងខ្ញុំឈ្មោះ គឹម លាង។ នាងខ្ញុំមានកូនចំនួនបីនាក់។

**ស៖** បាទ អរគុណ ហើយចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ៧៩ នោះ តើលោកស្រីរស់នៅទីកន្លែងណា? ហើយប្រកបមុខរបរធ្វើអ្វី?

**ឆ៖** ចាស នាងខ្ញុំចាប់ពីឆ្នាំ១៩៧៥ រហូតដល់ ៧៩ គឺនាងខ្ញុំ ប្រជាជន កសិករ នាងខ្ញុំ១៧ មេសា រស់នៅទីក្រុងភ្នំពេញ។

[១៣:៥៤:៤៥]

**ស៖** ចុះចាប់ពីថ្ងៃក្រោយថ្ងៃ១៧ មេសា ឆ្នាំ៧៥ រហូតដល់ថ្ងៃរំដោះ ០៧ មករា ឆ្នាំ៧៩ តើលោកស្រីរស់នៅទីកន្លែងណា? ធ្វើអី?

**ឆ៖** ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ថ្ងៃ៧ មករា នាងខ្ញុំចាប់មុនដំបូង នាងខ្ញុំចេញពីទីក្រុងទៅរស់នៅវត្តឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្ដាល។ នាងខ្ញុំចេញពីឃុំពោធិបាន ទៅនៅសហករណ៍ក្បាលឈើពុក ស្រុកណ្ដៀង ខេត្តពោធិ៍សាត់។ ដល់ឆ្នាំ១៩៧៩ នាងខ្ញុំរស់នៅទីក្រុងភ្នំពេញ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រីអាចថ្លែងរៀបរាប់ដល់អង្គសវនាការ អំពីស្ថានភាពទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលលោកស្រី -- ដែលកើតមានចំពោះលោកស្រី ជាអាទិ៍ ខូចខាតខាងផ្លូវចិត្ត ខាងផ្លូវកាយ ឬក៏សម្ភារៈ ហើយព្យសនកម្មនោះ គឺជាព្យសនកម្មផ្ទាល់ខ្លួន ដែលជាបច្ច័យដោយផ្ទាល់ពីបទល្មើស ដែលបានកើតពិតប្រាកដរហូតដល់សព្វថ្ងៃនេះ នាំឲ្យលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយសិទ្ធិនេះគឺលោកស្រីប្រើប្រាស់នៅពេលចុងក្រោយនៃការផ្តល់សក្ខីកម្មរបស់លោកស្រី។ ហើយបញ្ហាទាំងអស់នោះ គឺពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ទៅលើជនជាប់ចោទទាំងបីរូប គឺ នួន ជា, អៀង សារី, ខៀវ សំផន ហើយដែលប៉ះពាល់ចំពោះលោកស្រីនៅក្នុងអំឡុងពេល នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគ្រាន់តែជាប្រាប់ទេ ដើម្បីរំឭកជាមុនដល់លោកស្រីនូវសិទ្ធិនេះ។

[១៣:៥៦:៥៤]

ហើយលោកតំណាងសហព្រះរាជអាជ្ញា អនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះ ផ្តល់ភារកិច្ចក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទៅតំណាងសហព្រះរាជអាជ្ញាមុនភាគីដទៃទៀត ពីព្រោះតំណាងសហព្រះរាជអាជ្ញាមាន ជាភាគីជាអ្នកស្នើសុំ។ ហើយទាំងតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលតែកន្លះថ្ងៃទេ។

សូមអញ្ជើញលោកមេធាវីមានបញ្ហាអីទៅ?

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ ខ្ញុំមានមតិបន្តិចបន្តួចទាក់ទងទៅនឹងអ្វីដែលទើបតែបានលើកឡើង គឺថាសូមកុំគិតថា ជាការរិះគន់ឲ្យសោះ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ។ នីតិវិធីបានប្រព្រឹត្តទៅក្នុងការសួរ យើងបានផ្ដល់ឱកាសទៅតំណាងសហព្រះរាជអាជ្ញា ក្នុងការសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

យើងមិនអនុញ្ញាតឲ្យលោកនិយាយអ្វីទេ! នាពេលនេះ គឺនីតិវិធីស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំមិនមែនចង់សួរសំណួរអ្វីនោះទេលោកប្រធាន ខ្ញុំគ្រាន់តែចង់លើកមតិយោបល់ទាក់ទងទៅនឹងអ្វីដែលបាននិយាយនៅពេលមុននេះ។ ខ្ញុំគិតថា វាជាពេលវេលាសមស្រប។

[១៣:៥៨:៤៩]

**ប្រធានអង្គជំនុំ៖**

យើងអាហ្នឹងហើយ ដែលយើងមិនឲ្យនិយាយ ព្រោះឥឡូវនេះគឺនីតិវិធី ដែលប្រព្រឹត្តទៅដោយ -- យើងកំណត់នូវរបៀបវារៈ ក្នុងការធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី ដែលយើងបានកំណត់អម្បាញ់មិញនេះគឺឈ្មោះ យឹម សុវណ្ណ។ ហើយនាទីនេះ យើងប្រគល់ឲ្យទៅតំណាងសហព្រះរាជអាជ្ញា ដែលជាភាគីស្នើសុំតាំងសំណួរមុនភាគីឯទៀត។

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអភ័យទោស។ លោកសហព្រះរាជអាជ្ញា យើងខ្ញុំផ្ទាល់នោះគឺថា យើងគោរពសេចក្ដីណែនាំរបស់អង្គជំនុំជម្រះថា ដែលធម្មតាកាលណាយើងសួរដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវតែមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរមុន។ ហើយបន្ទាប់មក សហព្រះរាជអាជ្ញាត្រូវបន្ត តើខ្ញុំចង់សួរថាតើលោកប្រធានអនុញ្ញាតឲ្យធ្វើដូច្នេះដែរឬទេ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសួរមុនហើយ បានតំណាងសហព្រះរាជាសួរជាបន្ទាប់?

[១៣:៥៩:៥៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:០០:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គជំនុំជម្រះអនុញ្ញាត!

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូម -- ជាទម្លាប់ សំណួរតាមធម្មតានោះត្រូវខាងមេធាវីជាតិសួរមុន ខាងលោក សំ សុគង់ ហើយបន្ទាប់មកខ្ញុំជាមេធាវីអន្តរជាតិ សួរជាបន្តទៀតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

[១៤:០១:១៧]

**លោក សំ សុគង់៖**

ជាបឋមខ្ញុំបាទ សូមគោរពលោកប្រធាន ហើយនិងសូមគោរពអង្គសវនាការ ហើយជម្រាបសួរដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** ខ្ញុំមានសំណួរមួយចំនួនសួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ដែលខ្ញុំចែកចេញជាបីផ្នែក។ ហើយក្នុងផ្នែកទី១ ខ្ញុំចង់សួរលោកស្រីទាក់ទងនឹងស្ថានភាពមុនឆ្នាំ១៩៧៥។ សំណួរទី១ ខ្ញុំសួរថា មុនឆ្នាំ១៩៧៥ តើលោកស្រីរស់នៅទីកន្លែងណា?

**លោកស្រី យឹម សុវណ្ណ៖**

**ឆ៖** ចាស លោកមុន១៩៧៥ នាងខ្ញុំរស់នៅភូមិព្រែកត្រែង ស្រុកស្អាង ខេត្តកណ្ដាល។

[១៤:០២:២២]

**ស៖** នៅកន្លែងដែលលោកស្រីរស់នៅ ក្នុងទីរួមខេត្តកណ្ដាលនោះ តើស្ថានភាពនៅពេលនោះ

យ៉ាងដូចម្ដេចដែរ?

**ឆ៖** ចាស កន្លែងស្រុកកំណើតរបស់នាងខ្ញុំរស់នៅមានស្ថានភាពលំបាក ហើយមានទាហានខ្មែរក្រហម ហើយនិងទាហាន លន់ នល់ បានវ៉ៃគ្នា។ នាងខ្ញុំភៀសខ្លួនពីឆ្នាំ១៩៧២ មករស់នៅក្នុងទីក្រុងភ្នំពេញ រហូតដល់ឆ្នាំ១៩៧៥។ ហើយស្ថានភាពគ្រួសាររបស់ខ្ញុំ គឺរស់នៅដោយធម្មតា ដោយមធ្យម។

**ស៖** នៅពេលដែលលោកស្រីមករស់នៅទីក្រុងភ្នំពេញនៅក្នុងឆ្នាំ១៩៧២ តើនៅពេលនោះលោកស្រីជាសិស្សសាលា ឬមួយក៏លោកស្រីធ្វើការងារអី?

[១៤:០៣:៤៩]

**ឆ៖** កាលខ្ញុំមករស់នៅក្នុងទីក្រុងភ្នំពេញឆ្នាំ១៩៧២ នាងខ្ញុំអត់បានរៀនទេ ព្រោះនាងខ្ញុំគ្មានសមត្ថភាពនឹងរៀន ហើយខ្ញុំពិបាកការរស់នៅជាច្រើន។

**ស៖** សំណួរសួរថា នៅពេលដែលលោកស្រីមកដល់ទីក្រុងភ្នំពេញ លោកស្រីបានរស់នៅក្នុងទីក្រុងភ្នំពេញ។ នៅពេលដែលលោកស្រីមករស់នៅក្នុងទីក្រុងភ្នំពេញ តើភ្នំពេញហ្នឹងមានស្ថានភាពបែបណាដែរនៅពេលនោះ?

**ឆ៖** ខ្ញុំមករស់នៅទីក្រុងភ្នំពេញ ខ្ញុំមានពូមីងខ្ញុំនៅក្នុងបន្ទាយស្លឹក ហៅបន្ទាយស្លឹកហ្នឹង បន្ទាយអាំងតង់ដង់ ហើយបន្ទាយមួយទៀត ជាបន្ទាយគុយហ្សេ។ ខ្ញុំរស់នៅកន្លែងហ្នឹងបានរយៈប៉ុន្មានខែទេ ពួកទាហានខ្មែរក្រហមបានផ្លោង -- ខ្ញុំអត់ដឹងផ្លោងពីណាមកទេ ផ្លោងកាត់បន្ទាយហ្នឹងទៅឆេះផ្សារដើមគរ នាងខ្ញុំក៏រត់ចេញពីកន្លែងហ្នឹង បាននាងខ្ញុំមកនៅស្ដាតអូឡាំពិក ជាកន្លែងអង្គការឃែរគេចែកអំណោយដល់ប្រជាជនភៀសខ្លួន។

[១៤:០៥:១២]

**ស៖** នៅពេលនោះលោកស្រីថា នៅពេលនោះមានការបាញ់គ្នា។ តើការបាញ់គ្នានោះ គឺបាញ់គ្នារវាងអ្នកណាជាមួយអ្នកណាដែរ លោកស្រី?

**ឆ៖** ចាស ពេលយប់ឡើងខ្ញុំមិនដឹងថា ទាហានខ្មែរក្រហមផ្លោងពីទិសណាមកទិសណាទេ ព្រោះពេលយប់ឡើងហ្នឹងផ្លោងរកផ្ទះ លន់ នល់។ គឺផ្លោងមួយៗយប់ ពាក់កណ្ដាលយប់បានឈប់ តាំងពីត្រឹមម៉ោងប្រាំបួនរហូតដល់ម៉ោងពីរដណ្ដប់យប់បានឈប់ ហើយនាងខ្ញុំមានភ័យខ្លាច ដោយខ្លាចទាហានខ្មែរក្រហមផ្លោងដាក់ មានសកម្មភាពឆេះដូចផ្សារដើមគរទៀត។

[១៤:០៦:០៩]

**ស៖** នៅពេលនោះៗ តើលោកស្រីមានបានឃើញនៅតាមមន្ទីរពេទ្យ ក៏ដូចជានៅតាមផ្លូវ មានអ្នកជំងឺ ក៏ដូចជាមានសាកសព ក៏អ្នករបួសនៅទីនោះទេ?

**ឆ៖** ចាស មានតាមមន្ទីរពេទ្យ អ្នករបួស និងសាកសពនៅពាសពេញតាមមន្ទីរពេទ្យទាំងអស់។

**ស៖** សំណួរសួរថា នៅមុនឆ្នាំ១៩៧៥ មានន័យថានៅមុនឆ្នាំ -- មុនថ្ងៃទី១៧ មេសា ១៩៧៥ តើឪពុករបស់លោកស្រីមាន -- គាត់ធ្វើការអីដែរ?

**ឆ៖** ចាស នាងខ្ញុំដឹងថា ឪពុកនាងខ្ញុំ គាត់ធ្វើគិញ ប៉ុន្តែអ្នកក្រៅអត់ដឹងទេ ដឹងតែក្រុមគ្រួសាររបស់នាងខ្ញុំទេ។ ប៉ុន្តែគាត់ជាកសិករធម្មតា ភាពអ្នកខាងក្រៅគឺអត់ដឹងគាត់ទេ។

**ស៖** បាទ ចំពោះផ្នែកទី២ ខ្ញុំមានបំណងចង់តាំងសំណួរទាក់ទងនឹងការចាកចេញ ឬក៏ជម្លៀសដោយបង្ខំ។ សំណួរទី១ របស់ខ្ញុំចង់សួរថា នៅពេលដែលខ្មែរក្រហម កងទ័ពខ្មែរក្រហមមកដល់ទីក្រុងភ្នំពេញ លោកស្រីមានឃើញស្ថានភាពទីក្រុងនៅតែមានការបាញ់គ្នារវាងកងទ័ពខ្មែរក្រហម និងកងទ័ព លន់ នល់ ដែរឬទេ?

[១៤:០៨:១៦]

**ឆ៖** ពេលដែលឆ្នាំ៧៥ ថ្ងៃ១៧ មេសា កងទ័ពខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ពេលហ្នឹងអត់មានទាហានបាញ់ -- ទាហាន នល់ នល់ និងកងទ័ពខ្មែរក្រហមបាញ់គ្នាទៀតទេ ព្រោះតែកងទ័ព លន់ នល់ ចុះចាញ់ ដាក់អាវុធចុះហើយ ប៉ុន្តែកងទ័ពខ្មែរក្រហមរំលោភបំពានលើប្រជាជន និងកងទ័ព លន់ នល់ ដោយនាងខ្ញុំភ័យរន្ធត់ គួរឲ្យខ្លាច។

**ស៖** លោកស្រីថានៅក្នុងឆ្នាំ១៩៧៥ ថ្ងៃ១៧ មេសា ហ្នឹង គឺថាពុំមានការច្បាំងគ្នាទេ ដោយតែទាហាន លន់ នល់ គាត់បានចុះចូល។ តើនៅក្នុងស្ថានភាពដែលទាហាន លន់ នល់ ចុះចូលជាមួយទាហានខ្មែរក្រហម តើទាហាន លន់ នល់ ទាំងនោះ ត្រូវបានគេទទួលដោយយកចិត្តទុកដាក់ ឬមួយក៏មានការធ្វើទារុណកម្ម ឬក៏សម្លាប់ដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំឃើញទិដ្ឋភាពនៅនឹងភ្នែក ដូចជានៅចំវត្តព្រះពុទ្ធ នាងគង្គីងព្រះធរណីទាហាន -- នាងខ្ញុំនៅក្មេង នាងខ្ញុំដឹកដៃប្អូនរត់ដើររកមើលពូ ព្រោះពូខ្ញុំធ្វើទាហានបាក់ទ័ពពីទំនប់កប់ស្រូវមក នាងខ្ញុំចេះតែរត់។ ប៉ុន្តែខ្ញុំឃើញទាហានខ្មែរក្រហម ខ្ញុំដូចជាមានអារម្មណ៍ឆ្ងល់ ថាម៉េចបានជាទាហានខ្មែរក្រហមហ្នឹងកាត់សក់ខ្លី ពាក់ខោអាវខ្មៅ ហើយមួលជើងខោ ហើយកាំភ្លើងគ្រប់ដៃ សម្លុតឃើញរថក្រោះពាសពេញ ហើយខ្លះរ៉ៃនឹងស្វាយកាំភ្លើង ខ្លះចងស្លាបសេក។ ហើយអីចឹងបានខ្ញុំឆ្ងល់

ថាមូលហេតុអីបានជាទាហានខ្មែរក្រហមរំលោភបំពានលើកងទ័ព ហើយនិងប្រជាជន ដូចជានាងខ្ញុំ ប្រជាជន១៧ មេសា មានកំហុសអីបានជាទាហានខ្មែរក្រហមស្អប់ពួកអ្នក១៧ មេសា ចាត់ទុកខ្ញុំជាសត្រូវស្លាប់រស់របស់ទាហានខ្មែរក្រហម។

**សៈ** នៅៗថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងក្រុមគ្រួសាររបស់លោកស្រី ក៏ដូចជាលោកស្រីផ្ទាល់ តើមាននរណាខ្លះដែលមកផ្ទះលោកស្រី ដើម្បីប្រាប់លោកស្រីឱ្យៗចាកចេញពីលំនៅដ្ឋាន?

[១៤:១១:១៦]

**ធៈ** ខ្ញុំអត់ដឹងថាអ្នកខាងណាៗទេ គេសុទ្ធតែ សមមិត្តបងៗ ហើយឃើញទាំងបួនទិសហ្នឹងម្ដងមកខាងនេះ ម្ដងមកខាងនោះ ហើយឪពុកខ្ញុំព្យាយាមអត់ព្រមចេញ ពេលវេលាល្ងាច ប្រហែលជាម៉ោងបី។ នាង -- ឪពុកនាងខ្ញុំអត់ព្រមចេញ ហើយខ្ញុំចេះតែតាមសង្កេតមើលឃើញគេមានស្លុកបាយ បាយក្រៀម ហើយលីកាំភ្លើងមក ហើយគេសួរឪពុកខ្ញុំចេញមិនចេញ បើមិនចេញប្រយ័ត្នអាមេរិកាំងទម្លាក់គ្រាប់បែកងាប់ ហើយបើមិនចេញគេនឹងធ្វើ -- គេនឹងសម្លាប់ពួកខ្ញុំចោល ហើយឪពុកខ្ញុំឮអ៊ីចឹងក៏រៀបចំអីវ៉ាន់បានតែត្រឹមខោអាវបន្តិចបន្តួច និងអង្ករបន្តិចបន្តួចក៏នាំគ្នាស្រវារត់ចេញពីកន្លែងខ្ញុំនៅ ចាកចេញដោយៗវេទនាបំផុត។

**សៈ** លោកស្រីអាចប្រាប់បានទេថា នៅពេលដែលក្រុម លោកស្រីថាក្រុមមានច្រើន ហើយតើក្រុមនីមួយៗហ្នឹងមានឯកសណ្ឋានពណ៌អីខ្លះដែលមកផ្ទះលោកស្រី ដែលបង្ខំឱ្យលោកស្រីចាកចេញពីលំនៅដ្ឋាននោះ?

**ធៈ** ចាស ខ្ញុំអត់ដឹងថា ខាងណាមកខាងណា ប៉ុន្តែឃើញស្លៀកពាក់ខ្មៅដូចតែគ្នា។

**សៈ** នៅពេលដែលលោកស្រីឃើញក្រុមនោះពាក់អាវពណ៌ខ្មៅ តើក្រុមនោះមានកាន់អាវុធមកជាមួយដែរឬទេ នៅពេលនោះ?

**ធៈ** ចាស មាន មានស្រី មានប្រុសលីកាំភ្លើង ពាក់អាវខ្មៅបង់កក្រហម មានគ្រប់ដៃ ប៉ុន្តែខ្ញុំអត់ដឹងថាក្រុមណាជាក្រុមណា។

[១៤:១៣:៤២]

**សៈ** នៅពេលដែលក្រុមនោះមកដល់ផ្ទះលោកស្រី លោកស្រីឃើញថាពួកគេប្រដាប់ដោយអាវុធ តើគេបានប្រាប់លោកស្រីថាយ៉ាងដូចម្ដេចខ្លះ? ដើម្បីបង្ខំឱ្យលោកស្រីហ្នឹងចាកចេញពីទីក្រុងភ្នំពេញ ជាពិសេសពីលំនៅដ្ឋានរបស់លោកស្រី។

**ឆ៖** ចាស ពេលគេមក គេថាអង្គការថ្នាក់លើឲ្យចេញ។ ពួក -- ឪពុកខ្ញុំសួរថា "ចេញទៅណាលោក? ចេញទៅស្រុកកំណើត" ហើយថា "ឲ្យចេញតែ៣ថ្ងៃទេ មិនបាច់យកអីទៅខ្លះក៏បានដែរ យកទៅខ្លួនទទេក៏បានដែរ ខ្លាចអាមេរិកាំងទម្លាក់គ្រាប់បែកងាប់"។ ប្រាប់អ៊ីចឹង ហើយឪពុកខ្ញុំសួរថា "លោកអញ្ជើញមកពីខាងណា?" គេអត់មាត់។

[១៤:១៤:៤៣]

**ស៖** ចុះក្រៅពីក្រុមគ្រួសាររបស់លោកស្រី ក៏ដូចជាលោកស្រីផ្ទាល់ តើប្រជាជនពលរដ្ឋ ប្រជាជនផ្សេងទៀតដែលគាត់រស់នៅទីក្រុងភ្នំពេញហ្នឹងមានស្ថានភាពដូចគ្រួសារលោកស្រីដែរឬទេ?

**ឆ៖** ចាស និយាយរួមប្រជាជន១៧ មេសា មានស្ថានភាពដូចគ្នាទាំងអស់ឲ្យតែអ្នករស់នៅក្នុងទីក្រុងភ្នំពេញ។

**ស៖** នៅពេលដែលគេ ទាហានខ្មែរក្រហមបានប្រាប់ឲ្យលោកស្រីចាកចេញពីលំនៅដ្ឋាន តើទាហានខ្មែរក្រហមទាំងនោះទុកពេល -- រយៈពេលប៉ុន្មានៗម៉ោង ដើម្បីឲ្យលោកស្រីរៀបចំអីវ៉ាន់ដើម្បីចាកចេញពីលំនៅដ្ឋាន?

**ឆ៖** ចាស គេទុកពេលប្រហែលជា១៥នាទីទេ បើយើងចេញៗបាន បើយើងមិនចេញគេមានផែនការ តែខ្ញុំឃើញនៅផ្សារអូរឫស្សី ខ្ញុំដឹកដៃប្អូនខ្ញុំទៅមើលនៅផ្សារ ខ្ញុំឃើញផ្ទះមួយហ្នឹងបិទទ្វារ ដល់ពេលខ្ញុំត្រឡប់ពីផ្សារមកវិញ គោះទ្វារអត់បើក គោះទ្វារបើកៗ ហើយខ្ញុំឃើញបាញ់សោរផាំងៗ អូសចេញមកបាញ់ចោលនៅហ្នឹងមាត់ទ្វារ។ ហើយពួកខ្ញុំនាំគ្នារត់រឹងមករកឪពុកម្ដាយខ្ញុំ។

[១៤:១៦:៣៥]

**ស៖** នៅពេលដែលលោកស្រីត្រូវបានចាកចេញពីលំនៅដ្ឋានរបស់លោកស្រី តើលោកស្រីបានឃើញនៅតាមមន្ទីរពេទ្យដូចជាអ្នកជំងឺត្រូវបានគេជម្លៀសចេញពីមន្ទីរពេទ្យដែរឬទេ?

**ឆ៖** ចាស ខ្ញុំឃើញនៅក្នុងពេទ្យបុរីកីឡា ឃើញទាហានដែលត្រូវរបួសពេលជិតថ្ងៃកងទ័ពខ្មែរក្រហមហ្នឹងជិតចូលទៅដល់ ដោយច្រើនពេកអត់ដឹងយ៉ាងម៉េចទេ កងទ័ពខ្មែរក្រហមហ្នឹងច្រានទម្លាក់ចោលៗ ឃើញរបួសអ្នកខ្លះស្លាប់ អ្នកខ្លះរបួស ខ្លះរុញទាំងគ្រែ មានបងប្អូនទៅក៏គេរុញចេញ ខ្លះក៏អត់មានបងប្អូនដេកស្លាប់នៅក្នុងមន្ទីរពេទ្យបុរីកីឡាហ្នឹង។

**ស៖** សូមលោកស្រីបញ្ជាក់ថាមន្ទីរពេទ្យហ្នឹង តើមានទីតាំងនៅម្ដុំកន្លែងណាដែរលោកស្រី?

**ឆ៖** ចាស មន្ទីរពេទ្យហ្នឹងកាល លន់ នល់ ហ្នឹងគេដាក់មន្ទីរពេទ្យនៅក្នុងបុរីកីឡាហ្នឹងតែម្ដង។

មន្ទីរពេទ្យឃោធាហ្នឹងនៅក្នុងបុរីកីឡា។ មន្ទីរពេទ្យកងទ័ព លន់ នល់។ ខ្ញុំអត់ដឹងថា មន្ទីរពេទ្យអី ប៉ុន្តែខ្ញុំដឹងថាមន្ទីរពេទ្យហ្នឹងនៅក្នុងបុរីកីឡា។

**ស៖** នៅពេលដែលលោកស្រីត្រូវបានគេជម្លៀស ហើយលោកស្រីក៏ដូចជាក្រុមគ្រួសារបានចាកចេញពីលំនៅដ្ឋាន តើលោកស្រីចេញទៅច្រកខាងណាវិញនៃទីក្រុងភ្នំពេញ?

[១៤:១៨:៥៨]

**ឆ៖** ពេលដែលខ្ញុំ ថ្ងៃ១៧ មេសា ខ្ញុំពេលល្ងាចប្រហែលជាម៉ោងបី ខ្ញុំ ឪពុកខ្ញុំ និងក្រុមគ្រួសារខ្ញុំបានចាកចេញមក មកតាមផ្លូវផ្សារដេប៉ូ កាត់មកស្ទឹងមានជ័យៗ ហើយគេឃាត់អត់ឲ្យទៅ។ ពួកខ្ញុំបានចុះទៅតាមអូរបែកក្អមៗ កាត់ទៅរកពូរបស់នាងខ្ញុំនៅក្នុងបន្ទាយអូរបែកក្អមហ្នឹង គឺបន្ទាយកាំភ្លើងធំ ពេលខ្ញុំកាត់ទៅដល់អត់ឃើញមានប្រជាជន អត់មានឃើញអ្នកណាទាំងអស់ ឃើញតែសាកសពស្លាប់នៅទីហ្នឹង ហើយក៏ឪពុកខ្ញុំសម្រេចចិត្តកាត់តាមហ្នឹងឡើងទៅថ្នល់ពោធិ៍ចិនតុងវិញ ក្បែរព្រលានយន្តហោះ។ កាត់តាមថ្នល់ហ្នឹងបានឃើញខ្មោចទាហានស្លាប់នៅតាមដងផ្លូវ ហើយខ្ញុំហាក់ដូចជារន្ធត់ដូចជាខ្លាច ហើយអត់ឃើញពូខ្ញុំសោះ។

ហើយដល់ពេលឪពុកខ្ញុំកាត់តាមហ្នឹង ទៅដល់ហួស -- ទន្ទឹមពោធិ៍ចិនតុងហ្នឹង ទៅវត្តវិហារឃ្លូនហ្នឹង ក៏ឪពុកខ្ញុំសម្រេចចិត្តថា ស្នាក់នៅទីហ្នឹងសិន។ នៅទីហ្នឹងប្រហែលជាបួនប្រាំថ្ងៃ ក៏ទាហានខ្មែរក្រហមហ្នឹង ដេញពួកខ្ញុំឲ្យទៅទៀត។ ហើយឪពុកខ្ញុំសួរថា លោកឲ្យខ្ញុំទៅទីណា? ឆ្លើយថា ទៅទីណាទៅៗ ស្រេចតែចិត្ត។ ប៉ុន្តែដល់ពេលខ្ញុំសម្រេចចិត្តថាទៅស្រុកកំណើត គេអត់ឲ្យខ្ញុំទៅ។ ហើយខ្ញុំមិនដឹងទៅណា ផ្លូវណោះគេបិទ ផ្លូវណេះគេបិទ នៅផ្លូវជាតិលេខ៣ មួយគេឲ្យទៅ។ ទៅដល់ -- ដល់ពេលថ្ងៃខ្ញុំចេញទៅហ្នឹង មនុស្សច្រើន ច្រើនសូម្បីតែបែកគ្នាពីរម៉ែត្រឡើងទៅ គឺរកគ្នាអត់ឃើញ។ មានអ្នកឈឺ មានអ្នកខ្លះទៅស្លាប់តាមផ្លូវ ខ្លះជាន់គ្នា ឈឺល្អមៗ ជាន់គ្នាស្លាប់តាមផ្លូវ។

[១៤:២១:០៧]

មានពេលមួយនោះ ខ្ញុំឃើញឡានអ្នកមាន គេជិះឡាន គេរុញឡានទៅ។ ស្រាប់តែខ្មែរក្រហមខ្មែរហ្នឹងទៅ យួរពេក ទម្រាំ ហើយមនុស្សច្រើនពេក ទាញលោកហ្នឹង ចុះពីឡានមក បាញ់មុខប្រជាជន។ ហើយត្រង់តែបាញ់ហ្នឹង ដែលប្រជាជនភ័យ រត់ជាន់គ្នា យកតែប្រាសអាយុ។ ត្រង់ហ្នឹងហើយ បែក -- ខ្លះបែកបងប្អូន បែកម៉ែឪ អត់ដឹងថា ទៅទីណា។ ប៉ុន្តែឪពុកនាងខ្ញុំ គាត់ឆ្លាត គាត់គិតថា ពេលនេះ បើមិនឱបកូនតូចៗ គឺបែកគ្នា។ ហើយគាត់សម្រេចចិត្តថា ឱបពួកខ្ញុំឲ្យជាប់ ចងដៃឲ្យជាប់ ហើយក៏ទៅ

តាមផ្លូវជាតិលេខ៣រហូត ដើររហូត រយៈពេលប្រាំប្រាំមួយថ្ងៃ ទៅដល់ស្ទឹងកំពង់ទួលទឹកថ្លា ក៏នៅសម្រាកត្រឹមហ្នឹងទៅ។

**ស៖** ចំពោះពេលធ្វើដំណើរ ទាំងក្រុមគ្រួសាររបស់លោកស្រី ក៏ដូចជាលោកស្រីផ្ទាល់ ហើយនិងប្រជាពលរដ្ឋផ្សេងៗទៀត នៅពេលដែលគាត់ចាកចេញពីទីក្រុងភ្នំពេញ តើគាត់ធ្វើដំណើរដោយវិធីណា? ដោយថ្មើជើង ឬក៏មានឡានដឹកពួកគាត់ទៅ?

[១៤:២២:៥២]

**ឆ៖** មធ្យោបាយប្រជាជនដែលគេដេញខ្លះបានមានឡានអត់សាំងទៅ រុញទៅ ដាក់អីវ៉ាន់ខ្លះទៅ។ ដូចជាពួកខ្ញុំ ខ្ញុំធ្វើដំណើរទៅតាមគេ គេមានឡានអ៊ីចឹង ចេះតែទៅតិចៗតាមគេទៅ ក៏បានស្គាល់គេអ៊ីចឹង ទៅតាមគេទៅ។ ហើយដូចអ្នកប្រជាជនដែលខ្លះអត់ ក៏រែកទៅ ខ្លះទូលទៅ។ ឃើញសកម្មភាពជាក់ស្តែងនៅនឹងភ្នែក ឃើញសព្វបែប សព្វយ៉ាង។

**ស៖** សំណួរ ចំពោះគ្រួសារលោកស្រី តើមានការលំបាកទេ ក្នុងការធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញទៅកន្លែងផ្សេងៗនោះ?

**ឆ៖** ចាស ចំពោះគ្រួសាររបស់នាងខ្ញុំ រួមទាំងគ្រួសារប្រជាជន១៧ មេសា ទាំងអស់ គឺលំបាកដូចគ្នា។ ភាពភ័យខ្លាច ស្លាប់នៅនឹងមុខ ភាពអត់ឃ្លាន គ្មានម្ហូបអាហារ គ្មានលុយចាយ គឺគ្មានទាំងអស់។ ខ្វះខាតរកតែ -- សូម្បីតែទឹក រកហូបអត់បានផង។

[១៤:២៤:២៦]

**ស៖** ពីខាងលើអម្បាញ់មិញលោកស្រីថា នៅតាមផ្លូវមានមនុស្សយ៉ាងច្រើន ហើយនៅពេលនោះ ឃើញមានការជាន់គ្នាក៏មាន ហើយមានអ្នកដែលឈឺហ្នឹង ក៏មាន ហើយរហូតដល់មានអ្នកស្លាប់ទៀត។ តើលោកស្រីបានឃើញថា អ្នកដែលគាត់មានជំងឺ តើត្រូវបានខ្មែរក្រហម ឬក៏ទាហានខ្មែរក្រហមគាត់ផ្តល់ថ្នាំសង្កូវ ឬក៏ព្យាបាលទៅតាមវេជ្ជសាស្ត្រពេទ្យដែរឬទេ?

**ឆ៖** ចាស គឺគ្មាន។

**ស៖** បើតាមការសង្កេតរបស់លោកស្រី នៅពេលដែលលោកស្រីធ្វើដំណើរតាមផ្លូវ លោកស្រីឃើញមានសាកសពដេកស្លាប់នៅតាមផ្លូវ។ តើសាកសពទាំងអស់នោះជាជនស៊ីវិល ឬក៏ជាទាហានខាងលន់ នល់?

[១៤:២៥:៤៦]

**ឆ៖** ចាស ខ្ញុំឃើញពេលអ្នកស្លាប់នៅតាមផ្លូវហ្នឹង ដូចនៅតាមផ្លូវព្រលានយន្តហោះហ្នឹង ឃើញស្លៀកពាក់អាវទាហាន។ ហើយខ្ញុំក៏មិនបានពិនិត្យមើលថា ប្រជាជន ឬមួយក៏ -- ប៉ុន្តែឃើញតែសម្លៀកបំពាក់ទាហាន ហើយខ្ញុំមិនហ៊ានទៅក្បែរផង ព្រោះអ្នកខ្លះស្លាប់ឡើងហើម អ្នកខ្លះទើបនឹងស្លាប់ ហើយគួរឲ្យអនិច្ចា។

**ស៖** នៅពេលដែលលោកស្រីឃើញសាកសពនៅតាមផ្លូវ ក៏ដូចជាអ្នករបួសទាំងនោះ តើលោកស្រីមានបានឃើញថា សាកសពទាំងនោះត្រូវបានគេប្រមូលទុកមួយដុំ ឬមួយក៏គេធ្វើបុណ្យតាមប្រពៃណីដែរឬទេ?

**ឆ៖** ចាស គ្មាន។ ពេលដែលខ្ញុំចេញទៅឃើញហ្នឹង អត់មានអ្នកណាប្រមូល ហើយគ្មានអ្នកណាធ្វើបុណ្យតាមប្រពៃណី។

**ស៖** ប្រសិនបើជាសាកសពទាំងនោះ មិនត្រូវបានគេប្រមូល ឬក៏យកមកធ្វើបុណ្យ តើសាកសពទាំងនោះ គេស្ថិតនៅក្នុងសភាពបែបណា? តើរប៉ាត់រប៉ាយ ឬមួយក៏នៅជាៗដុំៗ?

**ឆ៖** ចាស នៅរប៉ាត់រប៉ាយ ដូចអ្នកណាស្លាប់នៅត្រង់ណា នៅត្រង់ហ្នឹង គ្មានអ្នកណាប្រមូលដាក់ទុកដាក់ផង។

**ស៖** លោកស្រីបានមានប្រសាសន៍ថា សាកសពទាំងនោះគឺស្ថិតនៅរប៉ាត់រប៉ាយ ហើយចម្លើយរបស់លោកស្រីបានឆ្លើយថា នៅពេលនោះគឺមានមនុស្សណែនណាន់តាន់តាប់រហូតដល់អ្នកមានរថយន្តខ្លះទៀតផង។ តើនៅពេលនោះសាកសពទាំងនោះត្រូវបាន មនុស្សដើរជាន់ ឬក៏ឡានកិនលើសាកសពដែរឬទេ?

[១៤:២៨:២០]

**ឆ៖** ចាស សាកសពទាំងនោះមិនមែននៅលើថ្នល់ទេលោក នៅលើតាមចង្អូរតាមចិញ្ចើមថ្នល់។ ហើយដែលឃើញ ខ្ញុំឃើញគេទាញពីក្នុងឡានយកបាញ់ចោលហ្នឹង ដោយសារឡានហ្នឹងអត់មានសាំង ហើយក៏បងប្អូនក្រុមគ្រួសារគេយកឡានហ្នឹងទៅ អត់មានសាំង គេបានឥវ៉ាន់ដាក់លើហ្នឹងគេរុញទៅ ប៉ុន្តែមនុស្សច្រើនពេកទៅមុខមិនរួច ទៅក្រោយមិនរួច ក៏គេទាញមកបាញ់ចោលនៅហ្នឹងតាមចិញ្ចើមថ្នល់ហ្នឹង តាមអន្លង់ចិញ្ចើមថ្នល់ហ្នឹង។

**ស៖** ចំពោះលោកស្រី ក៏ដូចជាក្រុមគ្រួសារលោកស្រីវិញ ទាក់ទងនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ តើទិសដៅដែលលោកស្រីទៅនោះ ដូចបំណងដែលក្រុមគ្រួសាររបស់លោកស្រីចង់ទៅដែរឬទេ?

**ឆ៖** ចាស នាងខ្ញុំថាទៅស្រុកកំណើត ទៅភូមិព្រៃកគ្រែង ឃុំសិត្បូ ស្រុកស្អាង ហ្នឹងអត់បានទៅទេ។ នាងខ្ញុំទៅនៅស្រុកផ្សេងវិញ។

[១៤:២៩:៥១]

**ស៖** នៅពេលដែលលោកស្រីទៅដល់ទិសដៅ ដែលគេរៀបចំទុកឲ្យលោកស្រីទៅដល់ លោកស្រីថានៅស្រុកផ្សេងនោះ តើនៅទីនោះមានការរៀបចំទុកសម្រាប់លោកស្រីរស់នៅទីនោះហើយឬនៅ?

**ឆ៖** ចាស គឺគ្មាន គឺខ្ញុំទៅដល់ដោយចៃដន្យ។

**ស៖** នៅពេលដែលលោកស្រីទៅរស់នៅទីនោះ តើស្ថានភាពការរស់នៅរបស់លោកស្រីមានយ៉ាងម្តេចដែរនៅពេលនៅទីនោះ?

**ឆ៖** ខ្ញុំអ្នក ១៧ មេសា ខ្ញុំទៅដល់ក្រោយគេ។ គេអ្នកទៅតាមផ្លូវកោះធំ ស្រុកស្អាង ខេត្តកណ្តាលហ្នឹង គេទៅដល់មុន គេរស់នៅមុនទៅ ខ្ញុំទៅដល់ក្រោយ ខ្ញុំទៅសម្រាកនៅវត្តសំប៉ានលើ ហើយខ្ញុំទៅរស់នៅហ្នឹងបាន ១យប់។ គេចេះតែថា ទៅៗអង្គការចាំទទួល។ ហើយខ្ញុំឆ្ងល់ ខ្ញុំអត់យល់ថាអង្គការហ្នឹងម៉េចផង។ អង្គការៗ រកមើលអង្គការអត់ឃើញ ហើយគេថា នោះគេដាំបាយពោតចែកទុកបីបួនខ្ទះអ្ហ៎! ហើយដល់ពេលខ្ញុំទៅដល់នុំងសម្រាក១យប់ ដាំបាយពោតសុទ្ធតែសំបក ហើយខ្ញុំគ្រាន់តែឃើញបានពោត ខ្ញុំយំ។

[១៤:៣១:៤២]

ខ្ញុំយំ ខ្ញុំដឹងថា ឪពុកខ្ញុំឃើញអ៊ីចឹងគាត់រកឆ្លងទៅត្រើយខាងកើត នៅភូមិពោធិបានហ្នឹង ទៅរកបងធម៌គាត់។ ទៅរកក៏បានជួប ព្រឹកឡើងក៏នាងខ្ញុំសម្រាកចេញទៅ នៅត្រើយម្ខាងឃុំពោធិបានវិញ។ ទៅនៅទីហ្នឹង គឺៗអ្នកស្រុកមូលដ្ឋានហ្នឹង សូម្បីតែបងធម៌របស់ឪពុកខ្ញុំហ្នឹងក៏កោសរូសពួកខ្ញុំរកមាសរកខោអាវល្អៗ ហើយនាងខ្ញុំគ្មានខោអាវល្អ គ្មានមាស។ មុនដំបូងទៅនៅ គេដូចជាអបអរសាទរ ដល់ទៅនៅយូរៗបានដឹងចិត្តគេថា គេមានចិត្តស្អប់ពួកខ្ញុំ។ គេរកមាស គេរកខោអាវ គេឆែកខោអាវរកហើយពួកខ្ញុំអត់មានក៏គេចាប់ផ្តើមគំនុំគុំក្អួន គេឲ្យពួកខ្ញុំទៅធ្វើការ ហើយគេគ្មានចែកអីឲ្យទាំងអស់។ ហើយគេចោទថា ពួកខ្ញុំ ១៧មេសា ខ្ជិលច្រអូស គេចវេះ សតិអារម្មណ៍ ហើយខ្ញុំ ៗអត់យល់ថាមូលហេតុអីបានគេស្អប់អ្នក ១៧មេសា ហ្នឹងស្អប់។

[១៤:៣២:៥៨]

តើពួកខ្ញុំធ្វើអីខុស ខ្ញុំជាប្រជាជនដែរហ្នឹង។ ខ្ញុំឆ្ងល់ណាស់ គឺធ្វើការរហូតដល់ខ្ញុំឈឺ គេថា ខ្ញុំហ្នឹង

ឈឺសតិអារម្មណ៍ ឲ្យខ្ញុំដេកហាលថ្ងៃ។ ដេកហាលថ្ងៃ គេថា អូ្ហ! កុំទៅជឿពួកមី ១៧មេសា វាគ្មានធ្វើអីកើតទេ។ វាឈឺសតិអារម្មណ៍ហ្នឹង ហើយខ្ញុំ ខ្ញុំអត់យល់។

**ស៖** សំណួរជាចុងក្រោយរបស់ខ្ញុំ គឺទាក់ទងនឹងការជម្លៀសពីទីក្រុងភ្នំពេញរហូតដល់ លោកស្រីទៅដល់ស្រុកកោះធំ តើលោកស្រីមានបាត់បង់សមាជិកក្រុមគ្រួសារ ក៏ដូចជាឪពុកម្តាយ ហើយដោយមូលហេតុអីដែរ?

**ឆ៖** សូមទោស ខ្ញុំអត់យល់។ សូមលោកសួរមួយសាទៀត!

**ស៖** នៅអំឡុងពេលដែលលោកស្រីធ្វើដំណើរពីទីក្រុងភ្នំពេញ បើតាមចម្លើយរបស់លោកស្រីថា លោកស្រីទៅស្នាក់នៅវត្តសុភាឃ្នួន បន្ទាប់មកទៅកំពង់ទួល ហើយបន្ទាប់មកទៅដល់កាយរូងទៀត ហើយជាចុងក្រោយលោកស្រីបានទៅដល់កោះធំ។ តើនៅក្នុងធ្វើដំណើរដ៏វែងឆ្ងាយនេះ ស្ថានភាពគ្រួសារលោកស្រីបងប្អូនលោកស្រី តើមានអ្នកណាត្រូវបាន ត្រូវស្លាប់ ឬក៏ត្រូវបែកបាក់គ្នាដែរឬទេ?

[១៤:៣៥:០២]

**ឆ៖** ចាស នាងខ្ញុំទៅដល់វត្តកាយរូងហ្នឹង ឪពុកខ្ញុំថា ទៅដល់បានប្រហែលជា៣ថ្ងៃ គេដេញទៅទៀតហើយ គេអត់ឲ្យនៅហ្នឹងទៀតទេ។ ហើយសម្រេចចិត្តថាទៅស្រុក ទៅអត់រួច អ៊ីចឹងមានតែដើរកាត់ពីកាយរូងហ្នឹង ធ្លាក់ទៅសំរោងយោង។ ធ្លាក់សំរោងយោង ធ្លាក់ទៅដល់ ខ្ញុំភ្លេច ទៅអ៊ីចឹងទៅ ខ្ញុំដើរ១ថ្ងៃវាល់ល្ងាចអត់ដល់ អត់ដល់ថ្ងៃទាន់ អត់ដល់ហើយមានរទេះគោគេទៅយក គេទៅដឹកពោត ហើយឪពុកខ្ញុំថា ដើរអត់ដល់អ៊ីចឹង បើដើរទៅមានផលវិបាកហើយ គឺប្អូនតូចៗ។ អ៊ីចឹងមានឈឺចាប់មានពិបាកទៅតាមផ្លូវ គាត់សុខចិត្តដោះនាឡិកាពីដៃឲ្យទៅអ្នករទេះគោហ្នឹង ហើយសុំរទេះគោគេជិះ ហើយខ្ញុំអត់ដឹងថាទៅលិច ឬទៅកើត ទៅជើង ទៅត្បូងទេ។ ជិះមួយយប់ទល់ភ្លឺទៅដល់ស្រុកស្ទឹង គេហៅក្បាលគ្រោះ ខេត្តកណ្តាល។ ដល់ហ្នឹងឡើងបកមកព្រែកអំបិល ទៅឈ្លប គេអត់ឡើងទៀត គេចសុំគេចុះឡើងៗ បានៗឡើងមកដល់ព្រែកអំបិល។ ឡើងមកដល់ព្រែកអំបិលជួបអ្នកស្រុកនៅជាមួយពួកខ្មែរក្រហមគេកៀរចុះមក ក៏សម្រាកនៅហ្នឹងប្រហែល២ម៉ោង ហូបបាយហើយ ក៏ចុះមកដល់សំប៉ាន ខាងសំប៉ានលើ។ ប៉ុន្តែអត់មានបាត់បង់ជីវិតអីទេ បងប្អូនខ្ញុំនៅជុំគ្នា។

[១៤:៣៧:១៣]

**ស៖** នៅពេល សំណួរចុងក្រោយបំផុតហើយ នៅសំណួរចុងក្រោយមួយទៀត។ នៅពេលដែល លោកស្រីទៅដល់ទីដៅដែលលោកស្រីត្រូវនៅនោះ នៅពេលនោះតើខ្មែរក្រហមមានបានហៅលោកស្រី

ដើម្បីប្រជុំ ដើម្បីកត់ប្រវត្តិរូបសង្ខេបរបស់លោកស្រីដែរឬទេ?

**ឆ៖** ចាស ទៅដល់ឃុំពោធិបានហ្នឹង ឃើញឈ្លបគេមកសួរ ចុះឈ្មោះចុះអី ហើយគេហៅប្រជុំ។ គេប្រជុំ -- ប្រជុំហើយគេចាត់ឲ្យពួកខ្ញុំមានសមាជិកក្រុមគ្រួសារហ្នឹងមានប៉ុន្មាននាក់អីចឹង គេឲ្យពួកខ្ញុំទៅចាប់ធ្វើការហើយ អត់មានសួរប្រវត្តិរូបអីថាយ៉ាងម៉េចយ៉ាងម៉ា អត់មានសួរទេ។ គេចាប់ផ្ដើមឲ្យខ្ញុំចេញធ្វើការ។

**លោក សំ សុគង់៖**

បាទ សូមជម្រាបលោកប្រធាន ខ្ញុំអស់សំណួរត្រឹមហ្នឹងហើយ ប៉ុន្តែប្រហែលជាសហមេធាវីខ្ញុំគាត់មានសំណួរបន្ត។ ហើយឆ្លៀតឱកាសនេះខ្ញុំបាទសូមថ្លែងអំណរគុណចំពោះដើមបណ្ដឹងរដ្ឋប្បវេណីលោកស្រី យឹម សុវណ្ណ ដែលបានព្យាយាមឆ្លើយនូវសំណួរ ដែលខ្ញុំបានសួរ។ សូមអរគុណ។

[១៤:៣៨:៤៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាក សមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីកិច្ចដំណើរការសវនាការ។ ហើយអង្គជំនុំជម្រះសូមរំឭកដល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហ -- តំណាងសហព្រះរាជអាជ្ញាថា ទាំងពីរក្រុមនេះមានពេលវេលាតែ១ម៉ោងនេះទៀតទេ។ អីចឹងពិភាក្សាក្នុងការកំណត់នូវពេលវេលាសម្រាប់សួរដេញដោលចំពោះសាក្សី -- ដើមបណ្ដឹងរដ្ឋប្បវេណីនេះឲ្យបានត្រឹមត្រូវ ពេលដែលត្រឡប់ចូលវិញ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៥:០០នាទី)*

[១៥:០០:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានស្តាប់ឮថាយើងត្រូវចប់ម៉ោងបួន ដូច្នេះយើងចាប់ផ្តើមយឺតពេលបន្តិចហើយ។ សូមឲ្យលោកប្រធានមេត្តាអនុគ្រោះយើងផង យើងត្រូវការពេលវេលាបន្ថែមទៀតបន្ថែមទៅលើពេលវេលាដែលបានផ្តល់ជូនអម្បាញ់មិញនេះ ដោយសារថាយើងចាប់ផ្តើមយឺតពេលបន្តិចហើយ។ ក៏ប៉ុន្តែខ្ញុំនឹងព្យាយាមសួរឲ្យបានលឿន។

[១៥:០១:៥០]

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជម្រាបសួរលោកស្រី យឹម សុវណ្ណ។ ខ្ញុំចង់ត្រឡប់ក្រោយបន្តិច គឺត្រឡប់មកសំណួរដែលគេសួរអំពីរយៈពេលដំបូង ក្រោយពេលដែលលោកចាកចេញ លោកស្រីចាកចេញពីភ្នំពេញ។ ខ្ញុំចង់ឲ្យលោកស្រីជម្រាបថា តើលោកស្រីមានបងប្អូនប៉ុន្មាននាក់ដែរនៅពេលដែលលោកស្រីចាកចេញពីទីក្រុងភ្នំពេញនោះ?

**លោកស្រី យឹម សុវណ្ណ៖**

**ឆ៖** ចាស នាងខ្ញុំមានបងប្អូនប្រាំមួយ -- ប្អូនប្រុសបីនាក់។ សូមទោស! ពេលនុំងមានប្អូនប្រុសពីរនាក់ ប្អូនស្រីពីរនាក់។ ទៅដល់ចុងឆ្នាំ៧៥ហ្នឹង ម្តាយខ្ញុំបានបង្កើតបានប្អូនប្រុសមួយទៀត។

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបាននិយាយអំពីអ្នកដែលទៅផ្ទះរបស់លោកស្រីហើយលោកស្រីបញ្ជាក់ថា ពាក់សម្លៀកបំពាក់ពណ៌ខ្មៅ។ តើអ្នកដែលទៅផ្ទះលោកស្រីហ្នឹងជាទាហានមែនទេ?

[១៥:០៣:០៥]

**ឆ៖** ចាស អ្នកទៅឲ្យពួកយើងខ្ញុំចេញពីទីក្រុងភ្នំពេញហ្នឹង គឺមានសម្លៀកបំពាក់ខ្មៅ ខ្លះគេមូលជើងខោ ខ្លះក៏ខ្មៅ ក្រវាត់ក្រមាក្រហម។ ខ្ញុំអត់ដឹងថា -- ខ្ញុំដឹងថាខោអាវខ្មៅហ្នឹងទាហានរបស់ខ្មែរក្រហមហើយ ប៉ុន្តែអត់ដឹងក្រុមណាជាក្រុមណា ខ្ញុំអត់ដឹង។

**ស៖** មិនចាំបាច់ឲ្យលោកស្រីបញ្ជាក់ទេ។ តើលោកស្រីអាចប្រាប់បានទេថា អ្នកដែលទៅផ្ទះ

លោកស្រីហ្នឹងអាយុប្រហែលប៉ុន្មានដែរ? ជាក្មេង ឬជាចាស់?

**ផ៖** ចាស ខ្ញុំអត់ដឹងដែរ មានខ្លះក្មេង មានខ្លះចាស់ ខ្ញុំមិនអាចប៉ាន់ស្មាន ខ្ញុំអត់ៗចាំ។

**ស៖** នៅពេលដែលគេឲ្យលោកស្រីចាកចេញពីផ្ទះ តើគេអនុញ្ញាតឲ្យលោកស្រីយកអ្វីទៅតាមខ្លួនខ្លះ?

[១៥:០៤:៣១]

**ផ៖** គេឲ្យក្រុមគ្រួសារនាងខ្ញុំចាកចេញពីផ្ទះ អ្នកខ្លះថាមិនបាច់យកអីទៅច្រើនទេ គេឲ្យចេញតែ៣ថ្ងៃទេ យកតែខោអាវខ្លះ និងអង្ករខ្លះទៅ ព្រោះចេញរយៈ៣ថ្ងៃទេ ព្រោះខ្លាចកងទ័ពអាមេរិកាំងទម្លាក់គ្រាប់បែក។ គេនិយាយប្រាប់តែប៉ុណ្ណឹង។

**ស៖** នៅពេលដែលឪពុករបស់លោកស្រីមិនព្រមចាកចេញ តើទាហានខ្មែរក្រហមបានគំរាមកំហែងដល់ ឪពុករបស់លោកស្រីទេ?

**ផ៖** ពេលឪពុកខ្ញុំអត់ព្រមចាកចេញ គាត់ចេះតែសួរសមមិត្ត ខ្ញុំសុំនៅបានអត់? តើពន្យារពេលឲ្យពួកខ្ញុំបានអត់? គេថាអត់បានទេ បើអត់ព្រមចាកចេញ អង្គការថ្នាក់លើគេអត់ឲ្យលោកឯងនៅ ទេបើលោកឯងចង់នៅប្រយ័ត្នគេ អង្គការថ្នាក់លើគេ គេមានផែនការ អ៊ីចឹង ដូចថាគេគំរាម អ៊ីចឹងឪពុកខ្ញុំថា គាត់អត់ផ្លូវជ្រើសរើសនឹងសួរ ហើយនិងសុំគេក៏ គេគំរាមខ្លាំងពេក ក៏គាត់សម្រេចចិត្តថា រៀបចំអីវ៉ាន់ តិចតួចហ្នឹងចេញ។

**ស៖** តើគេមានប្រាប់ថា គេនឹងចាត់វិធានការអីនៅពេលដែលយើងមិនព្រមចេញទេ?

**ផ៖** ទាហានខ្មែរក្រហមប្រាប់ថាបើអត់ចេញ គេនឹងបាញ់ចោល គេចោទយើងថាខ្មាំង។ ចង់កៀចនៅ ចោទយើងនឹងថា ទាហាន លន់ នល់ ខ្មាំងបង្កប់ ហើយឪពុកសម្រេចចិត្តថា អ៊ីចឹងគាត់ត្រូវតែចាកចេញហើយ ហើយចេញទៅថា ចង់ទៅស្រុកកំណើត ប៉ុន្តែអត់បានទៅ ចេះតែដើរតាមផ្លូវ ចង់យើងទៅកើតគេឲ្យយើងទៅលិច ហើយចេះតែទៅតាមទាហានខ្មែរក្រហមទៅ។

[១៥:០៦:៥៥]

**ស៖** ចុះអ្នកជិតខាង អ្នកនៅតាមផ្លូវ អ្នកនៅក្នុងសង្កាត់ជាមួយលោកស្រី តើពួកគេត្រូវបង្ខំឲ្យចាកចេញដូចគ្នាដែរទេ?

**ផ៖** ចាស សូម្បីតែមីងមាខ្ញុំហ្នឹង ជម្លៀសមកនៅជិតៗគ្នាហ្នឹង ដល់ពេលចាកចេញហ្នឹងមិនដឹងថាបែកទៅណាអស់ផង។ អត់មានដឹងថា អ្នកណាទៅណា ដល់ពេលស្លន់ស្លោខ្លាំងពេកបែកគ្នាអស់រលីង

អត់ដឹងថាទៅណា អ្នក -- អត់ដឹងថាទៅណា ទៅរៀងខ្លួន។

**ស៖** ចុះអ្នកនៅតាមផ្លូវ ហើយនិងអ្នកនៅក្នុងសង្កាត់ ដែលមិនមែនជាគ្រួសារលោកស្រីនោះ តើគេបង្ខំឲ្យចាកចេញដែរឬទេ?

**ឆ៖** ចាស ទាហានខ្មែរក្រហមចូលដល់ត្រង់ណា គឺប្រជាជនចេញទៅត្រង់ហ្នឹងបាត់ទៅមុន។ ដូចខ្ញុំនៅកណ្តាលគេ ចេញទៅតាមក្រោយ។ ខ្ញុំចេញទៅ គេចេញឡើងស្ងាត់ទីក្រុង ស្ងាត់អស់រលីង។ អត់មានឃើញប្រជាជនទីក្រុងចេញទៅជាមួយខ្ញុំផង មានតែពួកខ្ញុំចេញក្រោយគេ។

[១៥:០៨:៥០]

**ស៖** លោកស្រី តើលោកអាចផឹកទឹកបានទេ នៅពេលដែលលោកស្រី ធ្វើដំណើរចេញពីទីក្រុងទៅនោះ?

**ឆ៖** ចាស នៅពេលហ្នឹងគឺទឹក ដូចជាខ្វះខាត អត់មានអី -- ដូចជាខ្ញុំស្នាក់នៅវត្តវិហារឃ្លួនហ្នឹង ដូចជាប្រើទឹកអណ្តូងទឹកអី ខ្ញុំអត់ចាំ។ ប៉ុន្តែទឹកពិបាក ហើយប្រើសន្សំសំចៃ។

**ស៖** អម្បាញ់មិញនេះ លោកស្រីនិយាយអំពីអ្នកជំងឺ ហើយលោកស្រីបានឆ្លើយទៅនឹងសហភាតារបស់ខ្ញុំពាក់ព័ន្ធនឹងបញ្ហានេះ លោកស្រីថា មិនមានការព្យាបាលអ្នកជំងឺទេ នៅពេលដែល លោកស្រីចាកចេញពីភ្នំពេញ។ ចុះគេមានយកចិត្តទុកដាក់ចំពោះមនុស្សចាស់ដែរឬទេ?

**ឆ៖** ចាស អ្នកជំងឺ ហើយនិងមនុស្សចាស់ ដូចជាគ្មានពេទ្យខ្មែរក្រហមណា ពេល១ដែលថ្ងៃ ១៧មេសា ហ្នឹង ដូចជាអត់មាន ៗឃើញពេទ្យ ឃើញទាំងអស់ គឺរស់ដោយសម្មាអាជីវោ។ នរណាងាប់ៗ នរណារស់ៗ នរណាទៅបាន ទៅ នរណាទៅមិនបាន ទម្លាក់ចោល។

**ស៖** ចុះស្ត្រីមានផ្ទៃពោះ?

**ឆ៖** ខ្ញុំដូចជាអត់ដឹងដែរ ពេលហ្នឹង ខ្ញុំអត់ចាប់អារម្មណ៍។ ព្រោះមនុស្សច្រើនពេក អត់ដឹងថាអ្នកណា អ្នកណាផង។ អត់បានយកចិត្តទុកដាក់រឿងហ្នឹងផង។

[១៥:១១:២២]

**ស៖** នៅពេលដែលយើងមិនអាចជួយអ្នកអស់កម្លាំង អ្នកឈឺ ឬក៏មនុស្សចាស់អ៊ីចឹង នៅពេលដែលយើងមិនអាចធ្វើ ជួយអ៊ីចឹង តើយើងធ្វើម៉េចទៅ? ហើយគេយកអ្នកទាំងអស់ហ្នឹងទៅណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរ រឿងហ្នឹង ព្រោះដូចក្រុមគ្រួសារខ្ញុំ សុំគេដាក់អីវ៉ាន់អ៊ីចឹង ជួយរុញគេទៅ ទៅមុខបាត់ទៅ។ ឯអ្នកក្រោយ ដឹងម៉េចទៀតខ្ញុំអត់ដឹង។ ព្រោះយើងទៅមុខហើយ មិនអាចត្រឡប់មក

ក្រោយវិញបាន។

**សៈ** លោកស្រីបានធ្វើដំណើរដំបូងចេញពីភ្នំពេញ តើលោកស្រីអាចរៀបរាប់អំពីកន្លែងដែលលោកស្រីបានឆ្លងកាត់រហូតទៅដល់កន្លែងដែលលោកស្រីឈប់នោះ គឺភូមិពោធិ៍នោះ?

**ផៈ** ចាស មុនដំបូង ខ្ញុំចេញទៅ ឆ្លងកាត់ទៅផ្សារដេប៉ូ ផ្សារដេប៉ូទៅតាមស្ពានស្ទឹងមានជ័យ គេអត់ឲ្យទៅ ខ្ញុំកាត់ទៅបន្ទាយអូរបែកក្អម។ អូរបែកក្អមហើយ ខ្ញុំកាត់ទៅស្នាក់នៅវត្តវិហារឃ្លួន។ ខ្ញុំចេញពីវត្តវិហារឃ្លួនទៅ ទៅដល់បែកចាន ខ្ញុំទៅតាមផ្លូវជាតិលេខ៣ ទៅដងស្ទឹងកំពង់ទួល វត្តទឹកថ្លាហ្នឹង។ ខ្ញុំចេញពីវត្តទឹកថ្លាហ្នឹង កាត់ដឹងចូលទៅណាទៀត ទៅ ឪពុកខ្ញុំចេះតែនាំទៅ ខ្ញុំចាំថា ភ្នំជ្រៃញ៉ៅហ្នឹង កាត់ពីជ្រៃញ៉ៅឡើងមកថ្នល់ជាតិលេខ៣វិញ។

ជាតិលេខ៣ហ្នឹង ទៅសម្រាកវត្តកាយរូង។ ចេញពីវត្តកាយរូងទៅ ឆ្លង ចេះឆ្លងទៅ កាត់សំរោងយ៉ោង ឡើងទៅព្រៃល្វា។ ព្រៃល្វា មួយយប់ទាល់ភ្លឺហ្នឹង កាត់ទៅទៀត ឡើងទៅដល់ គេហៅ ភូមិគ្រួសស្រុកស្ទឹង ឡើងពីហ្នឹងទៅ ព្រែកអំបិល ចុះពីព្រែកអំបិលមកវិញ បានមកវត្តសំប៉ាន។ ឆ្លងពីវត្តសំប៉ានទៅពោធិបាន បានទៅដល់វត្តពោធិបានហ្នឹង បាននៅកន្លែងវត្តពោធិបាន គេហៅភូមិលេខ៥ ស្រុកកោះធំខេត្តកណ្ដាល។

[១៥:១៣:៥៦]

**សៈ** តើការធ្វើដំណើរលើកដំបូងចេញពីភ្នំពេញនេះ ប្រើពេលអស់រយៈពេលប៉ុន្មានដែរលោកស្រី?

**ផៈ** ខ្ញុំអត់ដឹងថា រយៈពេលប៉ុន្មានផង ព្រោះខ្ញុំចេញទៅ ទៅដល់វត្តវិហារឃ្លួនហ្នឹង ព្រលប់ៗអត់ដឹងថាប៉ុន្មានម៉ោង។ ហើយទៅស្នាក់នៅវត្តវិហារឃ្លួនហ្នឹង ៤-៥ថ្ងៃអ៊ីចឹង បានចេញទៅវត្តទឹកថ្លា គេដាក់ស្ទឹងកំពង់ទួល បាននៅប្រហែលជិតមួយអាទិត្យហ្នឹង គេដេញទៅ ចេះតែផ្លាក់ៗទៅ កាត់ទៅភ្នំជ្រៃញ៉ៅហ្នឹង។ បើសរុបទាំងអស់ ប្រហែលចូលជិត១ខែ បានខ្ញុំផ្លាក់ទៅដល់ភូមិពោធិបាន ភូមិលេខ៥ហ្នឹង។

**សៈ** សូមអរគុណលោកស្រី ហើយលោកស្រីស្នាក់នៅភូមិលេខ៥ហ្នឹង អស់រយៈពេលប៉ុន្មានដែរ?

[១៥:១៥:០៤]

**ផៈ** ខ្ញុំនៅស្នាក់នៅភូមិលេខ៥ ឃុំពោធិបាន ហ្នឹង ប្រហែលជាចុងឆ្នាំ៧០ -- ដើមឆ្នាំ៧៦។ ខ្ញុំនៅស្នាក់ហ្នឹងតាំងពីត្រឹមខែ៤ ចូលខែ៥ ដើមខែ៥ ប្រហែលពាក់កណ្ដាលខែ៥ ហ្នឹងរហូតដល់ដើមឆ្នាំ៧៦ បានគេជម្លៀសពួកនាងខ្ញុំ ចេញពីឃុំពោធិបានហ្នឹងទៅខេត្តពោធិ៍សាត់ សហករណ៍ក្បាលឈើពុក

ស្រុកកណ្ដៀងទៀត។

[១៥:១៥:៥៦]

**ស៖** លោកស្រី ខ្ញុំចង់និយាយអំពីភូមិ៥ ដែលលោកស្រីស្នាក់នៅពីខែឧសភា រហូតទៅដល់ដើមឆ្នាំ៧៦។ នៅក្នុងកំណត់ហេតុ លោកស្រីឆ្លើយថា ខែវិច្ឆិកា ឆ្នាំ៧៥ ដូច្នេះគឺលោកស្រីបានស្នាក់នៅប្រហែល៦ខែ។ នៅពេលដែលលោកស្រីនៅភូមិនោះ លោកស្រីប្រាប់ថា គេហៅលោកស្រីថាជាប្រជាជន១៧មេសា ហើយលោកស្រីគឺថា មិនល្អ។ តើមុនពេលដែលលោកស្រីទៅដល់ភូមិហ្នឹង គេហៅអ្នកភូមិហ្នឹងជាអ្នកភូមិយ៉ាងម៉េចដែរ?

**ឆ៖** ចាស ដែលពួកខ្ញុំអ្នក១៧ មេសា ហ្នឹងគឺអ្នកជម្លៀសចេញពីក្រុងភ្នំពេញ ហើយអ្នកស្រុកហ្នឹងគឺ អ្នកមូលដ្ឋាន។ មូលដ្ឋានហ្នឹង ខ្ញុំអត់ដឹងថា មានន័យថា ម៉េចទេ អ្នកមូលដ្ឋានហ្នឹងគឺគេស្រុកនៅដែលសម័យឆ្នាំ៧០ គេកាត់ផ្លូវត្រឹមស្រុកស្អាង ផ្សារព្រែកតូចហ្នឹងទៅក្រោម ហ្នឹងគេហៅអ្នកមូលដ្ឋាន។

**ស៖** សូមអរគុណលោកស្រី តើមានរបៀបផ្សេងគ្នា ក្នុងការប្រព្រឹត្តចំពោះប្រជាជនមូលដ្ឋានហើយនិងប្រជាជន១៧ មេសាដែរឬទេ? ហើយប្រសិនបើមានការប្រព្រឹត្តខុសគ្នាបែបនេះ សូមលោកស្រីផ្ដល់ជាឧទាហរណ៍។

**ឆ៖** ខ្ញុំយល់ថា ប្រជាជន១៧ មេសា គេចាត់ទុកជាខ្មាំង ហើយអ្នកប្រជាជនមូលដ្ឋានហ្នឹងទុកជាប្រជាជនបដិវត្តន៍ ហើយពួកខ្ញុំអ្នក១៧ មេសា ហ្នឹង ជាខ្មាំងនាយទុន វណ្ណៈសក្តិភូមិ ខ្ញុំអត់យល់។ ខ្ញុំយល់ក្នុងចិត្តខ្ញុំថា មូលហេតុអីខ្មែរដូចគ្នា ម៉េចក៏ចាត់ទុកពួកខ្ញុំជា សុទ្ធតែសក្តិភូមិ អ្នកណាក៏សក្តិភូមិ ខ្ញុំរកតែបាយហូបមិនបានផង ប្រជាជនដូចគ្នាសោះ ខ្ញុំអត់យល់។

[១៥:១៨:២៦]

**ស៖** នៅក្នុងភូមិនោះ តើលោកស្រីត្រូវធ្វើការធ្ងន់ជាងប្រជាជនមូលដ្ឋាន ហើយលោកស្រីទទួលបានអាហារហូបចុកតិចជាងប្រជាជនមូលដ្ឋាន តើមែនទេ?

**ឆ៖** ចាស អ្នក១៧ អាហារទៅដល់មុនដំបូងហូបខ្លួនឯង អត់ -- ហូបអត់គ្រប់គ្រាន់។ ហើយអ្នកមូលដ្ឋាន គេហូបគ្រប់គ្រាន់ គេមានអង្ករស្តុកទុក ពួកខ្ញុំអត់មាន ហើយធ្វើការយ៉ាប់ជាងគេ។

**ស៖** នៅពេលដែលលោកស្រីទៅដល់ភូមិនោះ តើលោកស្រីរស់នៅជាមួយឪពុកម្ដាយ ឬក៏បែកគ្នា?

**ឆ៖** ចាស ទៅដល់ភូមិនោះមុនដំបូងរស់នៅជុំគ្នា។

**សៈ** តើគេឲ្យលោកស្រីធ្វើការនៅអង្គភាពពិសេសណាមួយអ្វីទេ?

[១៥:២០:០៥]

**ឆៈ** ក្រោយមកគេឲ្យខ្ញុំទៅកងនារី។ កងនារីហ្នឹងគេអត់ឲ្យពួកខ្ញុំមកផ្ទះទេ ដឹងថាកងពិសេសហ្នឹងខ្ញុំអត់ដឹងថា យ៉ាងម៉េចទេ ប៉ុន្តែគ្រាន់គេឲ្យទៅប្រមូលផ្តុំចូលកងនារីហើយ។

**សៈ** សូមអរគុណលោកស្រី។ តើបងប្អូនរបស់លោកស្រីនៅក្នុងភូមិនុ៎ងមានបានរៀនសូត្រទេ?

**ឆៈ** ចាស អត់មានបានរៀនសូត្រទេ ខ្ញុំឃើញតែអ្នក ១៨មេសា ហ្នឹងគេហៅ ពួកមូលដ្ឋានហ្នឹងទៅរៀនសូត្រ។ ចំណែកពួកខ្ញុំអ្នក ១៧មេសា អត់បានរៀនទេ។

**សៈ** ចុះលោកស្រីវិញ តើលោកស្រីមានទទួលបានការរៀនសូត្រនយោបាយទេ?

**ឆៈ** ចាស ពួកខ្ញុំគេប្រជុំស្វ័យទិតៀន កសាង គេកសាងខ្ញុំរាល់តែពេលហ្នឹង គេថា ខ្ញុំខ្ជិលច្រអូស គេចវេះពីការងារ ឈឺជំងឺញាក់ ជំងឺញ័រ ឈឺជំងឺសតិអារម្មណ៍។ គេធ្វើ -- និយាយរួមគេទិតៀនតែអ្នក១៧មេសា ហ្នឹងព្រោះអ្នក១៧មេសា អត់ដឹងថា ត្រូវអាម៉េចជាមួយគេផង បានជាគេ ពេលណាមួយអាទិត្យណាក៏គេរករឿង ទិតៀនកសាង។ ខ្ញុំអត់យល់ដែរ។

[១៥:២២:១៣]

**សៈ** អម្បាញ់មិញនេះលោកស្រីនិយាយថា ប្អូនរបស់លោកស្រីហ្នឹងកើតឆ្នាំ៧៥ តើប្អូនរបស់លោកស្រីហ្នឹងកើតនៅថ្ងៃណាខែណាឆ្នាំណាឲ្យប្រាកដលោកស្រី?

**ឆៈ** ចាស ខ្ញុំអត់ចាំដែរ ប៉ុន្តែខ្ញុំដឹងថា កើតចុងឆ្នាំ៧៥ ដើមជិតចូលឆ្នាំ៧៦ ព្រោះពេលកើតបានមិនដឹងប្រហែល១ខែ មិនដឹង ២ខែ ខ្ញុំអត់ចាំ។ ពេលហ្នឹងគេត្រូវការជម្លៀសពួកខ្ញុំចេញទៅខេត្តពោធិ៍សាត់។

**សៈ** ខ្ញុំចង់សួរបំភ្លឺពីលោកស្រី ពីព្រោះថា តាមការបកប្រែនោះ គឺថាកើតនៅចុងឆ្នាំ៧៤ ហើយបន្ទាប់មកស្រីទៅពោធិ៍សាត់ អ៊ីចឹងតើចុង៧៤ ឬក៏ចុង៧៥ សូមលោកស្រីបញ្ជាក់ម្តងទៀត?

**ឆៈ** ចុងឆ្នាំ៧៥ ព្រោះពេលគេជម្លៀសពួកខ្ញុំជាលើកទី២ ទៅខេត្តពោធិ៍សាត់ប្អូនខ្ញុំនៅតូចប្រហែលជា២ខែមិនដឹងអី។ ខ្ញុំអត់ចាំ ប៉ុន្តែខ្ញុំដឹងថាកើតចុង៧៥។

[១៥:២៣:៤៤]

**សៈ** សូមអរគុណលោកស្រី។ នៅពេលសម្រាលកូននោះ តើមានគ្រូពេទ្យអ្វីជួយសម្រាលម្តាយលោកស្រីទេ?

**ឆ៖** ចាស ខ្ញុំឃើញនារីពេទ្យគេហ្នឹងជាយោធា គេបង្កើតឆ្មបតាមភូមិ ពេទ្យតាមភូមិហ្នឹង ឃើញគេមកបង្កើត ប៉ុន្តែត្រង់ថា ឲ្យថ្នាំលេបអីឲ្យអីទៀត គឺដូចជាខ្ញុំអត់បានដឹង អត់បានឃើញផង គ្រាន់ដឹងថា នារីភូមិហ្នឹងជាយោធា ឆ្មបនៅតាមភូមិ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ឆ្មបទាហានហ្នឹងតើគាត់មានអាយុប៉ុន្មានដែរ?

**ឆ៖** ខ្ញុំថាប្រហែល ២០ជាង ព្រោះគេរាងដូចអាយុរាងចំណាស់ អ៎! មិនចំណាស់ទេ ដូចថានៅក្មេងល្មម ប៉ុន្តែខ្ញុំចាំ ខ្ញុំសង្កេតមើលទៅប្រហែលជា ២០ជាង។

**ស៖** សូមអរគុណលោកស្រី។ នៅក្នុងភូមិដែលលោកស្រីរស់នៅរយៈពេល៦ខែនោះដដែល តើលោកស្រីមានកត់សម្គាល់ឃើញមានការចាប់ខ្លួននៅក្នុងភូមិលេខ៥ ដែលជាភូមិដែលលោកស្រីរស់នៅហ្នឹងទេ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំនៅផ្សេង ដល់ពេលធ្វើការទៅ ខ្ញុំអត់ៗដឹង។

[១៥:២៥:៤៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតអាននៃចម្លើយរបស់សាក្សី -- របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារ D246/4 ទំព័រ៦។ ខ្ញុំសូមផ្តល់លេខ ERN ជាភាសាបារាំង 00485487, ជាភាសាអង់គ្លេស 00379313, ជាភាសាបារាំង 00373424។ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីអានសម្រង់ចេញពីឯកសារមួយនេះ។ សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកស្រី យឹម សុវណ្ណ លោកស្រីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា នៅពេលដែលគេសួរលោកស្រីថា "នៅរយៈពេល៦ខែនោះ តើលោកស្រីមានឃើញខ្មែរក្រហមធ្វើបាប ឬសម្លាប់ប្រជាជនដែរឬទេ? ហើយមានការសួរចម្លើយដែរឬទេ?" ហើយលោកស្រីបានឆ្លើយថា "នៅទីនោះមានមន្ទីរសន្តិសុខមួយ ដែលគេហៅថាមន្ទីរ១៥។ ខ្ញុំមិនច្បាស់ថា មានទីតាំងនៅភូមិ១ ឬក៏ភូមិ២នោះទេ។ ដោយសារផ្ទះខ្ញុំនៅជិតទន្លេ ខ្ញុំឃើញគេដឹកមនុស្សតាមទូក ដែលបានចងស្លាបសេក យកទៅដាក់មន្ទីរសន្តិសុខនោះ"។

បន្ទាប់មកទៀត គេបានសួរលោកស្រីទៀតថា "តើមានអ្វីកើតឡើងចំពោះអ្នកនៅមន្ទីរសន្តិសុខនោះ?" ពេលនោះលោកស្រីបានឆ្លើយថា "ប្រជាជនទាំងនោះត្រូវបានគេចោទប្រកាន់ថាជាខ្មាំង ហើយ

គេយកទៅមន្ទីរសន្តិសុខ។ ពួកអ្នកត្រូវបញ្ជូនទៅនោះ គឺគ្មានសង្ឃឹមថានឹងរស់ទេ ហើយបាត់ខ្លួន។ ហើយបន្ទាប់មកទៀតគេសួរសំណួរលោកស្រី "ថាតើមានឃើញការសម្លាប់អ្នកទោស ក្នុងអំឡុងពេល៦ ខែនោះ?" លោកស្រីឆ្លើយថា "ទេ! មិនដែលឃើញទេ។ ខ្ញុំគ្រាន់តែឃើញគេយកមនុស្សទៅមន្ទីរសន្តិសុខ តែប៉ុណ្ណោះ"។ តើអ្នកស្រីនៅតែរក្សាចម្លើយដែលលោកស្រីបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតដែរឬទេ?

[១៥:២៨:០៤]

**លោកស្រី យឹម សុវណ្ណ៖**

**ឆ៖** ចាស ខ្ញុំៗយល់ថា ខ្ញុំបានឃើញមែន ប៉ុន្តែនៅក្នុងភូមិលេខ៥ ហ្នឹង ខ្ញុំអត់ដឹងយកអ្នកណា ប៉ុន្តែអ្នកដាក់ទូកយកទៅ ព្រោះផ្ទះខ្ទមនៅជាប់មាត់ទន្លេហ្នឹង ខ្ញុំឃើញគេចងស្លាបសេកយកទៅមែន ហើយទៅមន្ទីរ១៥ ហ្នឹង។ ប៉ុន្តែនៅក្នុងភូមិខ្ញុំអត់ដឹងទេ ឃើញតែមកពីផ្សេង ដាក់ទូកមកពីក្រោមមកវិញ។ ហើយនៅភូមិមន្ទីរ១៥ ហ្នឹង ខ្ញុំដឹងថានៅភូមិលេខ១ មិនដឹង លេខ២ មិនដឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ត្រង់គេសម្លាប់ខ្ញុំអត់ដែលបានឃើញទេ ព្រោះខ្ញុំទៅធ្វើការគ្រាន់តែខ្ញុំដើរកាត់តាមហ្នឹងទៅ ទៅស្ទូង ទៅដកអី ខ្ញុំឃើញ ឃើញថាមន្ទីរ១៥ហ្នឹង។

**ស៖** សូមអរគុណលោកស្រី។ លោកស្រីស្នាក់នៅ៦ខែនៅក្នុងភូមិនោះ ហើយបន្ទាប់មកលោកស្រីចាកចេញ។ តើលោកស្រីអាចបញ្ជាក់បានទេ ថាហេតុអ្វីបានជាលោកស្រីត្រូវចាកចេញពីភូមិលេខ៥ នុ៎ង?

**ឆ៖** ចាស ដល់ពេល -- ពេលហ្នឹងគេជម្លៀសពួកខ្ញុំចេញ ហើយឪពុកខ្ញុំថា ចង់ទៅសុំគេនៅ។ គេថា "កុំនៅ បើចង់នៅ ត្រូវចូលមន្ទីរ១៥" ឪពុកៗខ្ញុំថា "អីចឹងគាត់សម្រេចចិត្តថាទៅហើយ។ គេជម្លៀស គេឲ្យទៅតាមផែនការរបស់បក្ស អង្គការ" ហើយឪពុកខ្ញុំថាអីចឹង សម្រេចថាចិត្តចេញទៅ។ ហើយពេលហ្នឹងខ្ញុំនៅ កងៗនារីទេ ហើយខ្ញុំនឹក ឮសូរពាក្យថា "គេជម្លៀសអ្នក១៧ ជាលើកទី២" ហើយ។

[១៥:៣០:០០]

ហើយខ្ញុំថា មុនដំបូងខ្ញុំសួរប្រធាននារីខ្ញុំថាអីចេះ "គេអត់ឲ្យនារីទៅទេ" ខ្ញុំថា ខ្ញុំនឹកក្នុងចិត្ត បើអត់ឲ្យខ្ញុំទៅ ក៏ខ្ញុំរត់ទៅដែរ។ ហើយក៏ដល់ពេលជម្លៀសហ្នឹង គេឲ្យខ្ញុំមកជួបជុំគ្នា គេឲ្យខ្ញុំ -- គេចម្លងទូកមករង់ចាំនៅវត្តសំប៉ានលើវិញ។ ហើយដល់ពេលមកសំប៉ានលើហ្នឹង មកដល់ហ្នឹង ឡានយោធា

ហ្នឹងអត់ទាន់ដឹកពួកខ្ញុំឡើងមកបឹងសាឡាងទេ -- អ៎! វ៉ាប្រទះឡាងទេ ចាំនៅហ្នឹង ៣, ៤ ថ្ងៃ។ ឪពុកខ្ញុំក៏ជួបពួកម៉ាកមួយ ខ្មែរក្រហមហ្នឹង គាត់ប្រាប់ថា "អាម៉ាក អ្អែងកុំនៅហ្នឹង អ្អែងនៅហ្នឹងងាប់អស់ហើយ អ្អែងទៅខេត្តបាត់ដំបង ពោធិ៍សាត់ អ្អែងមានអង្ករ មានស្រូវស៊ីច្រើន"។ ហើយក៏ជួបអ៊ីចឹងហើយ បានប្រហែល៣ម៉ោងក្រោយមក ក៏មានឡានមកដឹកពួកខ្ញុំឡើង ដឹកចម្រុះចូលគ្នាទាំង មិនដឹងគ្រួសារណាខ្លះទេ តាមស្ថិតិដែលគេប្រមូលចងក្រងហ្នឹង ក៏ៗឡើងឡានកាត់តាមផ្លូវស្រុកស្អាងហ្នឹង ឡើងមកលើកាត់តាមតាខ្មៅ ឡើងមកវត្តស្លែង ហើយចុះមកវ៉ាប្រទះឡាង ក៏ចាំនៅ -- ចាំរទេះភ្លើងនៅហ្នឹង។

[១៥:៣១:៤៨]

**ស៖** តើគេមានប្រាប់មូលហេតុថា ហេតុអីបានជាលោកស្រីត្រូវចាកចេញ? ហើយហេតុអីបានជាមានការជម្លៀសលើកទី២ ហើយមានដែលលោកស្រីនិយាយមានប្រធានមានអីអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។ គេគ្រាន់ប្រាប់ថា ជម្លៀសអ្នក១៧ ជាលើកទី២។ ខ្ញុំអត់ដឹង អត់យល់ថាយ៉ាងម៉េចផង។ បើខ្ញុំគិត គេចាត់ទុកពួកខ្ញុំជាខ្មាំងរបស់ខ្មែរក្រហម ជាកងទ័ពខ្មែរក្រហមហ្នឹង គេចាត់ទុកពួកខ្ញុំជាខ្មាំង ហើយមិនថាកងទ័ពទេ ប្រជាជនដូចគ្នាហ្នឹងក៏គេចាត់ទុកពួកខ្ញុំជាខ្មាំងដែរ គេមិនដែលអនុគ្រោះឲ្យពួកខ្ញុំ អ្នក១៧ មេសា ផង។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ថាមានតែប្រជាជន១៧ មេសា ទេ ដែលត្រូវគេជម្លៀសចេញនោះ? តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** ក្នុងពេលជម្លៀសលើកទី២ តើលោកស្រីមានទទួលការថែទាំ ទទួលបានទឹក ឬក៏អាហារហូបចុកដែរឬទេ?

[១៥:៣៣:៣១]

**ឆ៖** ខ្ញុំមកស្នាក់នៅវត្តសំប៉ានលើហ្នឹងឃើញគេចែកអង្ករម្នាក់ មួយគ្រួសារ៣គីឡូ។ ហើយមុននឹងរៀបឡើងឡានហ្នឹង គេចែកអង្ករឲ្យ។ ហើយដល់ពេលឡើងឡានទៅដល់ មក ទៅដល់វ៉ាប្រទះឡាងហ្នឹង ពួកខ្ញុំស្នាក់នៅធ្វើ -- ស្នាក់នៅហាលវាលអ៊ីចឹង ចាំរទេះភ្លើង។ ប៉ុន្តែអត់មានផ្គត់ផ្គង់ទឹកអី អត់មានគឺពួកខ្ញុំប្រើទឹកស្ទឹងនៅជាប់ហ្នឹង ហើយមុននឹងឡើងរទេះភ្លើងហ្នឹង ឃើញគេចែកនំប៉ុងឲ្យម្នាក់មួយ។ ឃើញតែប៉ុណ្ណឹង។

**ស៖** លោកស្រីបានឆ្លើយថា ប្អូនរបស់លោកស្រីបានកើតនៅចុងឆ្នាំ៧៥ ហើយប្រហែលជា៥ខែ

-- ៣ខែនៅពេលដែលលោកស្រីចាកចេញ។ តើមានការថែទាំចំពោះម្តាយដែលមានកូនតូចទេ?

**ឆ៖** ថែទាំតែម្តាយក្នុងក្រុមគ្រួសារខ្ញុំ អត់ -- គាត់អត់មានទឹកដោះឲ្យប្អូនខ្ញុំបៅ ហើយគ្នាអត់មាន -- ស្គមរីងរៃ អត់មានអ្នកណាផ្តល់ជំនួយ អត់មានថ្នាំពេទ្យអីទាំងអស់ គឺរស់សម្នាអាជីវោខ្លួនឯង។

**ស៖** តើអ្នកស្រីមានលទ្ធភាពក្នុងការទិញចំណីអាហារ ឬក៏ថ្នាំសង្កូវ ទឹកដោះគោ អ្វីផ្សេងៗទៀតដែរឬទេ ក្នុងពេលធ្វើដំណើរហ្នឹង ថាធ្វើដំណើរទី១ ហើយធ្វើដំណើរទី២?

**ឆ៖** អត់មានទេ ព្រោះពេលហ្នឹង អត់មានចាយលុយតទៅទៀត។ គ្រាន់១៧ មេសា ហ្នឹង គេអត់ចាយលុយផង ត្រឹម១៧មេសា រហូតទៅ គឺអត់មានទាំងអស់។

[១៥:៣៦:០៤]

**ស៖** តើអ្នកស្រីអាចដោះដូររបស់របរអីបានទេ?

**ឆ៖** ចាស អត់មាន។ ពួកខ្ញុំអ្នកជម្លៀសលើកទី២ហ្នឹង គឺអត់មានទាំងអស់។ ត្រង់ចំពោះក្រុមគ្រួសារអ្នក១៧ មេសាផ្សេង ខ្លះគេមានលាក់ទុកទៅ ចំពោះក្រុមគ្រួសារខ្ញុំ គឺអត់មាន រកតែខោអាវស្លៀកអត់ចង់បានផង។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីកន្លែងទី២ ដែលអ្នកស្រីនៅទីនោះ ហើយគឺថានៅចុងរបបខ្មែរក្រហម គឺនៅក្នុងសហករណ៍ បើខ្ញុំអានឈ្មោះមិនសូវត្រូវ គឺសូមអភ័យទោស គឺថានៅក្បាលឈើពុក។ អ្នកស្រីនៅក្នុងសហករណ៍នុ៎ង ហើយបងប្អូនរបស់អ្នកស្រីហ្នឹង ប្រុសស្រីហ្នឹង មានបានគេចាត់តាំងឲ្យនៅក្នុងអង្គភាពពិសេសណាមួយទេ?

**ឆ៖** ខ្ញុំជម្លៀសទៅនៅសហករណ៍ក្បាលឈើពុក ស្រុកកណ្តៀង ឃុំទី៩ ខេត្តពោធិ៍សាត់ ហ្នឹងទៅដល់រស់នៅសហករណ៍ក្បាលឈើពុកហ្នឹង ទៅដល់ប្រហែលជាបីបួនខែ គេចាប់បំបែកប្អូនខ្ញុំឲ្យទៅកងកុមារ។ ឈ្មោះ យឹម វុទ្ធី ហ្នឹង គេចាប់បំបែកឲ្យទៅកងកុមារ ទៅកងពិសេស។ គេចាប់បំបែកម្តងមួយៗ ប៉ុន្តែខ្ញុំអត់បានទៅកងពិសេសហ្នឹងគេទេ ឪពុកខ្ញុំទៅកងជួរផ្សេង ខ្ញុំទៅកងផលិតផ្សេង។

[១៥:៣៨:២២]

**ស៖** សូមអរគុណ។ តើកម្រិតជីវភាពនៅកន្លែងហ្នឹង នៅសហករណ៍ហ្នឹង សម្រាប់ប្រជាជន ១៧ មេសា យ៉ាងម៉េចដែរ? ឧទាហរណ៍ដូចជា ចំណីអាហារ និងទីស្នាក់នៅជាដើមនោះ។

**ឆ៖** នៅសហករណ៍ក្បាលឈើពុកហ្នឹង គេធ្វើផ្ទះជាប់ៗគ្នា ហើយគេចែកម្នាក់មួយបន្ទប់ៗ ប៉ុន្តែទៅនៅហ្នឹង ឪពុកខ្ញុំមុននឹងគាត់ធ្វើអី គាត់គិតថា បើអត់បាយ អត់ចុះ ឲ្យតែនៅជាប់មាត់ស្ទឹង។

ឪពុកខ្ញុំគិតត្រូវ ពេលហ្នឹង ទៅនៅជាប់មាត់ស្ទឹង ដូចជាហូបអី អត់សូវពិបាក ដូចនៅស្រុកកោះធំទេ។ ទៅនៅហ្នឹងគ្រាន់ជាងនៅស្រុកកោះធំ។

[១៥:៣៩:២៧]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមនិយាយអំពីឪពុករបស់អ្នកស្រី ហើយនិងប្អូនស្រីរបស់អ្នកស្រី។ តើនៅក្នុងសហករណ៍ហ្នឹង មានរឿងអីកើតឡើងចំពោះឪពុករបស់អ្នកស្រី?

**ឆ៖** ចាស នៅក្នុងសហករណ៍ហ្នឹង ក្នុងឆ្នាំ១៩៧៨ ហ្នឹង ជិតចូលឆ្នាំ១៩៧៩ ខ្ញុំអត់ចាំខែ ព្រោះខ្ញុំដឹងថា ដកសំណាបជិតអស់ ជិតស្ទូងថ្នាលសំណាប។ ពេលហ្នឹង មេកងហ្នឹងឲ្យឪពុកខ្ញុំអ្នកនៅចាំស្រែ យប់ហ្នឹងមេកងហ្នឹងឲ្យឪពុកខ្ញុំទៅចាំផ្ទះបាយ។ កាលហ្នឹងមេកងថា មានខ្មាំងចូលអុកឡុក ក៏គាត់ទៅចាំ យប់ថ្ងៃហ្នឹង មេកងហ្នឹងដេកនៅហ្នឹងផ្ទះបាយហ្នឹងទាំងអស់គ្នា។ ហើយអាមួយទៀតឈ្មោះ អឿន ហ្នឹងវាអ្នកធ្វើចុងភៅ ប៉ុន្តែវាកាប់មេកងហ្នឹងឈ្មោះ គឿន។ ខ្ញុំក៏អត់ដឹងដែរ។

[១៥:៤០:៣៤]

ស្រាប់ពេលភ្លឺស្រាងៗ គាត់ថា កូនណាណាអាអឿនហ្នឹងកាប់ពូគឿនហ្នឹងបែកក្បាលហើយ។ អ៊ីចឹងកូនឯងជួយជូនគាត់ទៅពេទ្យ។ ខ្ញុំក៏ស្ទុះទៅជួយយកគាត់ទៅពេទ្យ។ យកទៅពេទ្យអស់រយៈមួយអាទិត្យក្រោយមក មេកងមួយ អ៎! មេភូមិមួយទៀតឈ្មោះ រីត វាទៅសួរពូគឿន ហ្នឹង នៅហ្នឹងពេទ្យថា ម៉េចបានលាក់ខ្មាំងទុក? ពូគឿនហ្នឹងថា អត់មានខ្មាំងទេ។ អ្នកយាមហ្នឹងគ្មានដឹងអីទាំងអស់។ អាអ្នកកាប់ហ្នឹង វារត់ទៅបាត់ហើយ។ ហើយអារីតហ្នឹង ម៉េចមិត្តឯងលាក់ខ្មាំងទុកអ៊ីចឹង យកអ្នកឯងទៅដែរ ព្រោះអ្នកឯងកុំថា ប្រធានភូមិ ឬប្រធានកង ហើយក៏គាត់សូមអង្វរគេអត់បាន គេមតិច្រើន មតិប្រធានភូមិ ប្រធានកងហ្នឹងច្រើន។ ក៏ខ្ញុំអត់ដឹងទេ ថ្ងៃហ្នឹងក៏ខ្ញុំទៅ ថ្ងៃមួយខ្ញុំទៅជាមួយគាត់ គាត់ចេះតែសំយ៉ុងមុខចុះ អស់រយៈវិលងមក២ថ្ងៃ ៣ថ្ងៃទៀត ថ្ងៃហ្នឹងដែលជាថ្ងៃចាប់ឪពុកខ្ញុំហ្នឹង គេថា គេអត់វែកបាយឲ្យទៅស្រែទេ ឲ្យមកកង។ ខ្ញុំក៏មក មកខ្ញុំមកដល់ហូបបាយហើយ ខ្ញុំសម្រាកមួយបន្តិចមើលប្អូនខ្ញុំ ក៏ខ្ញុំត្រឡប់ទៅវិញ។

[១៥:៤២:០៣]

ដល់ពេលនោះ ខ្ញុំឃើញឈ្លបដើរនៅមុខខ្ញុំពីរនាក់ ខ្ញុំផ្អាក់ផ្អើមស្រឹប ខ្ញុំមានអារម្មណ៍មួយភ័យ ហើយទៅដល់ពីរនាក់អាប្អូនខ្ញុំ អាមួយឈ្មោះ យឹម វុទ្ធី ហ្នឹងគ្នាស្លាប់ហើយ។ ទៅដល់ឃើញឪពុកគេចាប់ចងស្លាបសេកបីនាក់ នៅហ្នឹងជើងគ្រែ ខ្ញុំក៏អត់ ខ្ញុំអត់ដឹងនិយាយថាម៉េច ខ្ញុំយំ ខ្ញុំយំកកាយដី

ពេញហ្នឹង ហើយវាថា អាណាយំ អាហ្នឹងខ្លាំង។ គេថា អាណាយំអាហ្នឹងខ្លាំងស៊ីរូងផ្ទៃក្នុង ហើយខ្ញុំក៏អត់ហ៊ានយំដែរ ខ្ញុំសុខចិត្តខាំមាត់បោចស្មៅ ហើយឪពុកខ្ញុំក៏មើលពួកខ្ញុំហើយ ក៏វានៅវាអានសុន្ទរកថាថា ពួកខ្ញុំខ្លាំងស៊ីរូងផ្ទៃក្នុង ហើយវាអានហើយ ឪពុកខ្ញុំគាត់សុំថា សមមិត្តបង ខ្ញុំសុំបានទេ? វាសួរសុំអី? សុំសមមិត្តបង អភ័យទោសឲ្យខ្ញុំផង ព្រោះបើសមមិត្តផងចោទខ្ញុំថាខ្លាំង សមមិត្តបងទុកជីវិតប្រពន្ធ និងកូនខ្ញុំឲ្យគ្នារស់ចុះ។ ខ្ញុំសុខចិត្តទទួលកំហុស ថាខ្លាំងចុះ។ វាថាបាន១។ បានអីចឹងក៏វាប្រជុំអីហើយ វាចងខ្សែឪពុកខ្ញុំហ្នឹងទាំងបីនាក់ ជាមួយអ្នកជាមួយនៅក្នុងកងហ្នឹងចងនៅមុខពួកខ្ញុំហ្នឹង ដើរទៅៗតាមផ្លូវ ហើយឪពុកខ្ញុំបោះក្រមាឲ្យខ្ញុំ ហើយផុតពីមុខខ្ញុំបន្តិច វាស្រែកអាក្រោសៗ ពេញថ្នល់ទាំងអស់ទៅដាក់នៅ០៧ហ្នឹង វាថា ខ្លាំងស៊ីរូងផ្ទៃក្នុង ត្រូវកម្ចាត់ចោលឲ្យអស់។ ហើយខ្ញុំពេលហ្នឹងខ្ញុំយំ ខ្ញុំអត់ដឹងថា វាទៅស្រែក -- ខ្ញុំដឹងថា វាស្រែកអាក្រោស ប៉ុន្តែខ្ញុំអត់ដឹងគិតអីចេញ ខ្ញុំគិតតែយំអង្គុយយំធាក់ដីពេញហ្នឹងទៅ។

[១៥:៤៤:១៧]

**ស៖** អ្នកស្រីៗបាននិយាយថា ឪពុករបស់អ្នកស្រីត្រូវបាននាំយកទៅសម្លាប់ ហើយហេតុអ្វីជាអ្នកស្រីដឹងថា គាត់ត្រូវបានគេនាំយកទៅសម្លាប់ចោល?

**ឆ៖** ចាស ព្រោះខ្ញុំដឹងថា វាស្រែកអាក្រោសពេញហ្នឹងទាំងអស់ហើយ ហើយយកទៅដាក់វត្តបន្ទាយយួន ហ្នឹងមានមន្ទីរ០៧ នៅត្រង់ហ្នឹង។ ហើយមន្ទីរ០៧ហ្នឹង ដែលពួកប្អូនស្រីខ្ញុំឈ្មោះ យឹម វណ្ណៈហ្នឹងជាកុមារនៅហ្នឹង ហើយពួកម៉ាកវាហ្នឹងនៅហ្នឹងដែរ។ ពួកម៉ាកប្អូនខ្ញុំកុមារដូចគ្នានៅហ្នឹងទាំងអស់ហើយប្អូនខ្ញុំអត់បានលបមើលទេ លបមើលពួកប្អូនខ្ញុំកុមារមួយស្រីហ្នឹង វាលបមើលឃើញ។ ទៅដល់ថ្ងៃហ្នឹងយប់ហ្នឹងគឺវាសម្លាប់ចោលនៅហ្នឹង។ ប៉ុន្តែមាន១តាហ្នឹងមួយគាត់ចិន ចងទៅជាមួយគ្នា គេមាននាឡិកាមួយគេស្ងួកពួកឈ្លបហ្នឹង គេបានចេញមកវិញ។ ហើយខ្ញុំឆ្ងល់ថា មូលហេតុអីនៅជំនាន់ហ្នឹងមានពុករលួយដែរ។ ហើយខ្ញុំទៅអានសុន្ទរកថា ចាប់ច្រឡំគេឃើញគេសរសេរមកចាប់ច្រឡំ ហើយខ្ញុំចេះតែសួមសួរគេ គេអត់ប្រាប់ខ្ញុំសោះ គេចៗខ្ញុំរហូត ហើយខ្ញុំឆ្ងល់ថា មូលហេតុអីនៅជំនាន់ហ្នឹងចោទថា ខ្លាំងដូចគ្នា។ ហើយម៉េចបានគេរួចមកវិញ ហើយខ្ញុំស៊ើបទៀតថា គាត់មាននាឡិកាមីដូមួយ គាត់ជាចៅកែក្រុមហ៊ុនកប៉ាល់ហោះនៅខេត្តពោធិ៍សាត់។

**ស៖** សូមអរគុណអ្នកស្រី។ តើអ្នកស្រីមានបានយកសាកសពរបស់ឪពុកលោក ហើយក្រោយមករៀបចំពិធីធ្វើបុណ្យអីទេ?

[១៥:៤៦:៣៨]

**ឆ៖** ចាស នៅមន្ទីរសន្តិសុខ ០៧ហ្នឹង សូម្បីតែដើរទៅក្បែរហ្នឹងក៏អត់បានផង ព្រោះនៅហ្នឹងជាមន្ទីរសន្តិសុខគេៗធ្វើឃាតហើយ យើងមិនអាចចេញចូលបាន ហើយនៅជំនាន់ហ្នឹងគ្មាន -- អត់បានធ្វើបុណ្យរឿងប្រពៃណីជាតិអី អត់មានទាំងអស់។

**សៈ** សូមអរគុណ។ តើអ្នកស្រីអាចជម្រាបជូនតុលាការបានទេ អំពីអ្វីដែលកើតមានឡើងទៅប្អូន -- កើតមានឡើងចំពោះប្អូនស្រីរបស់អ្នកស្រី?

**ឆ៖** ចាស ខ្ញុំជម្រាបជូនបានព្រោះប្អូនស្រីរបស់នាងខ្ញុំ នៅកុមារនៅមន្ទីរសន្តិសុខ០៧ ហ្នឹង នៅកន្លែងហ្នឹងមន្ទីរសន្តិសុខផង កន្លែងកុមារផង។ ហើយគ្នាហូបអត់គ្រប់ ហើយកូនក្មេងចែកបបរពីរវែកមួយវែក ហើយគ្រាន់តែគ្នាដកស្រូវដែលស្រូវផើមសោះហ្នឹង! ចោទគ្នាខ្មាំង ហើយគ្នាប៉ុណ្ណឹង យកគ្នាទៅវ៉ៃចូលទៅមន្ទីរ០៨ ហើយប៉ុន្តែមុននឹងវ៉ៃចោទហ្នឹង គ្រូហ្នឹងមកទារចិញ្ចៀនម៉ែ -- ម្តាយរបស់នាងខ្ញុំថា ឲ្យចិញ្ចៀនហ្នឹងមកបាន យឹម វណ្ណៈ ហ្នឹងរួចខ្លួន បើអត់ឲ្យអត់ទេ។ ហើយគាត់ថា អ៊ីចេះ! “ខ្ញុំអត់ឲ្យទេ។ ថាបើអត់ឲ្យអត់រួចខ្លួនទេ”។ ហ្នឹងម្តាយរបស់ខ្ញុំប្រាប់ខ្ញុំ។ ហើយខ្ញុំៗឆ្ងល់អត់ដឹងមូលហេតុអីម៉េចក៏ក្មេងគ្នាដកស្រូវចោទថាគ្នាខ្មាំង ហើយស្រូវផើមហ្នឹងចោទគ្នាខ្មាំង ហើយយកគ្នាទៅវ៉ៃចោល។ ហ្នឹងគ្រូរបស់ប្អូនស្រីខ្ញុំតែម្តង។

[១៥:៤៩:១៦]

**សៈ** ហើយមានរឿងអ្វីកើតឡើងទៀតដែរឬទេ ពេលក្រោយមកនោះអ្នកស្រី?

**ឆ៖** ដល់តែពេលម្តាយខ្ញុំអត់ឲ្យចិញ្ចៀនហ្នឹង គេឲ្យឈ្លបបណ្តើរ ឈ្លប ០៧ហ្នឹង បណ្តើរទៅ ០៨ យកគ្នាទៅដាក់ ០៨ ប៉ុន្តែខ្ញុំអត់បានឃើញទេ។ ហើយតាំងពីពេលហ្នឹងបាត់រហូតៗ អត់ដែលជួបខ្ញុំអត់ដែលជួបមុខប្អូនរហូតតាំងពីពេលហ្នឹងមក ប៉ុន្តែម្តាយខ្ញុំគាត់ឃើញ គាត់ប្រាប់ខ្ញុំ បាត់រហូត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំសូមអរគុណ ដែលបានឆ្លើយតបនឹងសំណួរខ្ញុំទាំងអស់នេះ ហើយខ្ញុំនឹងផ្តល់វេទិកាទៅខាងសហព្រះរាជអាជ្ញា ដើម្បីចោទសំណួរបន្ថែម។ ហើយលោកប្រធាន មុននឹងបញ្ចប់នេះ ខ្ញុំសូមជម្រាបជូនថា អ្នកស្រី យឹម សុវណ្ណ នឹងនិយាយអំពីការឈឺចាប់របស់គាត់ នៅពេលបញ្ចប់ក្រោយពេលដែលគេសួរសំណួរគាត់ទៅទាំងអស់នោះ ដូចដែលករណីសំណុំរឿង០០១ ដែរ គឺថាយើងៗនឹងសរសេរជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យគាត់ជួយ -- ឲ្យគាត់សម្តែងមតិបានស្រួល។ តើលោកប្រធានអនុញ្ញាតដែរឬទេ

ក្នុងការជួយសរសេរបែបនេះ? ហើយចំពោះការថ្លែងទុក្ខរបស់គាត់នេះ តើលោកអនុញ្ញាតដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើដូច្នេះបាន។

[១៥:៥១:១៨]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំគិតថា ប្រហែលជាគាត់នឹងថ្លែងទុក្ខវេទនារបស់គាត់ នៅពេលដែលគេចោទសំណួរទៅគាត់ចប់សព្វគ្រប់អស់ហើយលោកប្រធាន។

អ្នកស្រី ខ្ញុំសូមអរគុណដែលបានឆ្លើយតបនឹងសំណួរទាំងអស់នេះ មានសារៈសំខាន់ណាស់ចំពោះភាគីទាំងអស់ ហើយនិងសាធារណជន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍ន័រ៖**

សូមអរគុណលោកប្រធាន។

[១៥:៥១:៥២]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឃីត រេយ៍ន័រ៖**

**ស៖** អ្នកស្រី យឹម សុវណ្ណ ខ្ញុំចង់ឲ្យអ្នកស្រីពិនិត្យទៅលើចម្លើយរបស់អ្នកស្រី ជាមួយអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេត គឺទៅទំព័រដែលយើងបានដកស្រង់រួចមកហើយ។ លោកស្រីៗ បាននិយាយអំពីពេលវេលាដែលលោកស្រីនៅក្នុងភូមិពោធិបាន ហើយលោកស្រីបានបញ្ជាក់ថា លោកស្រីនៅក្នុងភូមិនេះអស់រយៈពេល៦ខែ ពីខែឧសភា រហូតទៅដល់ខែវិច្ឆិកា ឆ្នាំ៧៥។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**លោកស្រី យឹម សុវណ្ណ៖**

**ឆ៖** ចាស ត្រឹមត្រូវ។

[១៥:៥២:៣៣]

**សៈ** លោកស្រីក៏បានបញ្ជាក់ក្នុងចម្លើយរបស់លោកស្រីផងដែរថា គ្រួសាររបស់អ្នកស្រីទទួលបានផ្ទះខ្ទមមួយ ហើយផ្ទះខ្ទមនេះគឺមានទីទាំងនៅជិតទន្លេ តើត្រឹមត្រូវដែរឬទេ?

**ផៈ** ចាស ត្រឹមត្រូវ នៅចាប់មាត់ទន្លេ។

**សៈ** តើអ្នកស្រីដឹងដែរឬទេ ថានៅពេលនុំងមានកោះមួយ គេហៅថា កោះគ? តើអ្នកស្រីស្គាល់កោះនេះដែរឬទេ?

**ផៈ** ចាស នៅកោះគ ជាស្រុកជាប់ស្រុកកំណើតរបស់នាងខ្ញុំ ខ្ញុំអត់ -- នៅឆ្ងាយពីគ្នា កោះគហ្នឹងនៅខាងលើ ខ្ញុំនៅខាងក្រោម ប្រហែលជាចូល២០, ៣០ គីឡូ។ ខ្ញុំអត់ដឹង ក្រោយមកបានខ្ញុំដឹងថា កោះគ មានធ្វើអត្តឃាតនៅកន្លែងហ្នឹង។

**សៈ** នៅពេលដែលលោកស្រីរស់នៅជិតមាត់ទន្លេនោះ គឺរស់នៅក្នុងផ្ទះខ្ទមនោះ អ្នកស្រីនិយាយថា អ្នកស្រីឃើញគេដឹកមនុស្សតាមទូក យកមកដាក់មន្ទីរសន្តិសុខ។ តើត្រឹមត្រូវដែរឬទេ?

**ផៈ** ចាស ត្រឹមត្រូវ។ ខ្ញុំឃើញដឹកតាមទូក គេដឹកពីក្រោមឡើងមកលើវិញ។

**សៈ** តើប្រហែលជាប៉ុន្មានដង? តើអ្នកស្រីឃើញគេដឹកមនុស្សតាមទូកហ្នឹងប្រហែលជាប៉ុន្មានដង?

**ផៈ** ខ្ញុំបានឃើញតែម្ដងទេ។

**សៈ** តើអ្នកស្រីអាចប៉ាន់ស្មានដែរឬទេ តើថាមានមនុស្សប៉ុន្មាននាក់នៅលើទូកហ្នឹង? គឺគ្រាន់តែប៉ាន់ស្មាន។

**ផៈ** ប្រហែលជាប្រាំនាក់ ប្រាំមួយនាក់ប៉ុណ្ណឹង។

[១៥:៥៥:០៦]

**សៈ** តើមនុស្សដែលប្រាំ ប្រាំមួយនាក់ដែលអ្នកស្រីឃើញនៅលើទូកហ្នឹង គាត់អត់មានគេចងចាប់ចងអីទេ គឺគាត់ ចង់និយាយថាគាត់នៅធម្មតា គ្មានការចាប់ចងអី តើមែនដែរឬទេ?

**ផៈ** ខ្ញុំឃើញគេចងស្លាបសេក។ ហើយខ្ញុំថា បើចងស្លាបសេកហ្នឹងសុទ្ធតែអ្នកទោសហើយ សុទ្ធខ្លាំងហើយបានគេចងស្លាបសេក។

**សៈ** គឺរយៈពេលហ្នឹង គឺរយៈពេលចន្លោះពីខែ៥ ដល់ ខែ១១ ៧៥ ហ្នឹង គឺថាលោកស្រីបានបញ្ជាក់ថា នៅក្នុងភស្តុតាងតាមដែលលោកស្រីចាំ គឺថាខ្មែរក្រហមចាត់ទុកប្រជាជន១៧ មេសា ជាខ្មាំង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ។

[១៥:៥៦:១៧]

**ស៖** តាមដែលលោកស្រីចាំ អតីតទាហានរបប លន់ នល់ ត្រូវបានគេចាត់ទុកថាជាខ្មាំងដែរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ?

**ស៖** នៅពេលនោះ គឺលោកស្រីសង្កេតឃើញថាមានមនុស្សគេចងស្លាបសេក។ តើលោកស្រីគិតថា មានក្រុមខ្មាំង ឬក៏ក្រុមមនុស្សផ្សេងទៀតដែលគេចាត់ទុកថាជាខ្មាំងក្រៅពីប្រជាជន១៧ មេសា និងអតីតទាហាន នល់ លន់ ដែរឬទេ? តើមានក្រុមមនុស្សប្រភេទផ្សេងទៀតដែរឬទេ ដែលគេចាត់ទុកថាជាខ្មាំងនោះ?

**ឆ៖** ខ្ញុំគិតថា ពីឆ្នាំ៧៥ ទៅចុងឆ្នាំ៧៦ ឲ្យតែគេចាប់ចង គឺជាទាហាន លន់ នល់ ហើយនិងប្រជាជន១៧ មេសា។ គេចាត់ទុកថាជាខ្មាំងទាំងអស់។

**ស៖** ពាក់ព័ន្ធទៅនឹងមនុស្សដែលលោកស្រីបានឃើញ គឺលោកស្រីនិយាយថាពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខនោះ។ មនុស្សដែលត្រូវគេយកទៅមន្ទីរសន្តិសុខហ្នឹង តែងតែបាត់ខ្លួន។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ឲ្យតែយកទៅមន្ទីរសន្តិសុខ មន្ទីរ១៥ ហ្នឹង ដឹងតែបាត់ខ្លួន មិនអាចវិលត្រឡប់មកវិញបានទេ។

[១៥:៥៨:០៩]

**ស៖** ដូច្នេះ ខ្ញុំគិតថា មន្ទីរសន្តិសុខ១៥ ហ្នឹង គឺជាមន្ទីរដែលលោកស្រីបានឃើញដោយផ្ទាល់ភ្នែក។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវ ព្រោះភូមិ១, ភូមិលេខ១, ភូមិលេខ២ ហ្នឹង ពួកខ្ញុំទៅច្រូតស្រូវ ស្ទូងស្រូវដល់ហ្នឹង។ ហើយដើរកាត់មុនដែលខ្ញុំជម្លៀសឡើងទៅខេត្តពោធិ៍សាត់។ គេបានបង្កើតមន្ទីរសន្តិសុខ១៥ ហ្នឹងនៅភូមិ -- មិនដឹងភូមិលេខ១, ភូមិលេខ២ ខ្ញុំអត់ចាំ។

**ស៖** លោកបាន -- លោកស្រីបាននិយាយអំពីឪពុករបស់លោកស្រី និងមន្ទីរសន្តិសុខទី៧។ ឥឡូវនេះខ្ញុំចង់និយាយអំពីសហករណ៍ទី២ គឺសហករណ៍ក្បាលឈើពុក។ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខនៅទីនោះ ខ្ញុំចង់និយាយយោងទៅលើចម្លើយរបស់លោកស្រី ជាមួយនឹងសហចៅក្រមស៊ើបអង្កេត គឺលេខ ERN 00379315, ភាសាខ្មែរគឺមានលេខ 00373426, និងភាសាខ្មែរគឺមានលេខ 00373426

គឺលោកស្រីនិយាយអំពីមន្ទីរសន្តិសុខទី -- លេខ ៧។ ខ្ញុំសូមដកស្រង់ "អ្នកដែលនៅមន្ទីរសន្តិសុខ០៧ ស្ថិតក្រោមការឃ្លាំមើលយ៉ាងជិតដល់។ ប៉ុន្តែពួកគេត្រូវបានអនុញ្ញាតឲ្យធ្វើការ ដោយពួកគេត្រូវបាន គេតាមដានយ៉ាងជិតដល់។ ប្រសិនបើពួកគេប្រព្រឹត្តកំហុសទៀត ពួកគេនឹងត្រូវបញ្ជូនទៅ មន្ទីរសន្តិសុខ០៨។ អ្នកទោសមន្ទីរ០៨ វេទនាណាស់។ ដោយសារតែពួកគេត្រូវបានដាក់ខ្នោះដៃ ខ្នោះជើង និងត្រូវធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ"។ តើត្រឹមត្រូវដែរឬទេ?

**ផ៖** ចាស ត្រឹមត្រូវ។ ព្រោះមន្ទីរសន្តិសុខ០៧ហ្នឹង ពេលខ្លះ ដូចថាប្រជាជនមានដៃ មានជើង ល្អួចនេះ ល្អួចនោះទៅ ជួនកាលគេចាប់យកទៅកសាងត្រឹមហ្នឹង កសាងខ្លួនបាន គេពន្លែងមកវិញ បើកសាងអត់បាន គេនឹងចាប់យកទៅដាក់នៅ០៨ បន្តទៅទៀត។ គេបញ្ជូនទៅ ព្រោះមន្ទីរ០៧ ហ្នឹង នៅក្នុងវត្ត។ មន្ទីរ០៨ នៅចុងភូមិ សហករណ៍ក្បាលឈើពុក។

[១៦:០១:២៤]

**ស៖** ខ្ញុំនៅនិយាយអំពីទំព័រដដែល គឺចម្លើយរបស់លោកស្រីនៅទំព័រដដែល នៅពេលដែលលោកស្រីនិយាយអំពីមន្ទីរសន្តិសុខ០៨ ហើយសំណួរបានសួរអំពីមនុស្ស៥០០នាក់ ដែលត្រូវបានគេសម្លាប់នៅទីនោះ ហើយលោកស្រីបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់ "ខ្ញុំបានឃើញប្រជាជនមកពីភូមិភាគបូព៌ាខេត្តស្វាយរៀង ត្រូវបានគេចងជាខ្សែ ហើយបានយកទៅសម្លាប់នៅមន្ទីរសន្តិសុខ០៨"។ តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ផ៖** ចាស ត្រឹមត្រូវ។ ពេលហ្នឹង ពេលខែច្រូតជិតបែកវៀតណាមចូលហ្នឹង ប្រជាជនពីស្វាយរៀងទៅ គេបញ្ជូនទៅនៅសហករណ៍កណ្ដៀង ហើយថៃដន្យថ្ងៃហ្នឹង ពួកខ្ញុំច្រូតហ្នឹង ស្រាប់តែឃើញប្រជាជនសហករណ៍កណ្ដៀងហ្នឹង ពួកបូព៌ាហ្នឹង គេចាប់ចងស្ពាយសេក ដឹកតាមផ្លូវកាត់តាមវាលស្រែរហូត ហើយទទួលពេលហ្នឹង ខ្ញុំកំពុងតែច្រូតហ្នឹង មានយាយមួយចាស់ អាយុ -- ខ្ញុំសួរដូន អាយុប៉ុន្មានហើយ? គាត់ថា គាត់៨០ហើយកូន គាត់ស្រែកទឹកណាស់។ ខ្ញុំថា ខ្ញុំមានទឹកឲ្យដូនហូប ហើយដូនទៅណាវិញ?

[១៦:០២:៤៦]

គាត់ថា អត់ដឹងទៅណាទេកូន ព្រោះគាត់មិនមែនអ្នកស្រុកហ្នឹងទេ គាត់អ្នកស្វាយរៀង។ ហើយខ្ញុំឃើញកូនឈ្លបពីរហ្នឹង វាបង្ខំយាយហ្នឹង ថាញោមឯងទៅឲ្យលឿន គេទៅចោលអស់ហើយ ទៅឲ្យលឿន ហើយខ្ញុំដឹងថា យកទៅៗមន្ទីរ០៨ ហើយ ប៉ុន្តែដូនហ្នឹង វាអត់ចង វាគ្រាន់ក្រៀកបណ្ដើរឈ្លបពីរ

នាក់។ ក្រៅពីហ្នឹងកម្លាំងក្មេងៗ ដូចនៅពេញកម្លាំង គឺគេចងស្ពាបសេក ជាប់ដឹកខ្សែយកទៅទាំងអស់។ ហ្នឹង ខ្ញុំឃើញនឹងភ្នែក ហើយជាការពិត។

[១៦:០៣:៣១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

លោកតំណាងសហព្រះរាជអាជ្ញា តើលោកត្រូវការពេលវេលាប៉ុន្មានទៀត ក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ?

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំសូមតែ ៣នាទីទៀតទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមទោសដែលខ្ញុំត្រូវកាត់។ ការចោទសួរ ខ្ញុំចង់ឲ្យមានការបញ្ជាក់ថាតើព្រះរាជអាជ្ញានឹងនៅរក្សាអំពីផ្នែកនេះដែរឬទេ? ព្រោះថាតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតហ្នឹង គឺថា អ្វីនេះគឺវានៅក្រោយម៉ោងចិតសិប -- ក្រោយឆ្នាំ៧៨។ ដូច្នេះ ប្រសិនបើយើងនិយាយអំពីបញ្ហានេះបន្តទៅទៀត គឺវាហាក់ដូចជានិយាយអំពីអ្វីដែលកើតឡើងនៅក្រោយឆ្នាំ៧៨ គឺវាៗគឺវាហួសពេលយុត្តាធិការ ឬក៏ផ្នែកយុត្តាធិការ ពេលវេលាដែលអង្គជំនុំជម្រះបានពិចារណា ហើយគ្របដណ្តប់នៅក្នុងផ្នែកនៃសំណុំរឿងមួយនេះ។ គឺជាអ្វីដែលយើងមិនចង់ផ្តោតទៅលើនោះទេ។ ដូច្នេះហើយ នេះគឺនិយាយអំពីមន្ទីរសន្តិសុខ ឬក៏ការផ្លាស់ជម្លៀសប្រជាជននៅក្រោយ នៅឆ្នាំ៧៨ ខ្ញុំចង់លើកអំពីបញ្ហានេះ។ សូមអរគុណលោកប្រធាន។

[១៦:០៥:១៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើននូវការកត់សម្គាល់នេះ។ តំណាងសហព្រះរាជអាជ្ញា សូមរៀបចំនូវការតាំងសំណួររបស់លោក ឲ្យក្នុងវិសាលភាពនៃសំណុំរឿង០០២/០១ ជាការសមស្រប ពីព្រោះយើងកំណត់ធ្វើសវនាការនេះតែសំណុំរឿង០០២/០១ គឺជម្លៀសទី១ និងទី២ ទេ។ ហើយអម្បាញ់មិញនេះគឺ វាជាផល

វិបាកនៃការជម្លៀសទី៣ហើយ។ ហើយអង្គហេតុដែលពាក់ព័ន្ធនៅស្រុក នៅខេត្តពោធិ៍សាត់នេះ គឺអង្គហេតុនៃទីកន្លែងសម្លាប់ទួលពោធិ៍ជ្រៃតែមួយគត់។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តបញ្ចប់ទៅ ប្រសិនជានៅមានពេលវេលាតែបន្តិចទៀតប៉ុណ្ណោះ។

**លោក ឃីត វេយ៍ន័រ៖**

ខ្ញុំយល់អំពីការជំទាស់នេះ ហើយក៏ខ្ញុំយល់អំពីសេចក្ដីសម្រេចរបស់លោកប្រធានដែរ។ គោលដៅសំខាន់ដែលខ្ញុំចង់សួរអំពីបញ្ហាក់ចំណុចនេះ គឺចង់ឲ្យសាក្សីផ្ដល់ភស្តុតាងដែលគាត់នឹងនិយាយទាក់ទងទៅនឹងឪពុករបស់គាត់ ដែលត្រូវបានគេយកទៅដាក់មន្ទីរនេះ។

[១៦:០៦:២៦]

**សួរដោយលោក ឃីត វេយ៍ន័រ៖**

**ស៖** លោកស្រី យឹម សុវណ្ណ ភូមិដែលលោកស្រីនៅគឺភូមិក្បាលឈើពុកហ្នឹង តើលោកស្រីមានដឹងដែរឬទេ នៅពេលដែលលោកស្រីមកដល់ឃុំនេះ គឺលោកស្រីមានឮអំពីទួលពោធិ៍ជ្រៃ តើធ្លាប់ឮគេនិយាយអំពីទួលពោធិ៍ជ្រៃទេ នៅពេលដែលលោកស្រីមកដល់ភូមិក្បាលឈើពុកនេះ?

**លោកស្រី យឹម សុវណ្ណ៖**

**ឆ៖** ចាស ឃុំទួលពោធិ៍ជ្រៃហ្នឹង ខ្ញុំធ្លាប់ទៅ ដើរកាត់ទៅច្រូតស្រូវទៅតាមហ្នឹង ហើយកន្លែងសម្លាប់ទាហាន លន់ នល់ ហ្នឹងគឺពួកខ្ញុំទៅអង្គុយលើហ្នឹង។ ហើយខ្ញុំអ្នកស្រុកហ្នឹងថា ហ្នឹងហើយកន្លែងទាហានសម្លាប់ចោល។ ខ្ញុំធ្លាប់ទៅអង្គុយ ប៉ុន្តែខ្ញុំអត់ដឹងថា ពេលណាគេសម្លាប់ទាហានហ្នឹងចោលទេ ខ្ញុំគ្រាន់តែទៅអង្គុយហ្នឹង ហើយខ្ញុំដើរឆ្លងកាត់ទៅច្រូតស្រូវនៅក្នុងព្រៃរនាមបាត់ទៅ។ ហើយជាពាក្យត្រឹមត្រូវពិតប្រាកដ។

**ស៖** តើនៅពេលណាដែលលោកស្រីដឹងព័ត៌មានអំពីទួលពោធិ៍ជ្រៃ? តើនៅពេលណាដែលលោកស្រីបានទទួលព័ត៌មាន ដែលគេប្រាប់លោកស្រីអំពីបញ្ហាទួលពោធិ៍ជ្រៃនេះ? ហើយនៅភូមិណាដែរ?

[១៦:០៨:០២]

**ឆ៖** នៅខ្ញុំទៅច្រូតស្រូវឆ្នាំ៧៦ ចុងឆ្នាំ៧៦ ចូល៧៧ គឺខែដែលខែដកស្ទូង ពួកខ្ញុំទៅច្រូតស្រូវដើរកាត់ពីឃុំក្បាលឈើពុកហ្នឹង ឆ្លាយទៅទួលគូ ឆ្លាយទៅទួលគូហើយ ឆ្លាយទៅភូមិពោធិ៍ហ្នឹង គេហៅឃុំទួល -- ខ្ញុំមុនដំបូង ខ្ញុំអត់ចាំទេ ដល់ពេលខ្ញុំទៅពោធិ៍សាត់ម្ដងទៀត ខ្ញុំបញ្ជាក់អ្នកស្រុកហ្នឹងគេថា

មាន។ ហើយខ្ញុំសួរថា ខ្ញុំអត់ចាំដែរ ប៉ុន្តែខ្ញុំធ្លាប់ទៅអង្គុយលើហ្នឹង រហូតដល់ -- មើល៍ចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ គឺពួកខ្ញុំឆ្លងកាត់ទៅតាមហ្នឹងរហូត ច្រូតស្រូវ។

**ស៖** ខ្ញុំចង់ឲ្យបញ្ជាក់ នៅពេលដែលលោកស្រីដឹងអំពីអង្គហេតុមួយនេះ បើតាមដែលលោកស្រីដឹងតើទួលពោធិ៍ជ្រៃហ្នឹង ជាទីតាំងសម្លាប់មនុស្សដែរឬទេនៅពេលនោះ?

**ឆ៖** ចាស ទីតាំងសម្លាប់ទាហាន លន់ នល់ ព្រោះទាហានខ្មែរក្រហមហ្នឹងថា អ្នកណាធ្វើអីអ្នកណាស័ក្តិអី អ្នកណាស័ក្តិប៉ុន្មានមកទាហានប្រមូលទៅធ្វើការវិញ ហើយដូចអ្នកខ្លះអត់ចាប់អារម្មណ៍អ៊ីចឹងឮសូរអ៊ីចឹងជឿតាមគេ គេដាក់ឡើងឡានៗ យកទៅសម្លាប់ចោលនៅហ្នឹងទាំងអស់។ សម្លាប់ចោលហ្នឹង គឺចុងឆ្នាំ -- ពេលដើមឆ្នាំ៧៥ ហ្នឹងពេល ថ្ងៃ១៧មេសា ហ្នឹងរយៈពេល -- អ្នកស្រុកប្រាប់ខ្ញុំរយៈពេលប្រហែលជាកន្លះខែក្រោយ។

**ស៖** នៅពេលដែលលោកស្រីនៅទីតាំងនៅតំបន់នោះ តើលោកស្រីមានឃើញទីតាំង ឬក៏ឃើញកន្លែងសម្លាប់មនុស្ស ឬក៏កន្លែងកប់សាកសព ឬក៏ឃើញផ្នូរ ឬក៏លោកស្រីមានឃើញស្លាកស្នាម ឬក៏អ្វីដែលបង្ហាញថា មានការកាប់សម្លាប់នៅទីនោះដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់មានឃើញស្លាកស្នាម ក៏ប៉ុន្តែគ្រាន់ថា ឃើញទួលហ្នឹងគេឈូសលុប ហើយខ្ញុំក៏អត់ដឹងថា គេសម្លាប់ទាហាន លន់ នល់ នៅកន្លែងហ្នឹងដែរ ខ្ញុំទៅ -- ខ្ញុំហត់ពេក ខ្ញុំដើរកាត់តាមហ្នឹងទៅឆ្ងាយ ហើយហូបអត់គ្រប់គ្រាន់ទៅអង្គុយលើហ្នឹងមានដើមឈើជ្រក ទៅអង្គុយទៅ ហើយអ្នកស្រុកសហករណ៍ក្បាលឈើពុកហ្នឹងមានបងប្អូនគេស្លាប់នៅហ្នឹង គេប្រាប់ថា កន្លែងហ្នឹងជាទីតាំងសម្លាប់ទាហាន លន់ នល់។ ហើយខ្ញុំក៏ហីទៅ ខ្ញុំអត់មានចាប់អារម្មណ៍អីផង គ្រាន់តែដឹង ហើយនិងឮប៉ុណ្ណឹង។

[១៦:១១:៤៦]

**ស៖** នៅពេលដែលយើងនិយាយអំពីទីតាំងសម្លាប់មនុស្សថា តើវាជាដីវាល ឬក៏មានអគារ ឬក៏មានផ្ទះសម្បែង ឬក៏មានទីតាំងអ្វីដែរទេនៅទីនោះ ឬក៏ជាដីវាលទេ?

**ឆ៖** ចាស ដីវាល នៅ -- ដីវាល ហើយនៅជាប់ៗទន្លេសាប របៀបដីវាល វាលធំអ៊ីចឹង ហើយនៅជាប់ព្រៃរនាម។

**ស៖** នៅក្នុងការពិភាក្សា ដែលលោកស្រីពិភាក្សាជាមួយនឹងអ្នកដទៃហ្នឹង តើមានការបញ្ជាក់អំពីចំនួនមនុស្ស ឬក៏ចំនួនទាហាន លន់ នល់ ដែលគេយកមកសម្លាប់នៅទីនោះទេ? មានការបញ្ជាក់ពីចំនួនមនុស្សដែលស្លាប់នៅទីនោះទេ?

[១៦:១២:៤៦]

**ឆ៖** គេអត់បញ្ជាក់បាន ព្រោះគេដឹងតែប្រជាជនហ្នឹងដឹងថា ដឹកទាំងឡានៗយកមក គេអត់អាចបញ្ជាក់ប្រជាជន ទាហាន លន់ នល់ ស្លាប់ហ្នឹងបាន ហើយមិនថា ទាហាន លន់ នល់ ទេ អ្នកធ្វើការរដ្ឋការទាំងអស់ ឲ្យតែថាខ្លួនអ្នកធ្វើអីធំដុំគ្រាន់បើ ដឹងតែគេយកទៅសម្លាប់ចោល។

**លោក ឃឹត វេយ៍ន័រ៖**

លោកស្រី សុវណ្ណ សូមថ្លែងអំណរគុណចំពោះលោកស្រីដែលបានឆ្លើយតបនៅសំណួរនេះ។ ហើយលោកប្រធានខ្ញុំសូមអភ័យទោសដែរ ដែលខ្ញុំសួរលើសពីរយៈពេល៣នាទី ដែលខ្ញុំបញ្ជាក់។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោកមេធាវីចង់មានបញ្ហា -- លើកបញ្ហាអីទៅ?

[១៦:១៣:៥១]

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ខ្ញុំមានចំណុចពីរ។ ចំណុចទី១ គឺដើម្បីជាប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី គឺខាង នួន ជា អត់មានសំណួរទេ ហើយខាងមេធាវីដទៃៗទៀត ក៏បញ្ជាក់ថាមិនមានសំណួរដែរ។ ដូច្នេះប្រហែលជាដើមបណ្តឹងរដ្ឋប្បវេណីនេះ អាចសម្រាក អាចត្រឡប់ទៅផ្ទះវិញបានដោយមិនមានបញ្ហាទេ នៅចុងសប្តាហ៍នេះ។ ខ្ញុំមិនមានចេតនាថា ជម្រាបប្រាប់ឲ្យលោកប្រធានត្រូវធ្វើបែបណានោះទេ។ គ្រាន់តែជាការផ្តល់ព័ត៌មានតែប៉ុណ្ណោះ។

[១៦:១៤:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៤:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណណាស់នូវព័ត៌មាននេះ។ ហើយមានបញ្ហាអីទៀត?

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

បញ្ហាមួយទៀត គឺអ្វីដែលខ្ញុំចង់និយាយ ថាតើខ្ញុំអាចធ្វើអ្វីដែលនៅពេលព្រឹកថ្ងៃចន្ទ? តើមាន

ព័ត៌មានអ្វីដែរ? ឥឡូវនេះម៉ោងបួនដប់ប្រាំហើយ។ ខ្ញុំចង់ដឹងថា ប្រធានបទគឺចង់និយាយអំពីអ្វីដែលលោកចៅក្រមបាននិយាយនៅពេលដើម គឺការ -- មុនពេលដែលយើងសួរដើមបណ្ដឹងរដ្ឋប្បវេណីនេះ ខ្ញុំគិតថា ប្រហែលជានឹងមានការលើកឡើងដូចគ្នាចំពោះសាក្សីដទៃទៀត ហើយលោកប្រធានកែប្រែផង ប្រសិនបើខ្ញុំនិយាយខុស គឺថាលោកបាននិយាយអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយជនជាប់ចោទដែលត្រូវបានចោទប្រកាន់។ បញ្ហាដែលខ្ញុំមាន គឺថា ខ្ញុំមិនមែនជាការវាយប្រហារដោយផ្ទាល់នោះទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៦:០៧]

**ប្រធានអង្គជំនុំ៖**

បាទៗ លោកឲ្យខ្លឹមសារនៃកម្មវត្ថុដែលបញ្ហាដែលលោកចង់លើកឡើងហ្នឹង លើកអីគេ? បញ្ហានេះដូចយើងបាននិយាយគ្នាច្រើនលើកច្រើនហើយ ហើយគួរតែស្ដាប់យល់ហើយ។ យើងមិនដឹងថា តើលោកមានបញ្ហាអីដែលមិនយល់ ឬក៏យ៉ាងម៉េច? ឬបញ្ហាដែលអង្គជំនុំជម្រះជម្រាបថា ប្រសិនបើលោកមានបំណងចង់និយាយបញ្ហាអី លោកឲ្យប្រធានបទនៃបញ្ហាដែលលោកចង់និយាយនេះ ចង់និយាយបញ្ហាអី? ដើម្បីឲ្យយើងសម្រេចឲ្យលោកនិយាយ ឬក៏មិនឲ្យលោកនិយាយ។ ចៀសវាងលោកប្រមាថដល់ការដំណើការគ្រប់គ្រងដំណើរការគ្រប់គ្រងសវនាការរបស់យើង ថាតើយើងធ្វើទៅវាមិនបានម៉ឺងម៉ាត់ មិនបានគ្រប់ជ្រុងជ្រោយ។

**លោក អេនគ្រូ អ៊ីទ្ធូហ្ស៊ី៖**

លោកប្រធាន ជាដំបូងខ្ញុំមិនចង់ធ្វើការប្រមាថទៅលើកិច្ចដំណើរការនីតិវិធីទេ ហើយខ្ញុំសូមអភ័យទោសប្រសិនបើថា អ្វីដែលខ្ញុំនិយាយហ្នឹង គឺជាការប្រមាថមើលងាយ ការពិតវាជាសំណើសុំដ៏តូចមួយរបស់ខ្ញុំទេ ដែលនិយាយពាក់ព័ន្ធទៅនឹងអ្វីដែលលោកប្រធានបាននិយាយ មុនពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីនេះគាត់ផ្ដល់សក្ខីកម្ម។ ហេតុដូច្នេះ ខ្ញុំចង់ឲ្យមានការបញ្ជាក់ឲ្យច្បាស់ ហើយដោយយឺត។

[១៦:១៧:៣៥]

ខ្ញុំបានឮលោកប្រធានមានប្រសាសន៍ថា គឺថា នៅពេលដែលលោកប្រធានពន្យល់ទៅលើដើមបណ្ដឹងរដ្ឋប្បវេណីនេះ លោកប្រធានមានប្រសាសន៍ថា ហើយប្រសិនបើខ្ញុំនិយាយខុស សូមលោកប្រធានកែផង ខ្ញុំកត់ត្រាតាមអ្វីដែលខ្ញុំបាន គឺឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់។ នេះគឺជាបញ្ហាដែលខ្ញុំចង់លើកឡើង គឺដោយសារតែមានការមិនបញ្ជាក់ឲ្យបានច្បាស់ទៅលើ

ពាក្យ "ឧក្រិដ្ឋកម្ម"។ លោកប្រធាន! បើតាមខ្ញុំយល់ លោកប្រធានគួរតែបញ្ជាក់ ប្រសិនបើខុស សូមលោកប្រធានប្រាប់ផង គឺថាបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ដែលប្រព្រឹត្តឡើងជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់។ ដូច្នេះ គឺខ្ញុំមិនចង់និយាយថា គឺខ្ញុំមិនចង់និយាយអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយថ្នាក់ក្រោម ឬក៏ថ្នាក់មូលដ្ឋាននោះទេ។ ដូច្នេះហើយថា យើងត្រូវបញ្ជាក់ឲ្យច្បាស់ ថាតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មអ្វី? ហើយជាឧក្រិដ្ឋកម្មអ្វី? អានេះជាអ្វីដែលខ្ញុំចង់តវ៉ា។ ហើយតើវាមានទំនាក់ទំនងទៅនឹងអ្វីបន្តទៅទៀត។

[១៦:១៨:៤១]

ហើយខ្ញុំចង់និយាយអំពីឯកសារ E163 គឺជាការជូនដំណឹងអំពីសេចក្ដីសម្រេចទៅលើសំណើរបស់ព្រះរាជអាជ្ញា ទាក់ទងទៅនឹងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង០០២/០១។ ហើយដោយការគោរព គឺថាបន្ថែមទៅលើការសម្លាប់នៅទួលពោធិ៍ជ្រៃ។ ដូច្នេះហើយការប្រើពាក្យថា "ការសម្លាប់" គឺថាការសម្លាប់មិនមានន័យថាឲ្យច្បាស់លាស់ ប៉ុន្តែនិយាយអំពីការសម្លាប់ គួរតែថាការសម្លាប់នៅឆ្នាំ៧៥ ឬក៏ដល់៧៧។ ដូច្នេះការនិយាយថា ការសម្លាប់ទទេ វាហាក់ដូចជាមិនមានន័យឲ្យបានគ្រប់គ្រាន់នោះទេ។ នេះជាចំណុចមួយដែលខ្ញុំចង់និយាយ។ ហើយខ្ញុំគិតថា ខ្ញុំមិនមែនចង់លើកឡើងដើម្បីរំខានដើម្បីបន្ទុចបង្អាក់នោះទេអ្វីនោះទេ គ្រាន់តែចង់ឲ្យមានលក្ខណៈច្បាស់លាស់ ទាំងសាធារណជន ក៏ដូចជាអង្គជំនុំជម្រះ ដើម្បីឲ្យមានការនិយាយឲ្យបានច្បាស់ពីការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មដែលបានធ្វើឡើងដើម្បីឲ្យមានការបញ្ជាក់អំពីកម្រិតនៃការទទួលខុសត្រូវ។ ដោយសារតែមិនមាន --។

[១៦:១៩:៤៨]

ដូច្នេះខ្ញុំសង្ឃឹមថា ខ្ញុំបញ្ជាក់ចំណុចខ្ញុំដែលចង់និយាយចង់ឲ្យបានច្បាស់លាស់ ហើយខ្ញុំសង្ឃឹមថាខ្ញុំមិនបានធ្វើឲ្យមានការប៉ះពាល់ដល់អារម្មណ៍ ដល់អង្គជំនុំជម្រះ ឬដល់ចៅក្រមណាមួយនោះឡើយ។ ដូច្នេះខ្ញុំគិតថា ខ្ញុំនឹងព្យាយាមប្រើប្រាស់ពាក្យឲ្យបានត្រឹមត្រូវ ហើយខ្ញុំនឹងបញ្ជាក់ថា អង្គជំនុំជម្រះបានសម្រេចថា ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ហើយការសម្លាប់ត្រូវបានធ្វើ។ ដូច្នេះប្រសិនបើមានការសម្រេចបែបនេះ គឺខ្ញុំមិនមានអ្វីត្រូវបញ្ជាក់បន្ថែមទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីជាតិការពារក្ដីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ អំមិញយើងគាំទ្រសំណើ និងយោបល់របស់លោក អេនឌ្រូ អ៊ីនូហ្ស៊ី ហើយថាមកទល់នឹងពេលនេះ បន្ទាប់ពីចប់សំណួររបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមក យើងអត់មាន -- ខ្ញុំខាងខ្ញុំអត់មានសំណួរសួរសាក្សីនេះទេ ប៉ុន្តែយើងសូមដូរជំហរនេះវិញ ក្នុងករណីដែលមានលោកចៅក្រមសួរសំណួរ ហើយបន្ទាប់ពីការសួរសំណួររបស់លោកចៅក្រម យើងនឹងពិចារណាថា យើងនឹងៗសួរដែរឬយើងអត់។ តែក្នុងករណីដែលលោកចៅក្រមអត់មានសំណួរទេ យើងអត់មានសំណួរដែរ។ សូមអរគុណ។

[១៦:២១:០៩]

**ប្រធានអង្គជំនុំ៖**

ចុះមេធាវីការពារក្តីលោក ខៀវ សំផន យ៉ាងម៉េចដែរ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ យើងខ្ញុំមេធាវីក្រុមមេធាវីការពារលោក ខៀវ សំផន អត់មានសំណួរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទេបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៦:២១:៥០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំចង់ធ្វើការកត់សម្គាល់មួយ។ ខ្ញុំគិតថា ទោះបីជាគាត់មានការពិចារណាយ៉ាងក៏ដោយ ក៏ខ្ញុំគិតថាវាមិនសមស្របទេក្នុងនិយាយបែបនេះ នៅក្នុងសវនាការបែបនេះ។ ការនិយាយបែបនេះគួរតែនិយាយនៅពេលដែលគាត់ចាកចេញពីបន្ទប់សវនាការ។ គាត់ ឥឡូវនេះគាត់កំពុងតែនៅទីនេះ គាត់បង្ហាញអំពីភាពសំខាន់ នូវអ្វីដែលគាត់ឆ្លងកាត់ ហើយដល់អ៊ីចឹង សូមឲ្យពិភាក្សានៅពេលផ្សេង កុំឲ្យមានវត្តមានរបស់គាត់នៅទីនេះ។ ហើយប្រសិន -- ឥឡូវនេះម៉ោងបួនម្ភៃហើយ វាអាចជាការលំបាកដែលគាត់អាចថ្លែងអំពីទុក្ខសោករបស់គាត់ វាហួសម៉ោងយឺតពេលទៅហើយ។ យើងត្រូវការពេលវេលាដើម្បីឲ្យគាត់ថ្លែងឲ្យបានសមរម្យ។ ហើយដូច្នេះ គាត់ត្រូវតែមកនៅថ្ងៃចន្ទ ដើម្បីឲ្យគាត់មកថ្លែងនូវទុក្ខសោករបស់គាត់។ យើងមិនអាចឲ្យគាត់ធ្វើនៅពេលនេះ វាពេលប្រថុចញ៉ុចពេកនោះទេ។

[១៦:២២:៥២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា និងស្ថានភាពព្យសនកម្មដែលកើតមានចំពោះខ្លួនគាត់។ ការខូចខាតផ្លូវចិត្ត ផ្លូវកាយ ឬសម្ភារៈជាព្យសនកម្មផ្ទាល់ដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋដែលបានកើតមានពិតប្រាកដរហូតមកដល់ពេលបច្ចុប្បន្ន ដែលនាំឲ្យប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទទាំងបីរូប នួន ជា, អៀង សារី, ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងវិសាលភាពសំណុំរឿង០០២/០១ គឺកើតឡើងក្នុងដំណាក់កាលជម្លៀសប្រជាជនដំណាក់កាលទី១ និងទី២ និងក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ រហូតដល់ដំណាច់ឆ្នាំ៧៦ ឬក៏យូរដើមឆ្នាំ៧៧។ នេះជាវិសាលភាពនៃព្យសនកម្មដែលកើតមាន ហើយអាចប្តឹងទាមទារបង្ហាញអំពីសម្តែងនូវទុក្ខសោកវេទនារបស់ខ្លួន។

បាទ នេះគឺចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះចំពោះដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតហ្នឹង គឺនៅក្នុងវិសាលភាពសំណុំរឿង០០២/០១ ហ្នឹងយើងបានកត់បន្ថែមហើយ យើងបើកទូលាយនូវវិសាលភាពបន្ថែមលើអង្គហេតុនៃទីកន្លែងចល័តទួលពោធិ៍ជ្រៃមួយទៀត។ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីណាដែលមានពាក់ព័ន្ធនៅក្នុងអង្គហេតុទួលពោធិ៍ជ្រៃ គឺអាចថ្លែងរៀបរាប់អំពីទុក្ខសោកវេទនារបស់ខ្លួន ដែលពាក់ព័ន្ធជាមួយនឹងផលអន្តរាយដែលខ្លួនកើតមាន ដោយសារឧក្រិដ្ឋកម្មដែលបង្កឡើងនូវចំពោះក្រុមគ្រួសារញាតិសន្តានរបស់ខ្លួន នៅអង្គហេតុទួលពោធិ៍ជ្រៃ។

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយនៅថ្ងៃចន្ទ សប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-25។

[១៦:២៦:០៥]

ហើយលោកស្រី យឹម សុវណ្ណ ការស្តាប់សក្ខីកម្មរបស់លោកស្រីបានចប់សព្វគ្រប់ហើយ ប៉ុន្តែនីតិវិធីរបស់តុលាការ គឺផ្តល់សិទ្ធិឲ្យលោកស្រីធ្វើសេចក្តីថ្លែងរៀបរាប់ អំពីទុក្ខសោកវេទនារបស់លោក

ស្រី ប៉ុន្តែដោយសារពេលវេលាមិនអាចប្រព្រឹត្តទៅបាន ពេលវេលាវាដល់ទីបញ្ចប់ហើយសម្រាប់ថ្ងៃនេះ។ ដូច្នេះ អង្គជំនុំជម្រះតម្រូវឲ្យលោកស្រីមកថ្ងៃចន្ទទៀត ដើម្បីថ្លែងរៀបរាប់នូវទុក្ខសោកវេទនារបស់លោកស្រី នៅពេលផ្ដើមដំបូងនៃដំណើរការសវនាការ។

ហើយមន្ត្រីតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ចាប់ផ្ដើមអ៎! នៅវេលាម៉ោងប្រាំបួនព្រឹក។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទពីររូប នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឲ្យនាំខ្លួនពួកគាត់ទាំងពីររូបមកកាន់បន្ទប់សវនាការនេះវិញ នៅថ្ងៃចន្ទដើមសប្ដាហ៍ក្រោយ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:២៧ នាទី)*